មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ឆ្នាំ ២០១៥

# ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នា នៅតាមសាលារៀនក្នុងប្រទេសកម្ពុជា



ឧបត្ថម្ភដោយ

rfsu

# អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") គឺជាអង្គការមិនមែនរដ្ឋាភិបាល ("អង្គការ") មិនចូលបក្ស សម្ព័ន្ធ ឯករាជ្យ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឱ្យកម្ពុជាក្លាយជាព្រះរាជាណាចក្រមួយគ្មានអំពើហឹង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិមនុស្សជាមូលដ្ឋាន មានសមភាពត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ និងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍប្រទេស។ ម.ស.ម.ក ចង់បាននិតិរដ្ឋជាជាងនិទណ្ឌភាព ចង់បានស្ថាប័នរឹងមាំជាជាងបុគ្គលខ្លាំង និងចង់បានសង្គមពហុនិយមដោយក្នុងនោះភាពចម្រុះបែបនៃសង្គមត្រូវបានទទួលយកនិងសាទរ ជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក រំលេចអោយឃើញរូបសត្វព្រាបស ហើរ ចេញពីរង្វង់មូល នៃផ្ទៃមេឃពណ៌ខៀវដែលនេះជានិមិត្តរូបនៃការទាមទារសេរីភាពរបស់កម្ពុជា។

របាយការណ៍ដែលមានចំណងជើងថា "របាយការណ៍ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា" ("*របាយការណ៍*") គឺជាសមិទ្ធផលការងារមួយនៃគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័ររបស់ម.ស.ម.ក ។ គម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រត្រូវបានចាប់ផ្តើមអនុវត្តក្នុងឆ្នាំ២០០៩ ក្នុងគោលបំណងផ្តល់អំណាចដល់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ("អ្នកស្រឡាញ់ភេទដូចគ្នា") តស៊ូមតិដើម្បីសិទ្ធិរបស់ពួកគេ និងចងក្រងបណ្តាញជាមួយនឹងដៃគូនានាដើម្បីបង្កើនការលើកស្ទួយនិងការការពារសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា។

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ អាចរៀបចំទៅបានដោយមានការគាំទ្រពីសមាគមអប់រំអំពីផ្លូវភេទរបស់ប្រទេសស៊ុយអែត (Riksförbundet för Sexuell Upplysning) ("RFSU") តាមរយៈការគាំទ្រហិរញ្ញវត្ថុរបស់ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអែត ដែលហៅកាត់ថា ស៊ីដា។ ម.ស.ម.ក សូមថ្លែងអំណរគុណដល់អង្គការដៃគូរនានារួមមានអង្គការអនាគតយុវជនកម្ពុជាអា ស៊ាន អង្គការសុខភាពបុរសកម្ពុជា និងសហគមន៍ឥន្ទធនូកម្ពុជា ចំពោះការចូលរួមចំណែកដ៏មានតម្លៃរបស់ពួកគេ។ ជាទីបញ្ចប់ ម.ស.ម.ក សូមថ្លែងអំណរគុណដល់អ្នកចូលរួមនៅក្នុងការអង្កេត ការសម្ភាសន៍ និងការពិភាក្សាក្រុម ដែលបង្កើតបានជាមូលដ្ឋានសំខាន់ក្នុងការសិក្សាស្រាវជ្រាវនេះនិងជាពិសេស សូមអរគុណដល់សិស្សដែលបានអនុញ្ញាតឱ្យដាក់រូបថតនៅលើក្របសៀវភៅនេះ។ ខ្លឹមសារនៃរបាយការណ៍នេះ គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ ម.ស.ម.ក។

# សំណួរ និងមតិឆ្លើយតប

ប្រសិនបើអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬប្រសិនបើអ្នកមានបំណងចង់ផ្ដល់មតិឆ្លើយតប សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈ info@cchrcambodia.org។ ឬសូមទាក់ទងមក ម.ស.ម.ក តាមរយៈអាសយដ្ឋាន ៖

ផ្ទះលេខ៧៩៨ ផ្លូវលេខ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន
រាជធានីភ្នំពេញ ប្រទេសកម្ពុជា

អ៊ីម៉ែល info@cchrcambodia.org
ទូរសព្ទ +៨៥៥(០)២៣ ៧២ ៦៩ ០១
ទូរសារ +៨៥៥(០)២៣ ៧២ ៦៩ ០២
គេហទំព័រ www.cchrcambodia.org

CC BY NC SA

# មាតិកា

ពាក្យកាត់ ........ v
និយមន័យ ........ vii
មូលន័យសង្ខេប ........ viii
១. សេចក្តីផ្តើម ........ 1
២. គោលបំណង វិសាលភាព និងវិធីសាស្រ្ត ........ 4
៣. អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងប្រទេសកម្ពុជា ........ 10
៣.១. ក្របខ័ណ្ឌច្បាប់ - ច្បាប់របស់ប្រទេសកម្ពុជា ........ 10
៣.៣. ឥរិយាបថសង្គម ........ 15
៤. បរិបទសាកល ៖ ការសម្លុតយុវជនដែលជាអ្នកស្រឡាញ់ ........ 19
ភេទដូចគ្នា ........ 19
៤.១. សេចក្តីផ្តើម ........ 19
៤.២. អាស៊ី ........ 20
៤.៣. អឺរ៉ុប ........ 23
៤.៤. សហរដ្ឋអាមេរិច ........ 24
៤.៥. ប្រទេសអូស្រ្តាលី ........ 25
៥. របកគំហើញ ........ 27
៥.១. ប្រេវ៉ាឡង់ និងទម្រង់នៃការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រតាមសាលារៀន ........ 27
៥.២. ការឆ្លើយតបចំពោះការសម្លុត ........ 37
៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ........ 44
៧. គន្ថនិទ្ទេស ........ 50

# ពាក្យកាត់

| | |
|---|---|
| ជំងឺអេដស៍ | រោគសញ្ញាដែលធ្វើឱ្យប្រព័ន្ធសាំនិងមេរោគថយចុះ |
| អាស៊ាន | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ខេមអេស៊ាន | អង្គការអនាគតយុវជនកម្ពុជាអាស៊ាន |
| ស៊ី-ដ | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ |
| ស៊ី អ ស៊ី | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ |
| ក្រមរដ្ឋប្បវេណី | ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ និង២០១១ |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ក.ព.ក | ការពិភាក្សាក្រុម |
| មេរោគហ៊ីវ | វីរុសដែលនាំឲ្យចុះខ្សោយភាពស៊ាំរបស់មនុស្ស |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ក.ស.ស.វ.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ សង្គម វប្បធម៌ និងនយោបាយ |
| ច.ស.ម.អ | ច្បាប់សិទ្ធិមនុស្សអន្តរជាតិ |
| អ្នកស្រឡាញ់ភេទដូចគ្នា | ស្រីស្រឡាញ់ស្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ |
| អឹម អេច្ឆ ស៊ី | អង្គការសុខភាពបុរសកម្ពុជា |
| ប.ស.ប | បុរសស្រឡាញ់បុរស |
| សង្គមស៊ីវិល | អង្គការសង្គមស៊ីវិល |
| របាយការណ៍ឆ្នាំ២០១០ | "ចេញជាចំហរនៅព្រះរាជាណាចក្រកម្ពុជា ៖ ពលរដ្ឋខ្មែរដែលស្រឡាញ់ភេទដូចគ្នា" របាយការណ៍ បោះពុម្ពផ្សាយដោយ ម.ស.ម.ក ខែធ្នូ ឆ្នាំ២០១០ |
| របាយការណ៍ឆ្នាំ២០១២ | "ឥន្ទធនូខ្មែរ ៖ ប្រែការរើសអើងទៅជាមោទនភាព" បាយការណ៍ បោះពុម្ពផ្សាយ ដោយ ម.ស.ម.ក ខែធ្នូ ឆ្នាំ២០១២ |
| គម្រោង | គម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រដែលអនុវត្តដោយ ម.ស.ម.ក |
| របាយការណ៍ | របាយការណ៍ "របាយការណ៍ការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នា នៅតាមសាលារៀនក្នុងប្រទេសកម្ពុជា" |
| អ អេហ្វ អេស យូ | សមាគមអប់រំអំពីផ្លូវភេទរបស់ប្រទេសស៊ុយអ៊ែត |

| | |
|---|---|
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| រ៉ក់ | សហាគមន៍ឥន្ទធនូកម្ពុជា |
| ស៊ីដា | ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិប្រទេសស៊ុយអ៊ែត |
| សូជី | និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ |
| សូជីអ៊ី | និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/និងការបង្ហាញនូវទំនោរយេនឌ័រ |
| អេស អេស អេ ជី យ្យូ | ការសួរសំណួរអំពីយេនឌ័រ និងការទាក់ទាញចំពោះភេទដូចគ្នា |
| ស.ប.ស.ស | សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស |
| ចក្រភពអង់គ្លេស | ចក្រភពអង់គ្លេស |
| សហ | អង្គការសហប្រជាជាតិ |
| យូ អិន ឌី ភី | កម្មវិធីអភិវឌ្ឍន៍ អង្គការសហប្រជាជាតិ |
| របាយការណ៍ យូ អិន ឌី ភី | របាយការណ៍កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិឆ្នាំ២០១៤ "ការធ្វើជាអ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ី៖ របាយការណ៍សម្រាប់ប្រទេសកម្ពុជា |
| យូណេស្កូ | អង្គការសហប្រជាជាតិស្តីពីការអប់រំ វិទ្យាសាស្រ្ត និងវប្បធម៌ |
| សហរដ្ឋអាមេរិក | សហរដ្ឋអាមេរិក |

# និយមន័យ

**និន្នាការភេទ** សំដៅទៅលើអារម្មណ៍ស្រឡាញ់ មនោសញ្ចេតនា ឬចំណាប់អារម្មណ៍ផ្លូវភេទទំនាក់ទំនងផ្លូវភេទរបស់បុគ្គលម្នាក់ទៅលើបុគ្គលផ្សេងទៀតដែលមានភេទជាក់លាក់ណាមួយអាចជាបុគ្គលភេទផ្ទុយគ្នាឬទៅលើបុគ្គលទាំងពីរភេទ។

**ការបង្ហាញនូវទំនោរយេនឌ័រ** សំដៅទៅលើការបង្ហាញឡើងនូវអាកប្បកិរិយារបស់បុគ្គលតាមទំនោរផ្នែកយេនឌ័ររបស់ខ្លួន។ ក្នុងន័យនេះអាចរាប់បញ្ចូលទាំងការបញ្ចេញឥរិយាបថ និងឫកពាខាងក្រៅដូចជាតាមរយៈការស្លៀកពាក់ ការតុបតែងខ្លួន ការសម្តែងកាយវិកា ការនិយាយ ការដាក់ឈ្មោះ និងការបញ្ចេញសំឡេង។

**អត្តសញ្ញាណយេនឌ័រ** សំដៅទៅលើអារម្មណ៍ខាងក្នុងផ្ទាល់ខ្លួននិងបទពិសោធន៍របស់បុគ្គលម្នាក់ទៅលើយេនឌ័ររបស់ខ្លួនដែលនេះអាចឬមិនអាចស៊ី សង្វាក់ទៅនឹងភេទពីកំណើតរបស់បុគ្គលនោះទេ។

**យេនឌ័រ** សំដៅលើតួនាទី អាកប្បកិរិយា សកម្មភាពនានាដែលសង្គមបានកំណត់ឡើងហើយដែលនេះនាំឱ្យសង្គមជាអ្នកកំណត់ថាបុគ្គលនោះថាជាបុរសឬស្ត្រី។

**ភេទ** សំដៅទៅលើលក្ខណៈក្រូម៉ូសូមអ័រម៉ូន(ជីវសាស្ត្រ)និងលក្ខណៈសរីរាង្គបន្តពូជនិងភេទរបស់បុគ្គលម្នាក់ដែលបានកំណត់ថាជាភេទប្រុសនិងភេទស្រី។

**អ្នកស្រឡាញ់ភេទដូចគ្នា** សំដៅដល់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរសអ្នកស្រឡាញ់ភេទទាំងពីរភេទនិងអ្នកប្តូរភេទ

**ការរើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នា** ការរើសអើងទៅលើបុគ្គលដោយផ្អែកលើនិន្នាការភេទរបស់ពួកគេ។

**ការរើសអើងទៅលើអ្នកប្តូរភេទ** ការរើសអើងទៅលើបុគ្គលដោយផ្អែកលើអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។

**អ្នកប្តូរភេទ** ជាពាក្យសម្គាល់ទៅលើបុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និងការសំដែងចេញនូវយេនឌ័រខុសពីភេទពីកំណើតរបស់បុគ្គលនោះ។

# មូលន័យសង្ខេប

របាយការណ៍នៃការស្រាវជ្រាវនេះគឺជាលទ្ធផលនៃការស្រាវជ្រាវទូទាំងប្រទេសមួយអំពីការសម្លុតដែលស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទនិងអ្នកប្តូរភេទ (“អ្នកស្រឡាញ់ភេទដូចគ្នា”) ជួបប្រទះក្នុងអំឡុងពេលដែលពួកគេសិក្សានៅតាមសាលារៀននៅក្នុងប្រទេសកម្ពុជា និងផលប៉ះពាល់រយៈពេលវែងនៃការសម្លុតបែបនេះ។ របាយការណ៍នេះត្រូវបានរៀបចំឡើងក្រោយពីមានការរកឃើញនូវចំណុចខ្វះខាតដ៏ធំមួយ ពាក់ព័ន្ធនឹងអ្វីដែលគេដឹងពីបទពិសោធន៍របស់សិស្សជាអ្នកស្រឡាញ់ភេទដូចគ្នាតាមសាលារៀនក្នុងប្រទេសកម្ពុជា។

ការស្រាវជ្រាវជាច្រើនបង្ហាញថាឥរិយាបថរើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នា និងឥរិយាបថរើសអើងទៅលើអ្នកប្តូរភេទកើតមានជាទូទៅនៅតាមគ្រឹះស្ថានអប់រំទូទាំងសកលលោក ហើយសម្មតិកម្មបែបនេះត្រូវបានបញ្ជាក់ថាពិតជាមានមែន តាមរយៈលទ្ធផលនៃការស្រាវជ្រាវនេះ។ របាយការណ៍នេះបង្ហាញពីរបកគំហើញនៃការអង្កេតទូទាំងប្រទេស ការពិភាក្សាក្រុម ការសម្ភាសន៍និងការស្រាវជ្រាវលើឯកសារពាក់ព័ន្ធដូចជាការសិក្សាពីគ្រប់ទិសទីក្នុងពិភពលោក និងផ្តល់នូវអនុសាសន៍ទៅលើដំណោះស្រាយទៅលើបញ្ហានៃការសម្លុតជាលក្ខណៈប្រព័ន្ធដោយសារនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រក្នុងប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា។

**ជំពូកទី ១ (សេចក្តីផ្តើម)** បង្ហាញពីវត្ថុបំណងធំៗនៃការស្រាវជ្រាវនេះនិងបង្ហាញដោយសង្ខេបពីទិដ្ឋភាពរួមនៃស្ថានភាពបច្ចុប្បន្ននៃសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងប្រទេសកម្ពុជា និងសារៈតារនៃការសិក្សានេះ។

**ជំពូកទី ២ (គោលបំណង វិសាលភាព និងវិធីសាស្រ្ត)** បង្ហាញជារួមអំពីវិធីសាស្រ្ត ដែលត្រូវបានប្រើសម្រាប់រៀបចំសេចក្តីព្រាងរបាយការណ៍នេះ និងធ្វើការស្រាវជ្រាវដើម្បីរៀបចំរបាយការណ៍នេះក៏ដូចជាមានការបង្ហាញពីដែនកំណត់នៃការស្រាវជ្រាវនេះផងដែរ។

**ជំពូកទី ៣ (បរិបទនៃប្រទេសកម្ពុជា)** ផ្តល់ព័ត៌មានសង្ខេបអំពីស្ថានភាពបច្ចុប្បន្ននៃ សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា រួមនឹងការពិនិត្យលើស្ថានភាពច្បាប់ និងឥរិយាបថសង្គមដែលកើតមានជាទូទៅក្នុងប្រទេសនេះ។

**ជំពូកទី ៤ (បរិបទសកល)** បង្ហាញពីការពិនិត្យលំអិតលើទិន្នន័យពាក់ព័ន្ធនឹងការសម្លុតលើយុវជនពាក់ព័ន្ធនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ ដែលទទួលបានពីការសិក្សានានាជុំវិញពិភពលោក។

**ជំពូកទី ៥ (របកគំហើញ)** បង្ហាញស៊ីជម្រៅអំពីរបកគំហើញដែលបានពីការចុះសិក្សាស្រាវជ្រាវ ក្នុងការរៀបចំរបាយការណ៍នេះ។

**ជំពូកទី ៦ (សេចក្តីសន្និដ្ឋាន និងអនុសាសន៍)** សង្ខេបពីរបកគំហើញសំខាន់ៗមួយចំនួនដែលទទួលបានពីការស្រាវជ្រាវនេះ និងប្រើប្រាស់របកគំហើញទាំងនេះដើម្បីផ្តល់អនុសាសន៍សមស្របដល់អ្នកពាក់ព័ន្ធផ្សេងៗក្នុងគោលបំណងទប់ស្កាត់ការសម្លុត ពាក់ព័ន្ធនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រនៅតាមសាលារៀនក្នុងប្រទេសកម្ពុជាដែលផ្តល់នូវបរិយាកាសអប់រំប្រកបដោយសុវត្ថិភាពសម្រាប់យុវជនដែលស្រឡាញ់ភេទដូចគ្នា និងធ្វើការដោះស្រាយបញ្ហានៃការរើសអើងផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រជាទូទៅដើម្បីជម្រុញឱ្យប្រជាជនកម្ពុជាដែលជាអ្នកស្រឡាញ់ភេទដូចគ្នាទាំងអស់អាចសម្រេចនូវសក្តានុពលពិតប្រាកដរបស់ពួកគេ។

# ១. សេចក្តីផ្តើម

បើតាមនិយមន័យ សមាជិកសង្គមដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ទទួលបានការធានាសិទ្ធិដូចគ្នាទៅនឹងមនុស្សគ្រប់គ្នាផ្សេងទៀតផងដែរ។ ប៉ុន្តែនៅក្នុងប្រទេសកម្ពុជា ខណៈពេលដែលពុំមានប្រពៃណីសាសនារើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នាក្នុងពេលជាមួយគ្នាក៏ពុំមានច្បាប់ឬបទដ្ឋានជាក់លាក់ណាមួយក្នុងការការពារដល់អ្នកស្រឡាញ់ភេទដូចគ្នានោះដែរ ហើយឥរិយាបថសង្គមនៅតែមានលក្ខណៈអវិជ្ជមានចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។ គុណតម្លៃឬសម្ពាធគ្រួសារនៅតែមានកម្រិតខ្លាំងក្នុងសង្គមកម្ពុជា ហើយមនុស្សវ័យក្មេងទទួលរងសម្ពាធខ្លាំង ឱ្យរៀបការតាមបែបប្រពៃណីនិងមានកូន។

ការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នា ដោយសារតែពួកគេ "ខុសពីគេ" អាចចាប់ផ្តើមពីវ័យក្មេងទៅ និងមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសុខភាព និងសុខុមាលភាពខាងអារម្មណ៍ ផ្លូវចិត្តនិងផ្លូវកាយរបស់បុគ្គលម្នាក់ៗ។

ការស្រាវជ្រាវនេះធ្វើឡើងនៅពេលដែលមានការផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនឡើងទៅលើសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងសកលលោកទាំងមូល និងក្នុងប្រទេស។ កាលពីពេលថ្មីៗនេះ ទីភ្នាក់ងារសហប្រជាជាតិចំនួន ១២ បានរួមគ្នាចេញសេចក្តីថ្លែងការណ៍ដែលមិនធ្លាប់មានកន្លងមកដោយជំរុញឱ្យរដ្ឋទាំងអស់គោរពសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា និងបញ្ចប់អំពើហិង្សា និងការរើសអើងផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ[1]។

នៅថ្នាក់តំបន់ មានសញ្ញាបង្ហាញយ៉ាងច្បាស់ពីការលើកតម្កើងសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា។ នៅក្នុងប្រទេសថៃ និងប្រទេសវៀតណាមមានសញ្ញាបង្ហាញថាសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាចាប់ផ្តើមទទួលបានការយកចិត្តទុកដាក់ក្នុងការពិភាក្សានយោបាយទូទៅ។ របាយការណ៍នេះនឹងបង្ហាញពីការអភិវឌ្ឍមួយចំនួនក្នុងចំណោមការអភិវឌ្ឍទាំងនេះក្នុងជំពូកទី ៤ ។ អ្វីដែលគួរឱ្យកត់សម្គាល់ជាពិសេស គឺការអនុម័តលើរដ្ឋធម្មនុញ្ញថ្មីរបស់ប្រទេសនេប៉ាល់កាលពីពេលថ្មីៗនេះ ដែលមានដាក់បញ្ចូលវិធានការជាក់លាក់ប្រឆាំងនឹងការរើសអើង ដែលហាមឃាត់ក្នុងការរើសអើងប្រឆាំងនឹងអ្នកស្រឡាញ់ភេទដូចគ្នា[2] ។ តាមរយៈការធ្វើបែបនេះ ប្រទេសនេប៉ាល់ក្លាយជាប្រទេសដំបូងគេនៅអាស៊ីដែលផ្តល់ការធានាតាមរដ្ឋធម្មនុញ្ញលើវិធានការប្រឆាំងនឹងការរើសអើងបែបនេះ។

---

[1] សេចក្តីប្រកាសរបស់សហប្រជាជាតិ "ទីភ្នាក់ងារសហប្រជាជាតិអំពាវនាវឱ្យរដ្ឋចាត់វិធានការជាបន្ទាន់ ដើម្បីបញ្ចប់អំពើហិង្សា និងការរើសអើងប្រឆាំងមនុស្សពេញវ័យ ក្មេងជំទង់ និងកុមារ ដែលជាអ្នកស្រឡាញ់ភេទដូចគ្នា" (២៩ កញ្ញា ២០១៥)។

[2] "រដ្ឋធម្មនុញ្ញរបស់ប្រទេសនេប៉ាល់នាំមុខគេក្នុងតំបន់ខាងសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា" *សារព័ត៌មាន The World Post* (១០ តុលា ២០១៥) <http://www.huffingtonpost.com/tracy-fehr/nepal-constitution-lgbti-rights_b_8239360.html>

ដោយឡែកក្នុងប្រទេស បន្ទាប់ពីមានការដាក់សម្ពាធពីអង្គការសង្គមស៊ីវិល ព្រឹត្តិការណ៍ក្នុងប្រទេសនេប៉ាល់បានជំរុញឱ្យមានការស្វាគមន៍ពីរាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងលទ្ធភាពផ្តល់ភាពស្របច្បាប់ដល់ការរៀបអាពាហ៍ពិពាហ៍របស់អ្នកស្រឡាញ់ភេទដូចគ្នា។[3] លើសពីនេះ កាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានចូលរួមជាមួយនឹងសង្គមស៊ីវិល ដើម្បីឱ្យការបណ្តុះបណ្តាលគ្រូ និងកម្មវិធីសិក្សាតាមសាលារៀន កាន់តែគិតគូរពីបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា។ ការរីកចម្រើនដែលបានពីការសហការគ្នារវាងសង្គមស៊ីវិល និងរាជរដ្ឋាភិបាលកម្ពុជានេះ គឺជាសញ្ញាដ៏ល្អមួយ ដែលបង្ហាញពីការរីកចម្រើនជាបណ្តើរៗនៃសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលបង្ហាញក្នុងរបាយការណ៍នេះ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ប្រសិនបើគេចង់ឱ្យមានការធានាសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាទាំងខាងច្បាប់និងឥរិយាបថសង្គម។ ជារឿយៗ ឧបសគ្គដែលពិបាកជាងគេសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នាមិនមែនក្របខ័ណ្ឌច្បាប់នោះទេ ប៉ុន្តែការធ្វើមិនល្អទៅលើពួកគេក្នុងសង្គមហើយការសម្លុតតាមសាលារៀនដោយសារតែនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ គឺជាឧទាហរណ៍បង្ហាញពីការប្រតិបត្តិជាអវិជ្ជមានដែលមានផលប៉ះពាល់យ៉ាងធំធេងទៅលើជីវិតរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា។

ក្នុងសកលលោកទាំងមូល ការសិក្សានានាបង្ហាញថាបញ្ហា នៃការសម្លុតដោយសារតែការស្អប់អ្នកស្រឡាញ់ភេទដូចគ្នាកាន់តែមានការរាលដាលខ្លាំងទៅៗនៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប៉ុន្តែ នៅកម្ពុជាពុំទាន់មានការស្រាវជ្រាវអំពីប្រធានបទនេះនៅឡើយទេ។ នៅក្នុងឆ្នាំ ២០១៤-២០១៥ គម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័ររបស់ ម.ស.ម.ក បាននិងកំពុងធ្វើការងារដើម្បីបំពេញចំណុចខ្វះខាតនេះ។ គម្រោងនេះបានធ្វើការស្រាវជ្រាវលើឯកសារពាក់ព័ន្ធជាច្រើន ការចុះអង្កេត ការសម្ភាស និងការពិភាក្សាក្រុមក្នុងគោលបំណងធ្វើការវាយតម្លៃ និងវិភាគលើកម្រិតនិងផលប៉ះពាល់នៃការសម្លុតផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រនៅតាមសាលារៀនក្នុងប្រទេសកម្ពុជា។

**ខណៈពេលដែលការសម្លុតត្រូវបានមនុស្សមួយចំនួន ចាត់ទុកថាជាផ្នែកមួយដែលមិនអាចចៀសរួចរបស់ក្មេងជំទង់** ក្រុមមួយចំនួនក្លាយជាគោលដៅនៃការសម្លុតយ៉ាងច្រើនលើសលុបដូច្នេះពួកគេត្រូវការការការពារជាពិសេស។ បើតាម*របាយការណ៍ស្តីពីអំពើហិង្សាលើកុមារក្នុងពិភពលោក* របស់សហប្រជាជាតិ ការសម្លុតគម្រាមភាគច្រើនគឺពាក់ព័ន្ធនឹងភេទឬយេនឌ័រ ទាំងក្នុងការជ្រើសរើសជនរងគ្រោះផង និងទាំងក្នុងលក្ខណៈនៃការរំលោភបំពានផង[4]។ ចំណុចនេះពាក់ព័ន្ធ

---

[3]"ប្រទេសកម្ពុជាស្វាគមន៍អាពាហ៍ពិពាហ៍របស់អ្នកស្រឡាញ់ភេទដូចគ្នា បើតាមការលើកឡើងរបស់អ្នកនាំពាក្យរដ្ឋាភិបាល" សារព័ត៌មាន *Khmer Times* (២៤ កញ្ញា ២០១៥) <http://www.khmertimeskh.com/news/16143/cambodia-welcomes-same-sex-marriage--gov---t-spokesman-says/>

[4] សហប្រជាជាតិ "របាយការណ៍ពិភពលោកស្តីពីអំពើហិង្សាលើកុមារ" (របាយការណ៍) (ឆ្នាំ ២០០៦) <http://www.unicef.org/violencestudy/reports.html>

ខ្លាំងជាមួយនឹងយុវជនជាអ្នកស្រឡាញ់ភេទដូចគ្នាដែលចាប់ផ្តើមដឹងពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័ររបស់ខ្លួនក្នុងវ័យជំទង់។

អត្រាខ្ពស់នៃការសម្លុតចំពោះសិស្សជាអ្នកស្រឡាញ់ភេទដូចគ្នាដោយសារតែនិន្នាការភេទឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេត្រូវបានចងក្រងទុកជាឯកសារត្រឹមត្រូវនៅគ្រប់ទិសទីក្នុងពិភពលោក។

ក្នុងកម្រិតមួយលើសលុប ការសិក្សានានាបានបង្ហាញពីទំនាក់ទំនងរវាងការសម្លុតនិងបញ្ហាជំងឺផ្លូវចិត្តដែលកើតមានឡើងនៅក្នុងជីវិតនៅពេលក្រោយ ដែលមួយផ្នែកដោយសារតែអ្នកស្រឡាញ់ភេទដូចគ្នាទទួលរងការសម្លុតតាមសាលារៀនក្នុងអត្រាមួយខ្ពស់គួរឱ្យកត់សម្គាល់ ជាងមិត្តភក្តិរបស់ពួកគេដែលមិនមែនជាអ្នកស្រឡាញ់ភេទដូចគ្នា។ ការស្រាវជ្រាវដែលធ្វើឡើងដោយគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ របស់ ម.ស.ម.ក គាំទ្រដល់ទ្រឹស្តីនេះ។

របាយការណ៍នេះបង្ហាញពីបរិបទជារួមនៃជីវិតរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាតាមរយៈការពិនិត្យលើទិដ្ឋភាពច្បាប់ពាក់ព័ន្ធនឹងសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា និងសម្ពាធសង្គមដែលអ្នកស្រឡាញ់ភេទដូចគ្នាត្រូវទទួលរង។ បន្ទាប់មក របាយការណ៍នេះបង្ហាញលំអិតពីរបកគំហើញ ពាក់ព័ន្ធនឹងការស្រាវជ្រាវលើឯកសារពាក់ព័ន្ធដែលបង្ហាញពីព័ត៌មានដ៏មានប្រយោជន៍សម្រាប់ជាមូលដ្ឋានចំណេះដឹងថ្មីបំផុត ពាក់ព័ន្ធនឹងការសម្លុតផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រពីគ្រប់ទិសទីក្នុងពិភពលោក ក៏ដូចជាទិន្នន័យប្រមូលផ្ទាល់ ដែលបានពីការចុះប្រមូលនៅមូលដ្ឋានរបស់គម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ។ តាមរយៈការស្រាវជ្រាវប្រមូលព័ត៌មានបែបនេះ របាយការណ៍នេះគឺជាជំហានសំខាន់ដំបូង នៃការប្រមូលទិន្នន័យអំពីបទពិសោធន៍របស់អ្នកស្រឡាញ់ភេទដូចគ្នាតាមសាលារៀនរបស់ប្រទេសកម្ពុជាដែលគេអាចប្រើប្រាស់សម្រាប់ទាញសេចក្តីសន្និដ្ឋាន និងលើកស្នើនូវអនុសាសន៍សមស្របសម្រាប់អ្នកធ្វើសេចក្តីសម្រេចចិត្ត និងអ្នកពាក់ព័ន្ធនានា។ យើងខ្ញុំសង្ឃឹមថា ការស្រាវជ្រាវនេះនឹងជម្រុញក៏ដូចជាលើកទឹកចិត្តឱ្យមានការស្រាវជ្រាវបន្ថែមទៀតលើបញ្ហាដ៏សំខាន់នេះ។

# ២. គោលបំណង វិសាលភាព និងវិធីសាស្ត្រ

របាយការណ៍នេះរៀបចំឡើង បន្ទាប់ពីគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័ររបស់ ម.ស.ម.ក បានចេញផ្សាយរបាយការណ៍ចំនួនពីរដងកន្លងមកហើយ រួមមានរបាយការណ៍ឆ្នាំ ២០១០ ដែលបង្ហាញជារួមពីទស្សនៈយល់ឃើញលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រក្នុងប្រទេសកម្ពុជាដែលមានចំណងជើងថា *"ការចេញមុខជាចំហានៅក្នុងព្រះរាជាណាចក្រកម្ពុជា ៖ ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ ក្នុងប្រទេសកម្ពុជា ("របាយការណ៍ឆ្នាំ ២០១០")*[5] និងរបាយការណ៍ឆ្នាំ ២០១២ ដែលបង្ហាញបន្ថែមទៀតអំពីការលំបាកដែលអ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះ និងផ្តោតលើការកំណត់នូវចក្ខុវិស័យមួយដែលសិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នាទទួលបានការការពារពេញលេញដោយច្បាប់ ទទួលបានការគោរពក្នុងការអនុវត្តជាក់ស្តែងនិងទទួលស្គាល់ជាសកលដែលមានចំណងជើងថា *"ឥន្ទធនូខ្មែរ ៖ ប្រែការរើសអើង ទៅជាមោទនភាព* ("របាយការណ៍ឆ្នាំ ២០១២")[6]។ របាយការណ៍នេះខុសពីរបាយការណ៍ឆ្នាំ២០១០ និងរបាយការណ៍ឆ្នាំ២០១២ នៅត្រង់ថារបាយការណ៍នេះមានបំណងផ្តល់ទិន្នន័យដើមទាក់ទិននឹងបទពិសោធន៍របស់យុវជនជាអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសកម្ពុជា និងជាពិសេសបង្ហាញពីប្រេវ៉ាឡង់នៃការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ ។ ដូច្នេះ វិសាលភាពនៃរបាយការណ៍នេះមានទំហំតូច មិនដូចរបាយការណ៍ដែលចេញផ្សាយពីមុននោះទេ ។ នៅក្នុងដំណាក់កាលពិគ្រោះយោបល់មុនពេលចាប់ផ្តើមរៀបចំរបាយការណ៍នេះឡើង គម្រោងហាក់បីដូចជាមិនសូវជាមានទិន្នន័យពាក់ព័ន្ធនឹងបទពិសោធន៍របស់យុវជនដែលជាអ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា។ តែតាមពិត ការស្វែងយល់ពីសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានិងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ ក្នុងប្រទេសកម្ពុជាទាំងមូល ទើបតែនៅដំណាក់កាលចាប់ផ្តើមដំបូងដែលធ្វើឱ្យបញ្ហានេះក្លាយជាបញ្ហាដែលមានសក្តានុពលសម្រាប់ការស្រាវជ្រាវ។ យើងសង្ឃឹមថា តាមរយៈបោះពុម្ពផ្សាយរបាយការណ៍នេះ វានឹងក្លាយជាមូលដ្ឋានសម្រាប់ជំរុញឱ្យមានការស្រាវជ្រាវបន្ថែមទៀតអំពីបញ្ហានេះ។

ទន្ទឹមនឹងការប្រមូលទិន្នន័យដើមអំពីការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រតាមសាលារៀនក្នុងប្រទេសកម្ពុជា គម្រោងយល់ថាការ

---

[5] ម.ស.ម.ក "ការចេញជាចំហាក្នុងព្រះរាជាណាចក្រ៖ បុរសស្រឡាញ់ប្រុស ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទក្នុងប្រទេសកម្ពុជា" (របាយការណ៍) (ខែ ធ្នូ ឆ្នាំ ២០១០)
<http://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=8&id=3>

[6] ម.ស.ម.ក "ឥន្ទធនូខ្មែរ៖ កែប្រែការរើសអើងទៅជាមោទនភាព" (របាយការណ៍) (ខែ ធ្នូ ឆ្នាំ ២០១២)
<http://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=85&id=3>

ប្រមូលទិន្នន័យពីការសិក្សាប្រហាក់ប្រហែលគ្នាដែលបានពីប្រទេសនានាជុំវិញពិភពលោកក៏ជាការសំខាន់ផងដែរ។ គោលបំណងនៃការធ្វើបែបនេះគឺដើម្បីធ្វើការវិភាគថាតើបទពិសោធន៍របស់យុវជនជាអ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាមានលក្ខណៈយ៉ាងណា បើធៀបជាមួយនឹងអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសផ្សេងទៀតនិងថាតើគេអាចកំណត់ដឹងពីនិន្នាការជាក់លាក់ដែរឬទេ។ ឧទាហរណ៍ ប្រសិនបើរបកគំហើញរបស់យើង មានលក្ខណៈខុសគ្នាពីទិន្នន័យក្នុងការសិក្សាផ្សេងទៀត អាចកើតឡើងដោយសារកត្តាវប្បធម៌ជាក់លាក់ ដែលអាចមានលក្ខណៈពិសេសសម្រាប់ប្រទេសកម្ពុជាឬតំបន់អាស៊ីប៉ាស៊ីហ្វិចទាំងមូល។ ប្រសិនបើទិន្នន័យនេះមានលក្ខណៈខុសប្លែកដោយសារតែកត្តាវប្បធម៌ គម្រោងស្នើអោយមានការយកចិត្តទុកដាក់បន្ថែមទៀតទៅលើកិច្ចការងារតស៊ូមតិ និងការផ្តល់អនុសាសន៍ក្នុងគោលបំណងធ្វើឱ្យកាន់តែប្រសើរនូវសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា។

របាយការណ៍នេះមានគោលបំណងបង្ហាញពីទិន្នន័យដែលប្រមូលដោយគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រសម្រាប់ការស្រាវជ្រាវអំពីស្ថានភាពបច្ចុប្បន្នពាក់ព័ន្ធនឹងការសម្លុតផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រតាមសាលារៀនក្នុងប្រទេសកម្ពុជា។ គម្រោងនេះសង្ឃឹមថារបាយការណ៍នេះនឹងក្លាយជាការរួមចំណែកយ៉ាងសំខាន់ដើម្បីផ្តល់ការយល់ដឹងអំពីបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាជាទូទៅក៏ដូចជាប្រភពព័ត៌មានដ៏សំខាន់អាចយកទៅប្រើប្រាស់បានសម្រាប់រាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត ក្នុងប្រទេសកម្ពុជា។

ដើម្បីទទួលបានព័ត៌មានអំពីប្រេវ៉ាឡង់នៃការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នា តាមសាលារៀនក្នុងប្រទេសកម្ពុជា ការស្រាវជ្រាវលើឯកសារពាក់ព័ន្ធជាច្រើនត្រូវបានធ្វើឡើង ក៏ដូចជាមានការចុះស្រាវជ្រាវផ្ទាល់ក្នុងទម្រង់ជា ការអង្កេត (ចុះទៅមូលដ្ឋានផ្ទាល់ និងធ្វើតាមអនឡាញ) ការសម្ភាស និងការពិភាក្សាក្រុម។

ការស្រាវជ្រាវលើឯកសារពាក់ព័ន្ធទាំងឯកសារភាសាខ្មែរ ទាំងអង់គ្លេស ត្រូវបានធ្វើឡើងដោយក្រុមការងារគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ។ ការស្រាវជ្រាវលើឯកសារពាក់ព័ន្ធនេះពិនិត្យលើការស្រាវជ្រាវដែលមានកន្លងមកអំពីការសម្លុតនៅសាលារៀន ការសម្លុតផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រនៅតាមសាលារៀន និងផលប៉ះពាល់រយៈពេលវែងនៃការសម្លុតបែបនេះ។ ការស្រាវជ្រាវនេះធ្វើឡើងលើឯកសារពាក់ព័ន្ធនឹងប្រទេសកម្ពុជា អាស៊ីអាគ្នេយ៍ និងប្រទេសផ្សេងទៀតក្នុងពិភពលោក។

សម្រាប់ការចុះស្រាវជ្រាវដល់មូលដ្ឋាន គម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រនេះប្រើប្រាស់បណ្តាញដែលមានស្រាប់របស់ខ្លួនដើម្បីស្វែងរកអ្នកចូលរួមដែលយល់ព្រមបំពេញទម្រង់អង្កេត ផ្តល់ការសម្ភាសនិងចូលរួមក្នុងការពិភាក្សាក្រុម។ ការងារនេះធ្វើទៅបានតាមរយៈការទាក់

ទងទៅកាន់អ្នកដឹកនាំសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានិង "សម្ព័ន្ធមិត្ត" របស់អ្នកដឹកនាំសហគមន៍អ្នកស្រឡាញ់ទាំងពីរភេទ ឬអ្នកដែលស្ថិតក្នុងស្ថានភាពស្រដៀងគ្នា ដែលស្គាល់ពីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាតាមមូលដ្ឋានដែលជួយគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រក្នុងការស្វែងរកអ្នកចូលរួមដែលយល់ព្រមចូលរួមក្នុងការស្រាវជ្រាវនេះ។ ការចុះស្រាវជ្រាវដល់មូលដ្ឋាននេះត្រូវបានធ្វើឡើងតែជាមួយនឹងមនុស្សដែលកំណត់អត្តសញ្ញាណថាជាអ្នកស្រឡាញ់ភេទដូចគ្នាប៉ុណ្ណោះ។ ពុំមានក្រុមសម្រាប់ត្រួតពិនិត្យឡើយ។ អ្នកចូលរួមមានអាយុចន្លោះពី ១៥ និង ៧២ ឆ្នាំ មានន័យថា ពួកគេកំពុងជាសិស្សនៅតាមសាលារៀនមធ្យមសិក្សា ឬសកលវិទ្យាល័យ និងជាអ្នកដែលធ្លាប់ទទួលបានការអប់រំនៅពេលណាមួយកន្លងមក។ គម្រោងនេះមានបំណងកំណត់ចំនួនអ្នកចូលរួមដែលបានចាកចេញពីប្រព័ន្ធអប់រំរួចទៅហើយ ដើម្បីវាយតម្លៃលើផលប៉ះពាល់រយៈពេលវែងនៃការសម្លុតផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រតាមសាលារៀន។

ការអង្កេតនេះគឺជាផ្នែកមួយដ៏សំខាន់នៃដំណើរការស្រាវជ្រាវសម្រាប់របាយការណ៍នេះ។ គម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័របានចុះទៅមូលដ្ឋាន ៣ លើកផ្សេងគ្នា ទៅលើខេត្តចំនួន ១១ ដូចជា ខេត្តមណ្ឌលគិរី ស្ទឹងត្រែង សៀមរាប បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កោះកុង កំពង់សោម កំពត តាកែវ និងរាជធានីភ្នំពេញ។

ទម្រង់អង្កេតត្រូវបានតាក់តែងឡើងក្នុងឆ្នាំ ២០១៤ ដើម្បីកំណត់ពីប្រេវ៉ាឡង់នៃការសម្លុតកើតមានលើអ្នកស្រឡាញ់ភេទដូចគ្នាតាមសាលារៀន ហើយត្រូវបានប្រើប្រាស់សម្រាប់ការចុះប្រមូលព័ត៌មានជុំដំបូង។ ការអង្កេតដំបូងគ្របដណ្តប់លើអ្នកស្រឡាញ់ភេទដូចគ្នាចំនួន ១១៩ នាក់ អាយុពី ១៦ ដល់ ៦៥ ឆ្នាំ។ ខណៈពេលដែលមានស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស និងអ្នកស្រឡាញ់ភេទទាំងពីរចូលរួមក្នុងការអង្កេតនេះ អ្នកចូលរួមភាគច្រើនគឺជាស្រីស្រស់ ("អ្នកប្តូរភេទប្រុសទៅស្រី") ហើយអ្នកចូលរួមជាច្រើននាក់ ជាអ្នកមកពីខេត្តសៀមរាប។ ក្នុងទំរង់ការអង្កេតនេះមានបែងចែកតាមផ្នែករួមមានផ្នែកទី១ មានសំណួរទូទៅទាក់ទិននឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ។ ផ្នែកទី ២ សំណួរអំពីបទពិសោធន៍របស់ពួកគេនៅសាលារៀន និងផ្នែកទី ៣ ផ្តោតលើជីវិតបច្ចុប្បន្ននិងការយល់ឃើញរបស់ពួកគេក្នុងនាមជាអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ក៏ដូចជាផលប៉ះពាល់រយៈពេលវែងនៃការសម្លុតផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ ។

សំណួរដែលមានក្នុងទំរង់អង្កេតនេះត្រូវបានរៀបចំឡើងដើម្បីប្រមូលព័ត៌មាន ជាពិសេសពាក់ព័ន្ធនឹងប្រធានបទធំៗចំនួន ៤ រួមមាន ប្រេវ៉ាឡង់នៃការសម្លុតផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រតាមសាលារៀនក្នុងប្រទេសកម្ពុជា ទម្រង់នៃការសម្លុតនិងប្រភពដែលបង្កការសម្លុតនេះ (ដូចជាសិស្សផ្សេងទៀត គ្រូ)។ល។ ការឆ្លើយតបចំពោះ

ការសម្លុត(ការឆ្លើយតបរបស់អ្នកដែលត្រូវបានគេសម្លុតផង និងការឆ្លើយតបរបស់សាលារៀនផង) និងផលប៉ះពាល់រយៈពេលវែងនៃការសម្លុត។ នេះគឺជាវិធីសាស្រ្តស្រដៀងគ្នាដែលធ្វើឡើងក្នុងការសិក្សានានាពីប្រទេសផ្សេងទៀត ដែលត្រូវបានស្រង់មកបង្ហាញក្នុងរបាយការណ៍នេះ ដើម្បីផ្តល់ភាពងាយស្រួលឱ្យមានការប្រៀបធៀបលទ្ធផល និងកំណត់និន្នាការរវាងទិន្នន័យទាំងនេះ។

ក្រោយពីបានវិភាគលើទិន្នន័យដែលប្រមូលបានក្នុងពេលចុះប្រមូលទិន្នន័យដំណាក់កាលទី ១ ក្រុមការងាររបស់គម្រោងបានរកឃើញចំណុចមួយចំនួនដែលត្រូវកែលំអ។ ការលំបាករួមមួយនៅក្នុងការអង្កេតដំបូងគឺថាសំណួរមួយចំនួនធ្វើការសន្មត់ថាការសម្លុតដែលទទួលរងដោយអ្នកស្រឡាញ់ភេទដូចគ្នា កើតឡើងដោយសារតែនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់ពួកគេ។ ប៉ុន្តែ ដោយសារតែការប្រើពាក្យមិនសូវច្បាស់លាស់ក្នុងសំណួរទាំងនេះ លទ្ធផលដែលបានពីសំណួរមួយចំនួនក៏មានលក្ខណៈមិនប្រាកដឡើយ។ មានមូលហេតុជាច្រើន ដែលនាំឱ្យមនុស្សម្នាក់ក្លាយជាមុខសញ្ញានៃការសម្លុត ហើយនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ គ្រាន់តែជាមូលហេតុមួយប៉ុណ្ណោះ។ ទោះបីជាទិន្នន័យដែលត្រូវបានប្រមូលក្នុងដំណាក់កាលទី ១ នេះនៅមានចន្លោះប្រហោង តែវាជាមូលដ្ឋានគ្រឹះក្នុងការកែលំអរសម្រាប់ការចុះស្រាវជ្រាវក្នុងគោលដៅដំណាក់កាលផ្សេងទៀត។

ក្រោយពីមានបទពិសោធន៍បែបនេះ ក្រុមការងារគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័របានកែលំអរទម្រង់អង្កេតមួយចំនួន។ គួរឱ្យសោកស្តាយ ទិន្នន័យមួយចំនួនដែលប្រមូលបានក្នុងកំឡុងពេលចុះធ្វើការអង្កេតដំបូង មិនអាចយកមកបញ្ចូលជាមួយនឹងទិន្នន័យដែលប្រមូលបានក្នុងពេលចុះប្រមូលដំណាក់កាលទី ២។ នៅក្នុងផ្នែក "របកគំហើញ" នៃរបាយការណ៍នេះមានការបញ្ជាក់យ៉ាងច្បាស់អំពីលទ្ធផលណាដែលជាលទ្ធផលមកពីការអង្កេតមួយ ឬការអង្កេតទាំងពីរបញ្ចូលគ្នា។

ការផ្លាស់ប្តូរភាគច្រើននៃទម្រង់អង្កេតភាគច្រើននៅក្នុងផ្នែកទី ២។ នៅក្នុងទម្រង់អង្កេតដែលត្រូវបានកែសម្រួលឡើងវិញ មានតែអ្នកចូលរួមដែលឆ្លើយថា "បាទ/ចាស" ប៉ុណ្ណោះ ចំពោះសំណួរដែលសួរថាតើពួកគេធ្លាប់ទទួលរងការសម្លុតនៅសាលារៀនដែរឬទេ ដែលត្រូវបានស្នើឱ្យអ្នកចូលរួមឆ្លើយសំណួរអំពីការសម្លុតជាបន្តបន្ទាប់។ សំណួរទាំងនេះមានគោលបំណងពន្យល់ឱ្យបានកាន់តែច្បាស់បន្ថែមទៀតអំពីការសម្លុត ជាពិសេសមូលហេតុដែលនាំឱ្យមានការសម្លុត (ថាតើពាក់ព័ន្ធជាមួយនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រឬអត់) ប្រេវ៉ាឡង់និងទម្រង់នៃការសម្លុតក៏ដូចជាអ្នកដែលប្រព្រឹត្តអំពើសម្លុតនេះ។ សំណួរអំពីការសម្លុតក៏ត្រូវបានកែសម្រួលផងដែរ នៅត្រង់កន្លែងដែលមិនច្បាស់ដើម្បីបង្កើនសុក្រឹតភាពនៃចម្លើយរបស់អ្នកចូលរួម។

ក្រោយពីបានកែសម្រួលការអង្កេតនេះរួច ការចុះប្រមូលព័ត៌មាននៅដំណាក់កាលទី ២ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី ១៥ ដល់ ២១ ខែមីនា ឆ្នាំ២០១៥ ក្នុងខេត្តកោះកុង កំពង់សោម កំពត និង តាកែវ ហើយជាការបន្តពីការចុះប្រមូលព័ត៌មានលើកទី ១ ដែលក្រុមការងារគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័របានចុះទៅខេត្តភាគខាងជើងដូចជាខេត្តមណ្ឌលគិរី ស្ទឹងត្រែង សៀមរាប បន្ទាយមានជ័យ បាត់ដំបង និងកំពង់ឆ្នាំង។ ការចុះស្រាវជ្រាវនេះរួមមានការសម្ភាស ការពិភាក្សាក្រុម និងការសម្ភាសជាលក្ខណៈបុគ្គលបែបអនាមិក ដើម្បីប្រមូលទិន្នន័យអំពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ។ លទ្ធផលដែលបានពីការចុះប្រមូលព័ត៌មានជាលើកទី ២ នេះត្រូវបានដាក់បញ្ចូលជាមួយនឹងលទ្ធផលដែលទទួលបានពីអ្នកចូលរួមចំនួន ៣៣ នាក់នៅរាជធានីភ្នំពេញ ដែលទទួលបានក្នុងពេលចុះប្រមូលព័ត៌មានជាលើកទី ១។ មូលហេតុដែលនាំឱ្យមានការដាក់បញ្ចូលលទ្ធផលពីទីក្រុងភ្នំពេញ ដែលបានពីការចុះប្រមូលព័ត៌មានលើកទី ២ គឺថាលទ្ធផលទាំងនេះត្រូវបានប្រមូល ក្រោយពីមានការផ្លាស់ប្តូរចំពោះការអង្កេតនេះ ដូច្នេះវាមានការងាយស្រួលក្នុងការប្រៀបធៀបជាមួយនឹងទិន្នន័យ ដែលបានពីការចុះប្រមូលព័ត៌មានលើកទី ២។ លទ្ធផលទាំងនេះគ្របដណ្តប់លើអ្នកចូលរួមចំនួន ១២៦ នាក់ ដែលមានអាយុចាប់ពី ១៥ ដល់ ៧២ ឆ្នាំ។

**ចំនួនសរុប និងអាយុរបស់អ្នកឆ្លើយនិងសំណួរ**មានចំនួន ២៤៥ នាក់ (១១៩ នាក់ ក្នុងការអង្កេតទី ១ និង ១២៦ នាក់ ក្នុងការអង្កេតទី ២)។ សរុប មានអ្នកចូលរួម ១៧០ នាក់ អាយុពី ១៥-២៩ ឆ្នាំ (៦៩%) ៦០ នាក់អាយុពី ៣០-៤៤ ឆ្នាំ (២៤%) ១៣ នាក់ អាយុ ៤៥-៥៩ ឆ្នាំ (៥%) និង ២ នាក់ អាយុ ៦០-៧២ ឆ្នាំ (១%)។ របាយអាយុរបស់អ្នកចូលរួមត្រូវបានបង្ហាញក្នុងតារាងដូចខាងក្រោម ៖



## ដែនកំណត់

ការអង្កេតនេះផ្តល់នូវលទ្ធផលគួរឱ្យចាប់អារម្មណ៍ខ្លាំង និងបង្ហាញថា គេចាំបាច់ត្រូវស្វែងយល់ពីប្រធានបទដ៏សំខាន់នេះបន្ថែមទៀត។ លទ្ធភាពអនុវត្ត (រួមមានពេលវេលានិងថវិកាមានកំណត់) ជាឧបសគ្គសម្រាប់គម្រោងនេះមិនឱ្យធ្វើការអង្កេតបានទូលំទូលាយជាងនេះឡើយ។ ការអង្កេតលើក្រុមសម្រាប់ផ្ទៀងផ្ទាត់ពោលគឺក្រុមមនុស្សដែលមិនមែនជាអ្នកស្រឡាញ់ភេទដូចគ្នា ក៏ជាការមានប្រយោជន៍ផងដែរដើម្បីប្រៀបធៀបបទពិសោធន៍របស់ពួកគេជាមួយអ្នកស្រឡាញ់ភេទដូចគ្នា។

មានដែនកំណត់មួយចំនួន នៅក្នុងការចុះស្រាវជ្រាវប្រមូលព័ត៌មាន។ បណ្តាញដែលមានស្រាប់បច្ចុប្បន្ននៅក្នុងខេត្តកំពតនិងខេត្តតាកែវគឺនៅថ្មី ហើយមិនសូវមានបទពិសោធន៍ច្រើនដូចបណ្តាញក្នុងខេត្តផ្សេងទៀតឡើយ។ អ្នកទំនាក់ទំនងនៅមូលដ្ឋានបច្ចុប្បន្ននៅខ្វះសមត្ថភាពធ្វើការចរចាប្រកបដោយប្រសិទ្ធភាព ជាមួយនឹងក្រុមគោលដៅ ជាពិសេស ស្ត្រីស្រឡាញ់ស្ត្រី។ លើសពីនេះ ពេលខ្លះមានការលំបាកក្នុងការរៀបចំការសម្ភាសជាមួយអ្នកចូលរួម ហើយអ្នកចូលរួមជាច្រើននាក់ ពេលខ្លះមានអារម្មណ៍ខ្មាស អៀន ឬស្ទាក់ស្ទើរក្នុងការបង្ហាញអត្តសញ្ញាណរបស់ពួកគេនៅទីសាធារណៈ ជាពិសេសក្នុងខេត្តតាកែវ និងខេត្តកំពត។ ការអង្កេតនេះក៏មានដាក់បញ្ចូលអ្នកដែលគេស្គាល់ថាជាអ្នកស្រឡាញ់ភេទដូចគ្នា ហើយជាមនុស្សដែលអ្នកដឹកនាំសហគមន៍ស្គាល់ផងដែរ។ ដូច្នេះ ទំនងជាមានអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់ ដែលអ្នកដឹកនាំសហគមន៍មិនស្គាល់ ហើយដែលការស្រាវជ្រាវនេះមិនបានគ្របដណ្តប់ដល់។

លើសពីនេះ គេអាចដឹងព័ត៌មានជាច្រើន តាមរយៈការសម្ភាសគ្រូ នាយកសាលា បុគ្គលិកសាលារៀន និងមាតាបិតា ឬសមាជិកគ្រួសារផ្សេងទៀត ដើម្បីពិនិត្យមើលផលប៉ះពាល់ធំៗនៃការសម្លុត និងយុទ្ធសាស្ត្រដែលមាន ដើម្បីដោះស្រាយបញ្ហានេះ។

ដែនកំណត់មួយទៀត គឺវិសាលភាពនៃការអង្កេតនេះតែម្តង។ ដូចគ្នានឹងការអង្កេតអ្វីក៏ដោយ តែងតែមានដែនកំណត់នៃបរិមាណសំណួរ ដែលគេអាចដាក់បញ្ចូលបាន។ អ្វីដែលមិនអាចចៀសរួច ដែនកំណត់បែបនេះនាំឱ្យគេមិនសូវជាអាចស្វែងយល់ពីបទពិសោធន៍មួយចំនួនរបស់អ្នកឆ្លើយសំណួរ បើធៀបជាមួយនឹងបទពិសោធន៍មួយចំនួនទៀត។ នៅក្នុងការអង្កេតរបស់យើង សំណួរជាច្រើនផ្តោតលើប្រេវ៉ាឡង់នៃការសម្លុតនៅសាលារៀនផង និងផលប៉ះពាល់រយៈពេលវែងផង។ ផ្ទុយទៅវិញ សំណួរមួយចំនួនផ្តោតលើការឆ្លើយតបចំពោះការសម្លុត។ ទោះជាយ៉ាងណាក៏ដោយ ទិន្នន័យដែលប្រមូលបានផ្តល់លទ្ធភាពឱ្យគេអាចទាញនូវសេចក្តីសន្និដ្ឋានច្បាស់លាស់ជាច្រើន និងដាក់ចេញនូវមូលដ្ឋានរឹងមាំ សម្រាប់ការស្រាវជ្រាវបន្ថែម។

# ៣. អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងប្រទេសកម្ពុជា

## ៣.១. ក្របខ័ណ្ឌច្បាប់ - ច្បាប់របស់ប្រទេសកម្ពុជា

បញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា ពុំបានទទួលការយកចិត្តទុកដាក់ច្រើនក្នុងច្បាប់របស់ប្រទេសកម្ពុជាឡើយ។ អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាពុំស្ថិតក្រោមវិសាលភាពច្បាប់ជាក់លាក់ពោលគឺការស្រឡាញ់ភេទដូចគ្នាមិនត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ ហើយក៏មិនបានទទួលការការពារតាមច្បាប់នោះដែរ ។ ការរួមភេទជាមួយអ្នកដែលមានភេទដូចគ្នា មិនមែនជាទង្វើខុសច្បាប់ក្នុងប្រទេសកម្ពុជានោះទេហើយប្រទេសនេះក៏នៅមិនទាន់មានច្បាប់ប្រឆាំងការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នានោះដែរ។ ដូចគ្នាដែរពុំមានការដាក់ទោសព្រហ្មទណ្ឌជាក់លាក់លើអ្នកដែលបំពានសិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀន ឬនៅកន្លែងផ្សេងទៀតឡើយ។

មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ធានាសមភាពចំពោះមុខច្បាប់។

*"ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។"*

ខណៈពេលដែលគេអាចអះអាងថា អ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានគ្របដណ្តប់ ក្នុង "ស្ថានភាពឯទៀត" ទឡ្ហីករណ៍នេះមានកម្រិតខ្សោយ ដោយសារតែមានការរៀបរាប់ជាក់លាក់ពីប្រភេទទាំង ៩ ។ បញ្ញត្តិធម្មនុញ្ញមួយទៀត អាចត្រូវបានគេបកស្រាយថាជាការផ្តល់ការការពារមួយចំនួនដល់អ្នកស្រឡាញ់ភេទដូចគ្នានោះគឺបញ្ញត្តិដែលមានដាក់បញ្ចូលសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ទៅក្នុងច្បាប់របស់ប្រទេសកម្ពុជា ៖[7]

*"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចដែលមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។"*

ប៉ុន្តែ ដូចដែលលើកឡើងក្នុងផ្នែក ៣.២ ខាងក្រោម ច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក៏ពុំមានច្បាស់លាស់អំពីការការពារដែលផ្តល់ដល់អ្នកស្រឡាញ់ភេទដូចគ្នានោះដែរ។

លើសពីនេះ ក៏នៅមានការខ្វះខាតបញ្ញត្តិអំពីការប្រឆាំងនឹងការរើសអើងផ្អែកលើនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ នៅក្នុងច្បាប់ផ្សេងទៀតរបស់ប្រទេសកម្ពុជានោះដែរ។ ឧទាហរណ៍ក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ របស់ព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") ហាមឃាត់ក្នុងការរើសអើងដោយផ្អែកលើមូលដ្ឋានមួយចំនួន ប៉ុន្តែស្រដៀងគ្នាទៅនឹងរដ្ឋ

[7] ដូចដែលត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

ធម្មនុញ្ញដែរពុំមានការលើកឡើងពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រនោះឡើយ។ ប៉ុន្តែខុសពីរដ្ឋធម្មនុញ្ញមាត្រា ២៦៥ នៃក្រមព្រហ្មទណ្ឌពុំបានដាក់បញ្ចូល "ស្ថានភាពផ្សេងទៀត" ថាជាមូលដ្ឋានហាមឃាត់មិនឱ្យមានការរើសអើងនោះឡើយ ដោយរៀបរាប់ត្រឹមតែជាតិពន្ធុ ឬពូជសាសន៍ សាសនា និន្នាការនយោបាយ សកម្មភាពសហជីព ស្ថានភាពគ្រួសារ ភេទ សុខភាព និងពិការភាព តែប៉ុណ្ណោះ។ លើសពីនេះ មាត្រា ១២ នៃច្បាប់ស្តីពីការងារឆ្នាំ ១៩៩៧ ក្នុងការរើសអើងលើមូលដ្ឋានដែលត្រូវបានហាមខាត់មួយចំនួនដូចជាពូជសាសន៍ ពណ៌សម្បុរ ភេទ ជំនឿ សាសនា និន្នាការនយោបាយ ជាតិកំណើត ដើមកំណើតសង្គមនិងការចូលជាសមាជិកសហជីព ឬការធ្វើសកម្មភាពក្នុងសហជីព។ ដូចករណីខាងដើមដែរនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រមិនត្រូវបានដាក់បញ្ចូលជាមូលដ្ឋានហាមឃាត់ឱ្យមានការរើសអើងនោះទេ។

បើទោះបីជាពុំមានផ្តល់ការការពារដល់អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងច្បាប់ជាតិរបស់ប្រទេសកម្ពុជាក៏ដោយ ការវិវឌ្ឍផ្នែកច្បាប់ដ៏ល្អមួយកើតឡើងជាមួយនឹងនិរាករណ៍លើការហាមឃាត់មិនឱ្យមានការរៀបការមនុស្សភេទដូចគ្នា ជាមួយការអនុម័តលើក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧។ រហូតដល់ឆ្នាំ២០១១ មាត្រា ៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ ១៩៨៩ ឱ្យនិយមន័យអាពាហ៍ពិពាហ៍ថាជា *"កិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងរវាងបុរសម្នាក់ និងស្ត្រីម្នាក់"* ហើយមាត្រា ៦ ហាមឃាត់យ៉ាងច្បាស់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍រវាង *"បុគ្គលមានភេទដូចគ្នា"*។ មាត្រា ៧៨ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីឆ្នាំ២០១១ បានធ្វើនិរាករណ៍បញ្ញត្តិភាគច្រើននៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ ក្នុងនោះមានមាត្រា ៣ និងមាត្រា ៦ ផងដែរ។ ឥឡូវនេះ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ គ្របដណ្តប់លើការហាមឃាត់ដែលអាចមានចំពោះភាគីនៃអាពាហ៍ពិពាហ៍ក្នុងប្រទេសកម្ពុជា។ នៅក្នុងជំពូកទី ៣ *"អាពាហ៍ពិពាហ៍"* ពុំមានការហាមឃាត់ច្បាស់លាស់មិនឱ្យមានការរៀបអាពាហ៍ពិពាហ៍របស់បុគ្គលភេទដូចគ្នា ហើយក៏ពុំមានការលើកឡើងឱ្យបានជាក់លាក់ថាការរៀបអាពាហ៍ពិពាហ៍ត្រូវតែធ្វើឡើងរវាងបុរសម្នាក់ និងស្ត្រីម្នាក់នោះដែរ។ ប៉ុន្តែភាពរីកច្រើនបែបនេះពុំបានផ្តល់ភាពស្របច្បាប់ដល់អាពាហ៍ពិពាហ៍បុគ្គលភេទដូចគ្នានោះឡើយ មួយផ្នែកគឺដោយសារតែមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា *"អាពាហ៍ពិពាហ៍ត្រូវធ្វើតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់និងតាមគោលការណ៍ស្ម័គ្រចិត្តប្តីមួយប្រពន្ធមួយ"*។ បើទោះបីជាមានបញ្ញត្តិធម្មនុញ្ញបែបនេះក៏ដោយ គម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័ររបស់ម.ស.ម.ក និងដៃគូរបស់ខ្លួនបានចងក្រងទុកជាឯកសារនូវករណីអាពាហ៍ពិពាហ៍ជាច្រើនករណី ដែលទទួលស្គាល់ដោយអាជ្ញាធរមូលដ្ឋានក្នុងប្រទេសកម្ពុជា ជាធម្មតានៅពេលដែលដៃគូម្ខាងយល់ព្រមធ្វើជា "ប្តី" ហើយដៃគូម្ខាងទៀតជា "ប្រពន្ធ"។ ករណីបែបនេះអាចពន្យល់មួយផ្នែកថាដោយសារតែការបកស្រាយមិនជាក់លាក់នូវពាក្យ "ប្តី" និង "ប្រពន្ធ" ក្នុងភាសាខ្មែរ និងមួយផ្នែកទៀត ដោយសារតែការ

អនុវត្តនិងការផ្សព្វផ្សាយច្បាប់នៅមានកម្រិតទាប នៅថ្នាក់មូលដ្ឋានក្នុងប្រទេសកម្ពុជាជាទូទៅ។ អ្វីដែលបន្ថែមទម្ងន់លើសម្មតិកម្មដែលថាអាពាហ៍ពិពាហ៍បុគ្គលភេទដូចគ្នា គឺមានភាពស្របច្បាប់រួចទៅហើយនៅកម្ពុជាគឺការលើកឡើងរបស់អ្នកនាំពាក្យរដ្ឋាភិបាលលោក ផៃ ស៊ីផាន កាលពីថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៥ ដែលបាននិយាយថា *"ពុំមានអ្វីដែលហាមឃាត់ [គូស្រករភេទដូចគ្នា] មិនឱ្យស្រឡាញ់គ្នាឬរៀបការជាមួយគ្នានោះឡើយ"*។ [8] ជារួម ស្ថានភាពច្បាប់ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ភេទដូចគ្នាក្នុងប្រទេសកម្ពុជា អាចត្រូវបានគេរៀបរាប់ល្អបំផុតថានៅមានការភ័ន្តច្រលំ និងពុំភាពច្បាស់លាស់។

អ្វីដែលមានលក្ខណៈពាក់ព័ន្ធជាពិសេស ចំពោះរបាយការណ៍នេះ គឺមាត្រា ៣៥ នៃច្បាប់ស្ដីពីការអប់រំរបស់ប្រទេសកម្ពុជា ដែលផ្ដល់សិទ្ធិជាច្រើនដល់ប្រជាពលរដ្ឋកម្ពុជាទាំងអស់ក្នុងប្រព័ន្ធអប់រំ។ សិទ្ធិទាំងនេះរួមមានសិទ្ធិមានសេរីភាពក្នុងការសិក្សា សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព សិទ្ធិចូលរួមយ៉ាងសកម្មនិងពេញលេញដើម្បីអភិវឌ្ឍស្ដង់ដាអប់រំ សិទ្ធិទទួលបានការគោរពជាពិសេសសិទ្ធិទទួលបានសេចក្ដីថ្លៃថ្នូរ សិទ្ធិមានសេរីភាពរួចផុតពីការធ្វើទារុណកម្មទោះជាក្នុងរូបភាពអ្វីក៏ដោយ និងរួចផុតពីការដាក់ទណ្ឌកម្មលើផ្លូវកាយ និងផ្លូវចិត្ត។ ច្បាប់ស្ដីពីការអប់រំ ឆ្នាំ ២០០៧ ក៏តម្រូវឱ្យសិស្សនិស្សិតខ្មែរគោរព *"តម្លៃសមធម៌យេនឌ័រ"* និង *"សិទ្ធិផ្សេងទៀតរបស់មនុស្ស"*។ លើសពីនេះ សិស្ស និស្សិតដែលត្រូវបានគេរំលោភបំពានសិទ្ធិមានសិទ្ធិតវ៉ាប្រឆាំងនឹងការរំលោភបំពាននិងសិទ្ធិទទួលបានដំណោះស្រាយចំពោះបណ្ដឹងរបស់ពួកគេ។[9]

នៅកម្រិតគោលនយោបាយវិញ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ របស់ប្រទេសកម្ពុជា សន្យាថានឹងផ្ដល់ឱ្យកុមារគ្រប់រូបនូវលទ្ធភាពទទួលបានការអប់រំប្រកបដោយគុណភាពដោយមិនគិតពីឋានៈសង្គមទីតាំងភូមិសាស្ត្រ ជាតិពន្ធុ សាសនា ភាសា យេនឌ័រ និងកាយសម្បទា។ ផែនការនេះក៏សន្យាថានឹងបង្កើតនូវក្របខ័ណ្ឌច្បាប់មួយ ដើម្បីដោះស្រាយការរើសអើងយេនឌ័រតាមសាលារៀនផងដែរ។ ប៉ុន្តែ ផែនការនេះពុំបានលើកឡើងពីបញ្ហានិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រឡើយ។ មានសញ្ញាល្អប្រសើរដែលបង្ហាញពីវឌ្ឍនភាពក្នុងការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នាទៅក្នុងការងារផ្សេងទៀតរបស់រដ្ឋាភិបាល។ ឧទាហរណ៍ក្រសួងអប់រំយុវជននិងកីឡាកាលពីពេលថ្មីៗនេះ បាននឹងកំពុងសហការជាមួយសង្គមស៊ីវិលដើម្បីបណ្ដុះបណ្ដាលគ្រូបង្រៀនកម្ពុជាអំពីការដាក់បញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នា និងស្វែងរកធាតុចូលពីសង្គមស៊ីវិលលើ "សៀវភៅណែនាំអំពីបំណិនជីវិត" (ដែលប្រើប្រាស់តាមសាលារៀនទាំងអស់នៅកម្ពុជា) ដើម្បីធ្វើឱ្យសៀវភៅណែនាំនេះមានភាពងាយស្រួលសម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា។ លើសពីនេះ ក្រសួងកិច្ចការនារីក៏បានដាក់បញ្ចូលបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នាទៅ

---

[8] សារព័ត៌មាន Khmer Times "ប្រទេសកម្ពុជាស្វាគមន៍អាពាហ៍ពិពាហ៍ភេទដូចគ្នា នេះបើតាមការលើកឡើងរបស់អ្នកនាំពាក្យរដ្ឋាភិបាល" (ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៥)។

[9] មាត្រា ៤០ នៃច្បាប់ស្ដីពីការអប់រំ ឆ្នាំ ២០០៧។

ក្នុងផែនការយុទ្ធសាស្ត្ររបស់ខ្លួនស្តីពីសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រីសម្រាប់ឆ្នាំ ២០១៤-២០១៨ ផងដែរ។[10]

## ៣.២. ក្របខ័ណ្ឌច្បាប់ - ច្បាប់សិទ្ធិមនុស្សអន្តរជាតិ

សិទ្ធិទទួលបានការអប់រំមានចែងក្នុងមាត្រា ២៦ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ប.ស.ស.") និងត្រូវបានពង្រីកបន្ថែមក្នុងមាត្រា ១៣ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមនិងវប្បធម៌ ("ក.អ.ស.ស.វ") ដែលប្រទេសកម្ពុជាក៏ជាភាគីមួយផងដែរ ដូចខាងក្រោម៖

*"រដ្ឋភាគីនៃកតិកាសញ្ញានេះទទួលស្គាល់សិទ្ធិរបស់មនុស្សគ្រប់គ្នា ក្នុងការទទួលបានការអប់រំ។ រដ្ឋទាំងនេះយល់ស្របថាការអប់រំត្រូវផ្តោតលើការអភិវឌ្ឍឱ្យបានពេញលេញនូវបុគ្គលិកលក្ខណៈរបស់មនុស្ស និងសេចក្តីថ្លៃថ្នូរ ហើយត្រូវពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ រដ្ឋភាគីយល់ស្របទៀតផងដែរថា ការអប់រំត្រូវផ្តល់លទ្ធភាពឱ្យមនុស្សគ្រប់រូបអាចចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងសង្គមសេរីបង្កើនការយល់ដឹង ការយល់អធ្យាស្រ័យនិងមិត្តភាពក្នុងចំណោមប្រជាជាតិទាំងអស់ និងគ្រប់ក្រុមពូជសាសន៍ ជាតិពន្ធុ ឬសាសនាទាំងអស់ ក៏ដូចជាក្នុងសកម្មភាពរក្សាសន្តិភាពរបស់សហប្រជាជាតិ។"*[11]

ពុំមានសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សរបស់សហប្រជាជាតិណាមួយ ដែលប្រទេសកម្ពុជាជារដ្ឋភាគីលើកឡើងជាក់លាក់អំពីបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នាឡើយ ហើយអ្នកស្រឡាញ់ភេទដូចគ្នា មិនត្រូវបានគេចាត់ទុកថាជាក្រុមដែលទទួលបានការការពារពិសេស ក្នុងការហាមឃាត់មិនឱ្យមានការរើសអើងដូចមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ("ក.អ.ស.ព.ន.") នោះដែរ។ ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែងយុទ្ធសាស្ត្រនៃស្ថាប័នអនុសញ្ញារបស់ប្រជាជាតិលើកឡើងថាច្បាប់សិទ្ធិមនុស្សអន្តរជាតិពិតជាបានផ្តល់ការការពារជាក់លាក់ដល់អ្នកស្រឡាញ់ភេទដូចគ្នា។ ក្នុងឆ្នាំ ១៩៩៤ គណៈកម្មាធិការសិទ្ធិមនុស្សរបស់សហប្រជាជាតិ (ស្ថាប័នសន្ធិសញ្ញា ក.អ.ស.ព.ន.) បានចេញនូវសេចក្តីសម្រេចមួយក្នុងករណីតូនេន *(Toonen) ធៀបនឹងករណីប្រទេសអូស្ត្រាលី* ដែលក្នុងនោះការហាមឃាត់ទៅលើការរើសអើងផ្អែកលើ "ភេទ" ស្របតាមមាត្រា ២៦ នៃក.អ.ស.ព.ន. [12] ត្រូវបានបកស្រាយថាមានបញ្ចូលការរើសអើងផ្អែកលើនិន្នាការភេទ។ [13] ក្នុង

---

[10] ផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ ស្តីពីសមភាពយេនឌ័រ និងការផ្តល់ភាពអង់អាចដល់ស្ត្រី ២០១៤-២០១៨ នារីរតនៈ ៤។

[11] មាត្រា ១៣.១ នៃ ICCPR ។

[12] មាត្រា ២៦ នៃ ICCPR ចែងថា *"មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិ ទទួលបានការការពារស្មើភាពគ្នាពីច្បាប់ ដោយពុំមានការរើសអើង។ ក្នុងន័យនេះ ច្បាប់នេះហាមឃាត់មិនឱ្យមានការរើសអើងអ្វីទាំងអស់ និងធានាផ្តល់ឱ្យមនុស្សគ្រប់រូបនូវការការពារស្មើភាពគ្នា និងប្រកបដោយប្រសិទ្ធភាព ប្រឆាំងនឹងការរើសអើង ផ្អែកលើមូលដ្ឋាននានា ដូចជា ពូជសាសន៍ ពណ៌សម្បុរ*

ករណីយ៉ាំង *(Young) ធៀបនឹងករណីនៅអូស្ត្រាលី* ជាថ្មីម្តងទៀតគណៈកម្មាធិការសិទ្ធិមនុស្សបាន សម្រេចថាការប្រតិបត្តិផ្សេងគ្នាដោយគ្មានហេតុផលផ្អែកលើនិន្នាការភេទគឺជាការរើសអើងក្រោម មាត្រា ២៦ នៃ ក.អ.ស.ព.ន.[14] ។ នៅក្នុងឆ្នាំ ២០១២ គណៈកម្មាធិការសិទ្ធិមនុស្ស បានចេញផ្សាយ នូវសេចក្តីសម្រេចអំពីករណីហ្វេដូតូវ៉ា *(Fedotova) ធៀបនឹងករណីនៅសហព័ន្ធរុស្សី* [15] ដែលក្នុង នោះការហាមឃាត់របស់ប្រទេសរុស្សីមិនឱ្យមាន "ការឃោសនា" អំពីការស្រឡាញ់ភេទដូចគ្នាដល់ អនីតិជន ត្រូវបានរកឃើញថាជាការបំពានសិទ្ធិមានសេរីភាពរួចផុតពីការរើសអើង ក៏ដូចជាសេរី ភាពនៃការបញ្ចេញមតិ របស់ដើមបណ្តឹង។ លើសពីនេះ អនុសញ្ញាស្តីពីសិទ្ធិកុមារ ក.អ.ស.ស.វ និង អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (ហៅកាត់ថា "ស៊ី-ដ") សុទ្ធ តែត្រូវបានបកស្រាយដោយស្ថាប័នអនុសញ្ញារៀងៗខ្លួនថាមានដាក់បញ្ចូលការហាមឃាត់ការ រើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។[16]

ដូច្នេះ តាមរយៈការផ្តល់សច្ចាប័ននិងការទទួលយក ក.អ.ស.ព.ន. និង ក.អ.ស.ស.វ រដ្ឋធម្ម នុញ្ញកម្ពុជាផ្តល់នូវកិច្ចការពារក្នុងកម្រិតមួយដល់អ្នកស្រឡាញ់ភេទដូចគ្នាប្រឆាំងនឹងការរើសអើង។ ប៉ុន្តែ ការមិនមានការលើកឡើងជាក់លាក់អំពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវ ទំនោរយេនឌ័រក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាគួបផ្សំនឹងការពុំមានការផ្សព្វផ្សាយនិងការយល់ដឹង ឱ្យបានទូលំទូលាយអំពីការអនុវត្តច្បាប់អន្តរជាតិមិនត្រឹមតែក្នុងចំណោមអ្នកដែលទទួលរងផលប៉ះ ពាល់ដោយសារការរើសអើងប៉ុណ្ណោះទេ ថែមទាំងដល់អ្នកដែលធ្វើការងារក្នុងប្រព័ន្ធយុត្តិធម៌ផង ធ្វើឱ្យក្របខ័ណ្ឌច្បាប់ពុំមានភាពច្បាស់លាស់។

គោលការណ៍**យ៉កយ៉ាកាតា**គឺជាសំណុំគោលការណ៍ណែនាំដែលត្រូវបានរៀបចំព្រាងឡើង ដោយអ្នកជំនាញខាងសិទ្ធិមនុស្សអន្តរជាតិមួយក្រុមក្នុងឆ្នាំ ២០០៦ ក្នុងគោលបំណងបង្ហាញពី" *ច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលកំពុងមានជាធរមាន ពាក់ព័ន្ធនឹងបញ្ហានិន្នាការភេទនិងអត្ត*

---

*ភេទ ភាសា សាសនា គំនិតនយោបាយ ឬគំនិតផ្សេងទៀត ជាតិកំណើត ឬដើមកំណើតសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពផ្សេង ទៀត។"*

[13] *គណៈកម្មាធិការសិទ្ធិមនុស្សរបស់សហប្រជាជាតិ៖ ការយល់ឃើញរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ក្រោមមាត្រា ៥ កថាខណ្ឌ ៤ នៃ ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ របាយការណ៍លេខ ៤៨៨/១៩៩២*

[14] *គណៈកម្មាធិការសិទ្ធិមនុស្សរបស់សហប្រជាជាតិ៖ ការយល់ឃើញរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ក្រោមមាត្រា ៥ កថាខណ្ឌ ៤ នៃ ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ របាយការណ៍លេខ ៩៤១/២០០០*

[15] *គណៈកម្មាធិការសិទ្ធិមនុស្សរបស់សហប្រជាជាតិ៖ ការយល់ឃើញរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ក្រោមមាត្រា ៥ កថាខណ្ឌ ៤ នៃ ពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ពលរដ្ឋ និងសិទ្ធិនយោបាយ របាយការណ៍លេខ ១៩៣២/២០១០*

[16] See for example: Concluding observations by the HRC: Poland (CCPR/C/79/Add.110), 1999, para. 23; Concluding observations by the CESCR: China (E/C.12/1/Add.58), 2001, paras. 15(c) and 31; Ireland (E/C.12/1/Add.35), 1999, para. 5; អនុសញ្ញាស្តីពីសិទ្ធិកុមារ ៖ *ការពិចារណាលើរបាយការណ៍ ដែលដាក់ដោយរដ្ឋភាគី ក្រោមមាត្រា ៤៤ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ៖ យោបល់សន្និដ្ឋាន៖ ចក្រភព អង់គ្លេស និងអៀរឡង់ខាងជើង* (CRC/C/GBR/CO/4). ២០ តុលា ២០០៨

*សញ្ញាណយេនឌ័រ។*[17] គោលការណ៍ណែនាំទាំងនេះគឺជាសំណុំគោលការណ៍ទូលំទូលាយ បែបបញ្ចុះបញ្ចូលដែលមានឥទ្ធិពលលើការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ចំពោះអ្នកស្រឡាញ់ភេទដូចគ្នា។ បើទោះបីជាវាមិនមែនជាឯកសារដែលចងកាតព្វកិច្ចខាងច្បាប់ក៏ដោយ គោលការណ៍**យ៉កយ៉ាកាតា**មានភាពពាក់ព័ន្ធកម្រិតខ្ពស់ដោយសារតែគោលការណ៍នេះបានបញ្ជាក់ពីគោលការណ៍ច្បាប់ចងកាតព្វកិច្ចដែលមានរួចទៅហើយ។ គោលការណ៍ទី ១៦ នៃគោលការណ៍ **យ៉កយ៉ាកាតា** ចែងថាៈ

*"មនុស្សគ្រប់គ្នាមានសិទ្ធិទទួលបានការអប់រំដោយពុំមានការរើសអើងផ្អែកលើនិង ពិចារណាលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។"*[18]

គោលការណ៍ទី ១៦ លើកឡើងពីការមានកាតព្វកិច្ចវិជ្ជមានចំនួន ៧ លើរដ្ឋដែលត្រូវចាត់វិធានការច្បាប់ក្នុងគោលបំណងលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រព័ន្ធអប់រំដូចជា ការរៀបចំគោលនយោបាយ និងច្បាប់ដើម្បីប្រយុទ្ធនឹងការសម្លុត ផ្អែកលើនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។

## ៣.៣. ឥរិយាបថសង្គម

ដោយសារតែកត្តាវប្បធម៌ សាសនា និងប្រវត្តិសាស្ត្ររួមបញ្ចូលគ្នា ការយល់ឃើញទៅលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រនៅប្រទេសកម្ពុជាមានលក្ខណៈខុសគ្នាស្រលះទៅនឹងបស្ចឹមប្រទេស។ ប្រទេសកម្ពុជាមិនដែលមានបទពិសោធន៍ដាក់ការគាបសង្កត់ជាទ្រង់ទ្រាយធំលើអ្នកស្រឡាញ់ភេទដូចគ្នាពីសំណាក់ស្ថាប័នរដ្ឋឬស្ថាប័នសាសនា ដូចដែលតែងកើតមាននៅតំបន់ផ្សេងទៀតក្នុងពិភពលោកនោះទេ។ បើទោះបីនេះជាបរិបទដែលមានលក្ខណៈវិជ្ជមានក្នុងប្រវត្តិសាស្ត្រកន្លងមកក៏ដោយ អ្នកស្រឡាញ់ភេទដូចគ្នាជាជនជាតិខ្មែរបច្ចុប្បន្ននេះមិនត្រូវបានចាត់ទុកថាជាប្រជាពលរដ្ឋស្មើភាពគ្នានោះទេ ហើយជារឿយត្រូវរស់នៅក្នុងជ្រុងមួយនៃសង្គមកម្ពុជា។ ទន្ទឹមគ្នានឹងការខ្វះក្របខ័ណ្ឌច្បាប់ដែលផ្តល់នូវការការពារឱ្យបានជាក់ច្បាស់ អ្នកស្រឡាញ់ភេទដូចគ្នាត្រូវទទួលរងសម្ពាធសង្គមជាច្រើនដោយជារឿយៗមនុស្សនៅជុំវិញពួកគេតែងមានការយល់ច្រឡំចំពោះពួកគេនិងធ្វើបាបពួកគេ។ ប៉ុន្តែ គួរកត់សម្គាល់ផងដែរថាបុរសស្រឡាញ់បុរសជាទូទៅទទួលបានការអធ្យាស្រ័យជាងស្ត្រីស្រឡាញ់ស្ត្រី និងក្រុមស្រីស្រស់ (អ្នកប្តូរភេទពីប្រុសទៅស្រី និងពីស្រីទៅប្រុស)។

សាសនាដ៏ធំនៅក្នុងប្រទេសកម្ពុជា គឺព្រះពុទ្ធសាសនានិកាយថេរវាទ ដោយមានអ្នកគោរពប្រតិបត្តិប្រមាណជា ៩៧% នៃប្រជាពលរដ្ឋទាំងអស់។[19] ព្រះពុទ្ធសាសនានិកាយនេះជាទូទៅផ្តល់

---

[17] គោលការណ៍ យ៉កយាកាតាៈ ការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ ពាក់ព័ន្ធនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ (២៦ មីនា ២០០៧)។

[18] គោលការណ៍ទី ១៦ នៃគោលការណ៍ យ៉កយាកាតា

ការអធ្យាស្រ័យដល់អ្នកដែលមានភេទភាគតិច ហើយពុទ្ធឱវាទតែងវាចាកនៅការរើសអើងផ្អែកទៅតាមនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័របើធៀបជាមួយនឹងសាសនាផ្សេងទៀតក្នុងពិភពលោក។ របាយការណ៍ឆ្នាំ២០១៤ របស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិលើកឡើងពីពុទ្ធឱវាទថា *"មិនត្រូវមានការបែងចែករវាងអ្នកដែលស្រឡាញ់ភេទដូចគ្នា និងអ្នកដែលស្រឡាញ់ភេទផ្ទុយគ្នា ដោយពួកគេទាំងពីរត្រូវមានសេរីភាពរួចផុតពីគ្រោះថ្នាក់ ដោយមានការយល់ព្រមជាមួយគ្នាទៅវិញទៅមក។"*[20] នៅក្នុងឆ្នាំ ២០១២ ការអបអរសាទរទិវាមោទនភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ត្រូវបានប្រារព្ធបិទជាផ្លូវការនៅវត្តដំបូកខ្ពស់ក្នុងទីក្រុងភ្នំពេញដោយមានការជូនពរជ័យពីព្រះសង្ឃផងដែរ។ ក្នុងពិធីនោះ ព្រះចៅអធិការបានមានសង្ឃដីកាថា *"ព្រះពុទ្ធដែលជាព្រះគ្រូនៃយើងបានប្រៀនប្រដៅយើងឱ្យចេះ ស្រឡាញ់គ្នា ចេះជួយយកអាសាគ្នា និងមិនត្រូវរើសអើងគ្នានោះទេ"។* តំណាងអង្គការសមាគមន៍ឥន្ទធនូកម្ពុជា(រ៉ក់) ដែលធ្វើការងារខាងសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានិងជាអ្នករៀបចំពិធីនេះឡើងបានលើកឡើងថាស្ទើរតែគ្រប់វត្តអារាមទាំងអស់ក្នុងរាជធានីភ្នំពេញរីករាយនឹងរៀបចំពិធីនេះ។[21]

បើទោះបីជាមានការអធ្យាស្រ័យក្នុងព្រះពុទ្ធសាសនាថេរវាទបែបនេះក៏ដោយ ក៏នៅមានកម្លាំងសង្គមដ៏ធំមួយទៀតនៅកម្ពុជាដែលជាឫសគល់នាំឱ្យមានការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នានោះគឺតម្លៃប្រពៃណីគ្រួសារខ្មែរ។ សម្រាប់សិស្សសាលាក្មេងៗ ដែលនៅក្រោមបន្ទុកឪពុកម្តាយរបស់ពួកគេគ្រួសារគឺជាកន្លែងដែលមានអំណាចជាពិសេស។ ការបារម្ភពីកេរ្តិ៍ឈ្មោះរបស់គ្រួសារក្នុងចំណោមសហគមន៍មូលដ្ឋាន នាំឱ្យឪពុកម្តាយរបស់អ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់ប្រតិកម្មជាអវិជ្ជមានចំពោះនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់កូនពួកគេ។ កិច្ចពិគ្រោះយោបល់ថ្នាក់ជាតិដែលធ្វើឡើងដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ ជាមួយអ្នកពាក់ព័ន្ធជាច្រើនអំពីសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាបានបង្ហាញថាអំពើហិង្សាក្នុងគ្រួសារលើកុមារដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ច្រើនតែកើតមានឡើងដោយការជាត់ចេញ ការរើសអើង និងការបំពារបំពានខាងអារម្មណ៍ កើតមានជាទូទៅក្នុងរចនាសម្ព័ន្ធរបស់គ្រួសារ។ អ្នកចូលរួមជាច្រើននាក់ក្នុងកិច្ចពិគ្រោះយោបល់នេះបានរាយការណ៍ពី *"ការប្រមាថ ការវាយដំ ការជេរប្រទេច ការបន្ទោស និងការដកហូតគ្រឿងសម្ភារផ្ទាល់ខ្លួន"* ពីសំណាក់ឪពុកម្តាយ ដោយសារតែនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់កូន[22] បើតាមរបាយការណ៍របស់ម.ស.ម.ក នៅក្នុងឆ្នាំ២០១២ ឪពុកម្តាយជាច្រើននាក់ជឿថាកូនដែលជាអ្នកស្រឡាញ់

---

[19] មជ្ឈមណ្ឌលស្រាវជ្រាវ Pew៖ សាសនា និងជីវិតសាធារណៈ: *សមាសភាគសាសនាបែងចែកតាមប្រទេស ២០១០-២០៥០* <http://www.pewforum.org/2015/04/02/religious-projection-table/>

[20] កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ "ការធ្វើជាអ្នកស្រឡាញ់ភេទដូចគ្នា នៅអាស៊ី៖ របាយការណ៍ សម្រាប់ប្រទេសកម្ពុជា(២០១៤)

[21] "មោទនភាពបញ្ចប់ជាមួយនឹងពរជ័យតាមបែបព្រះពុទ្ធសាសនា" សារព័ត៌មាន Phnom Penh Post (២២ ឧសភា ២០១២)

[22] កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ "ការធ្វើជាអ្នកស្រឡាញ់ភេទដូចគ្នា នៅអាស៊ី៖ របាយការណ៍ សម្រាប់ប្រទេសកម្ពុជា(២០១៤)

ភេទដូចគ្នារបស់ពួកគេមានជំងឺផ្លូវចិត្ត ហើយព្យាយាម"ព្យាបាល" កូនប្រុស ឬកូនស្រីរបស់ខ្លួនដោយយកពួកគេទៅគ្រូខ្មែរ។ ការបង្ហាញពីអត្តសញ្ញាណពិតប្រាកដក្នុងប្រទេសកម្ពុជា ជារឿយៗនាំឱ្យមានការបដិសេធពីគ្រួសារ ដោយពេលខ្លះកូនត្រូវបានបណ្តេញចេញពីផ្ទះក៏មាន។ មនុស្សវ័យក្មេងដែលជាអ្នកស្រឡាញ់ភេទដូចគ្នាក្នុងករណីនេះ ងាយទទួលរងការរើសអើងពីមនុស្សដែលពួកគេមិនស្គាល់ ពីនគរបាល និងពីអ្នកផ្សេងទៀត។ ដោយពុំមានការគាំទ្រហិរញ្ញវត្ថុ ហើយឱកាសការងារទៀតសោតក៏មានតិចតួច យុវជនដែលជាអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់ ជាពិសេសបុរសស្រឡាញ់បុរសនិងស្រីស្រស់ (អ្នកប្តូរភេទពីបុរសទៅស្រី) ត្រូវរកស៊ីផ្លូវភេទ ដើម្បីទ្រទ្រង់ជីវភាពរបស់ខ្លួន។ បើតាមការសិក្សាមួយ ក្នុងចំណោមអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ដែលជាអ្នកឆ្លើយសំណួរ មាន ៧% រកស៊ីផ្លូវភេទ។[23]

ក្នុងចំណោមអ្នកដែលត្រូវបានបង្ខំឱ្យចេញពីផ្ទះគឺបញ្ហាផ្លូវចិត្ត ដែលមនុស្សវ័យក្មេងជាអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់ជួបប្រទះគឺសម្ពាធឱ្យរៀបការបែបប្រពៃណី ជាមួយនឹងអ្នកដែលមានភេទផ្ទុយពីពួកគេ ពីសំណាក់ឪពុកម្តាយរបស់ពួកគេ។ អាពាហ៍ពិពាហ៍ មានតួនាទីយ៉ាងសំខាន់ជាពិសេស នៅក្នុងវប្បធម៌របស់ប្រទេសកម្ពុជា ហើយ ម.ស.ម.ក ធ្លាប់ជួបនឹងអាពាហ៍ពិពាហ៍ដោយបង្ខំជាច្រើនករណីបែបនេះ។ នៅក្នុងស្ថានភាពបែបនេះ ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ តែងកើតមានឡើង។

នៅក្នុងប្រទេសកម្ពុជា នៅមិនទាន់មានទិន្នន័យស្រាវជ្រាវគ្រប់ជ្រុងជ្រោយអំពីឥរិយាបថសង្គមចំពោះនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនៅឡើយទេ។ ការសិក្សាដាច់ដោយឡែកជាច្រើនត្រូវបានធ្វើឡើងដែលផ្តល់នូវគំនិតស៊ីជម្រៅមួយចំនួន ប៉ុន្តែវិសាលភាពមានកម្រិត។ បើតាមការសម្ភាសដែលម.ស.ម.កធ្វើឡើងក្នុងឆ្នាំ២០១២ លទ្ធភាពដែលសិស្សជាអ្នកស្រឡាញ់ភេទដូចគ្នាបោះបង់ចោលការសិក្សាមានកម្រិតខ្ពស់ជាងអត្រាបោះបង់ចោលការសិក្សាដោយគិតជាមធ្យមនៅថ្នាក់ជាតិ ជាពិសេសដោយសារតែ"*ការលំបាកខាងសេដ្ឋកិច្ចដែលកើតឡើងដោយសារតែការមិនទទួលយកពីក្រុមគ្រួសាររបស់ពួកគេ*" និង"*ការដាក់ឈ្មោះមិនសមរម្យនិងការសម្លុតពីសំណាក់មិត្តរួមថ្នាក់របស់ពួកគេដោយសារតែនិន្នាការភេទរបស់ពួកគេ។*" [24] ការសិក្សាឆ្នាំ២០១៣ ស្តីពីការផាត់អ្នកស្រឡាញ់ភេទដូចគ្នាចេញពីសង្គមក្នុងប្រទេសកម្ពុជា ដែលពិនិត្យលើការទទួលបានការអប់រំកម្រិតសកលវិទ្យាល័យបានរកឃើញថាមានបុរសស្រឡាញ់បុរស ២០% ស្ត្រីស្រលាញ់ស្ត្រីចំនួន ១៧% និងក្រុមស្រីស្រស់តែ ៦% ប៉ុណ្ណោះ ដែលបានទទួលការអប់រំកម្រិត

[23] Vicente S.Salas និង Srun Sorn "ការស្វែងយល់ពីការផាត់ចេញពីសង្គមនៃស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់ប្រុស និងអ្នកប្តូរភេទក្នុងគ្រួសារ និងសហគមន៍ នៅតាមតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា និងវិធីដោះស្រាយរបស់ពួកគេ" (របាយការណ៍) (ឆ្នាំ ២០១២)
[24] ម.ស.ម.ក "ឥន្ទធនូខ្មែរ៖ កែប្រែការរើសអើងទៅជាមោទនភាព" (របាយការណ៍) (ខែ ធ្នូ ឆ្នាំ ២០១២) ទំព័រ១៩

សកលវិទ្យាល័យ។[25] នៅក្នុងការសិក្សាមួយនៅឆ្នាំ២០១២ ដែលធ្វើការអង្កេតតែលើបុរសស្រឡាញ់ភេទដូចគ្នា មានអ្នកឆ្លើយសំណួរចំនួន៦៣% បានលើកឡើងថាពួកគេនឹងទទួលរងភាពអាម៉ាស់នៅពេលមានកូនប្រុសជាមនុស្សស្រឡាញ់បុរសដូចគ្នា។ ប៉ុន្តែ ការអង្កេតដដែលនេះបានសួរថាតើគួរមានការដាក់ឱ្យអនុវត្តច្បាប់ប្រឆាំងការរើសអើងផ្អែកលើនិន្នាការភេទដែរឬទេ អ្នកឆ្លើយសំណួរ ៦៥% បានលើកឡើងថាពួកគេនឹងគាំទ្រឱ្យមានការដាក់ចេញច្បាប់បែបនេះ។[26]

នៅក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រដែលកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិរៀបចំឡើង បញ្ហាមួយចំនួនដែលសិស្សជាអ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះក្នុងប្រទេសកម្ពុជាត្រូវបានលើកឡើង ។ ក្រៅតែពីការសម្លុតនិងការសើចចំអកឡកឡឺយដាក់ពីសំណាក់មិត្តរួមថ្នាក់របស់ពួកគេ អ្នកចូលរួមបានរាយការណ៍ថាត្រូវបានគ្រូបង្រៀននិងបទបញ្ជាផ្ទៃក្នុងរបស់សាលារៀនបង្ខំឱ្យស្លៀកពាក់ឯកសណ្ឋានដែលមិនត្រូវនឹងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ អ្នកដែលមិនធ្វើតាមបានរាយការណ៍ថាត្រូវទទួលរងការស្តីបន្ទោសជាសាធារណៈនិងទទួលរងភាពអាម៉ាស់ពីសំណាក់អាជ្ញាធរសាលារៀន ។ នេះជាលើកទីមួយហើយដែលការស្រាវជ្រាវរបស់ម.ស.ម.ក អំពីការសម្លុតលើអ្នកស្រឡាញ់ភេទដូចគ្នាក្នុងសាលារៀន មានគោលបំណងធ្វើការប្រមូលទិន្នន័យពាក់ព័ន្ធនឹងបញ្ហាជាច្រើន ដែលត្រូវបានលើកឡើងក្នុងកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិនេះ។

---

[25] Vicente S.Salas និង Srun Sorn "ការស្វែងយល់ពីការផាត់ចេញពីសង្គមនៃស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់ប្រុស និងអ្នកប្តូរភេទក្នុងគ្រួសារ និងសហគមន៍ នៅតាមតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា និងវិធីដោះស្រាយរបស់ពួកគេ" (របាយការណ៍) (ឆ្នាំ ២០១២)

[26] ក្រុមហ៊ុនដំរីស្រាវជ្រាវ និងពិគ្រោះយោបល់ "ការអង្កេតបឋមលើយុទ្ធនាការប្រាស្រ័យទាក់ទងរួមគ្នាលើអំពើហិង្សាលើស្ត្រី" (របាយការណ៍) (ឆ្នាំ ២០១២)

# ៤. បរិបទសាកល ៖ ការសម្លុតយុវជនដែលជាអ្នកស្រឡាញ់ភេទដូចគ្នា

## ៤.១. សេចក្តីផ្តើម

នៅក្នុងសកលលោកទាំងមូលមានសិស្សសាលារាប់លាននាក់ដែលតែងរងគ្រោះដោយសារតែការបំពានផ្លូវកាយ ពាក្យសម្តី អារម្មណ៍ និងផ្លូវចិត្តតាមគ្រឹះស្ថានអប់រំនិងក្នុងបរិបទនៃ ការអប់រំ។ ការសម្លុតដោយសារមូលហេតុអ្វីក៏ដោយឬគ្មានមូលហេតុអ្វីសោះ មានផលប៉ះពាល់ជ្រាលជ្រៅនិងយូរអង្វែង នៅលើជីវិតរបស់សិស្សដែលរារាំងពួកគេក្នុងការទទួលបាននូវសិទ្ធិជាមូលដ្ឋានជាច្រើនរបស់ពួកគេ។

យោងតាមអង្គការយូណេស្កូបានរកឃើញថាការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័របានកាត់បន្ថយវត្តមានសិស្សក្នុងសាលារៀន មានផលប៉ះពាល់លើអត្រានៃការបោះបង់ចោលការសិក្សា និងធ្វើឱ្យខូចដល់ការសិក្សានិងលទ្ធផលសិក្សា។ លើសពីនេះ ការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រមានផលវិបាកធ្ងន់ធ្ងរលើសុខភាពផ្លូវចិត្តរបស់យុវជនដែលនាំឱ្យមានផលប៉ះពាល់អវិជ្ជមានមកលើការអប់រំរបស់ពួកគេ។ ការសិក្សានានាបានរកឃើញថាការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ ដែលអូសបន្លាយក្នុងរយៈពេលវែងគឺជាកត្តារួមចំណែកដ៏ធំមួយដែលនាំឱ្យប៉ះពាល់ដល់ការបាក់ទឹកចិត្ត ការថប់បារម្ភ ការបាត់បង់ទំនុកចិត្ត ការដកខ្លួន ការនៅឯកាក្នុងសង្គម ការធ្វើបាបលើខ្លួនឯង និងការប៉ុនប៉ងចង់សម្លាប់ខ្លួនរបស់ជនរងគ្រោះ។ ការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ មានផលប៉ះពាល់មកលើអ្នកដែលទទួលរងការសម្លុត អ្នកដែលសម្លុតគេ អ្នកឈរមើល និងសាលារៀនដែលការសម្លុតកើតមានឡើង ។ ការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញមានផលវិបាកធ្ងន់ធ្ងរទៅលើការអប់រំ ។ វាមានផលប៉ះពាល់លើសិទ្ធិទទួលបានការអប់រំ ។ វាគឺជាទម្រង់មួយនៃការរើសអើងនិងការផាត់ចេញ ហើយវាបំពានគោលការណ៍សុវត្ថិភាពក្នុងសាលារៀន។[27]

ការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រគឺជាករណីដែលមិនទាន់មានការសិក្សាច្រើននៅឡើយ ហើយអង្គការសហប្រជាជាតិចាប់ផ្តើមយកចិត្តទុកដាក់លើបញ្ហានេះជាលើកទីមួយនៅឆ្នាំ ២០១១ ប៉ុណ្ណោះ ក្នុងទម្រង់ជាកិច្ចពិគ្រោះយោបល់អន្តរ

[27] អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់សហប្រជាជាតិ "ផលប៉ះពាល់ដោយសារការសម្លុតប្រឆាំងទៅនិងអ្នកស្រឡាញ់ភេទដូចគ្នា" <http://www.unesco.org/new/en/education/themes/leading-the-international-agenda/health-education/homophobic-bullying/bullying/>

ជាតិដើម្បីដោះស្រាយបញ្ហាសម្លុតដោយសារតែការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នាក្នុងគ្រឹះស្ថានអប់រំជាមួយនឹងទីភ្នាក់ងារសហប្រជាជាតិ អង្គការមិនមែនរដ្ឋាភិបាល ក្រសួងអប់រំ និង ស្ថាប័នសិក្សាស្រាវជ្រាវមកពីជាង២៥ ប្រទេសនៅជុំវិញពិភពលោក។[28] ចាប់តាំងពីពេលនោះមកយូណេស្កូ បាននិងជំរុញលើកកម្ពស់ឱ្យមានកិច្ចខិតខំប្រឹងប្រែងជាសកលដើម្បីធ្វើការប្រមូលទិន្នន័យអំពីប្រេវ៉ាឡង់ មូលហេតុ ផលប៉ះពាល់ និងប្រភេទនៃការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរផ្លូវភេទតាមសាលារៀននានាទូទាំងពិភពលោក។ កាលពីពេលថ្មីៗនេះ ការសិក្សានៅថ្នាក់ជាតិអំពីការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រត្រូវបានធ្វើឡើងនៅតាមប្រទេសជាច្រើនក្នុងពិភពលោក។

## ៤.២. អាស៊ី

នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានការកើនឡើងគួរឱ្យកត់សម្គាល់នូវការផ្តោតការយកចិត្តទុកដាក់លើបញ្ហានិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ និងសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅអាស៊ី។ បើទោះបីជាមានការសិក្សាតិចតួចពាក់ព័ន្ធនឹងការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រក៏ដោយ ក៏បញ្ហាប្រឈមរបស់អ្នកស្រឡាញ់ភេទដូចគ្នាគឺជាបញ្ហាមួយដែលទីបំផុតត្រូវបានដាក់បញ្ចូលទៅក្នុងកិច្ចពិគ្រោះយោបល់ជាតិនិងក្នុងវេទិកានយោបាយរបស់បណ្តាប្រទេសជាច្រើនក្នុងតំបន់នេះ។ ការពិនិត្យឡើងវិញលើដំណើរវិវឌ្ឍន៍កន្លងមកបានផ្តល់នូវសារតារនិងបរិបទដ៏មានប្រយោជន៍សម្រាប់ការស្រាវជ្រាវរបស់ ម.ស.ម.ក ក្នុងប្រទេសកម្ពុជា។

អត្ថបទជាច្រើនដែលត្រូវបានបោះពុម្ពផ្សាយកាលពីពេលថ្មីនេះ ក្នុងសៀវភៅការពិនិត្យឡើងវិញក្យូតូលើអាស៊ីអាគ្នេយ៍ (Kyoto Review of Southeast Asia) ផ្តោតទៅលើសម្ពាធដែលអ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះ និងវឌ្ឍនភាពដែលសម្រេចបានក្នុងការទទួលស្គាល់សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅតាមប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍នេះ។ អ្វីដែលគួរឱ្យកត់សម្គាល់ បទពិសោធន៍របស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសមីយ៉ាន់ម៉ា មានលក្ខណៈស្រដៀងគ្នាទៅនឹងបទពិសោធន៍របស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាដែរ ដោយសម្ពាធសង្គមនិងតម្លៃប្រពៃណីគ្រួសារតែងនាំឱ្យមានការទទួលរងភាពអាម៉ាស់និងការសៅហ្មងចិត្ត និងពេលខ្លះនាំឱ្យមានអំពើហិង្សាលើអ្នកស្រឡាញ់ភេទដូចគ្នា។[29] ការសិក្សាមួយ ដែលធ្វើឡើងដោយសាស្ត្រាចារ្យដូហ្គ្លាស សែនដឺ (Douglas Sanders) នៃសកលវិទ្យាល័យម៉ាហ៊ីដុលក្នុងទីក្រុងបាងកក បានរំលេចឱ្យ

---

[28] អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់សហប្រជាជាតិ "ការឆ្លើយតបរបស់វិស័យអប់រំចំពោះការសម្លុតដោយសារតែការរើសអើងភេទដូចគ្នា" (កូនសៀវភៅ) (ឆ្នាំ ២០១២) <http://unesdoc.unesco.org/images/0021/002164/216493e.pdf>

[29] David Gilbert "ការរើសអើងលើអ្នកប្តូរភេទក្នុងគ្រួសារ និងសាច់ញាតិ ក្នុងប្រទេសមីយ៉ាន់ម៉ា" (សារព័ត៌មាន *Kyoto Review of Southeast Asia*, កញ្ញា ២០១៥) <http://kyotoreview.org/issue-18/familial-transphobia-kinship-opens-myanmar/>

ឃើញពីវឌ្ឍនភាពដែលសម្រេចបានកាលពីពេលថ្មីៗនេះ ក្នុងការទទួលស្គាល់សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសវៀតណាមនិងប្រទេសថៃ។ [30] ពាក់ព័ន្ធនឹងប្រទេសវៀតណាម លោក សែនដឺបានបង្ហាញពីការអនុវត្តឃឹតយ៉ាវក្នុងការផ្លាស់ប្តូរច្បាប់ទាក់ទិនអាពាហ៍ពិពាហ៍និងការរួមរស់ជាប្តីប្រពន្ធរបស់អ្នកស្រឡាញ់ភេទដូចគ្នា។ អ្វីដែលមានលក្ខណៈវិជ្ជមាននោះគឺក្នុងប្រទេសវៀតណាម សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានលើកយកមកជជែកវែកញែកនៅកម្រិតរដ្ឋាភិបាល ហើយតួអង្គសង្គមស៊ីវិលបានចូលរួមយ៉ាងសកម្មក្នុងកិច្ចពិគ្រោះយោបល់នេះ។ ពាក់ព័ន្ធនឹងប្រទេសថៃវិញ លោក សែនដឺ បានលើកឡើងថារដ្ឋាភិបាលបច្ចុប្បន្នមិនសូវចាប់អារម្មណ៍ចំពោះបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នាឡើយប៉ុន្តែលោកបានកត់សម្គាល់ថារដ្ឋាភិបាលហាក់មិនបានប្រឆាំងទាំងស្រុងទៅលើពួកគេ ពុំមានការរឹតបន្តឹងលើការបោះពុម្ពផ្សាយទស្សនាវដ្តីរបស់ក្រុមបុរសស្រឡាញ់បុរសនិងអង្គការសង្គមស៊ីវិលរបស់ក្រុមបុរសស្រឡាញ់បុរសឡើយ។ លោក សែនដឺក៏បានទទួលស្គាល់ផងដែរថាការអនុម័តច្បាប់ស្តីពីសមភាពភេទកាលពីពេលថ្មីៗនេះបាននាំមកនូវការប្រតិបត្តិស្មើគ្នាដល់អ្នកប្តូរភេទ។ ដូច្នេះមានហេតុផលសមស្របដើម្បីសន្និដ្ឋានថាប្រទេសកម្ពុជានៅតាមក្រោយប្រទេសជិតខាងទាំងពីរពាក់ព័ន្ធនឹងការវឌ្ឍនធ្វើច្បាប់ទាក់ទិននឹងបញ្ហានិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។

ដោយឡែកនៅថ្នាក់តំបន់វិញ ក្រុមសកម្មជនសិទ្ធិមនុស្សដ៏ល្បីមួយក្រុម ដែលហៅខ្លួនឯងថាក្រុមនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រនៅអាស៊ាន (ASEAN SOGIE Caucus) ត្រូវបានបង្កើតឡើងក្នុងគោលបំណងចម្បងគឺឱ្យមានការដាក់បញ្ចូលសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងហេដ្ឋារចនាសម្ព័ន្ធសិទ្ធិមនុស្សរបស់អាស៊ាន[31] ជាកិច្ចការមួយដែលមានការលំបាកខ្លាំង ដោយសារតែគោលការណ៍មិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដែលជាគោលការណ៍គ្រឹះមួយរបស់អាស៊ាន[32] និងដោយសារតែការសម្រេចចិត្តនានាត្រូវធ្វើឡើងដោយមានការឯកភាពគ្នាជាឯកច្ឆន្ទ។[33] ទោះជាយ៉ាងណាក៏ដោយបង្ហាញឱ្យឃើញពីដំណើរការរីកចម្រើនទាក់ទិនបញ្ហានិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រនិងសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាដែលត្រូវដាក់ក្នុងរបៀបវារៈនយោបាយនៅអាស៊ីអាគ្នេយ៍នេះ។

ដើម្បីឱ្យមានការផ្តោតការយកចិត្តទុកដាក់នៅថ្នាក់តំបន់នៃគំនិតផ្តួចផ្តើមសកលរបស់ យូណេស្កូ ដើម្បីប្រយុទ្ធប្រឆាំងនឹងការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រតាមសាលារៀន យូណេស្កូបានរៀបចំនូវ "កិច្ចពិគ្រោះយោបល់អាស៊ីប៉ាស៊ីហ្វិចលើកទី ១ ស្តីពីការសម្លុតតាមសាលារៀនផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញ

[30] Douglas Sanders "ទំនាក់ទំនងភេទតែមួយ៖ ការផ្តល់ការទទួលស្គាល់ ក្នុងប្រទេសវៀតណាម និងថៃ" (សារព័ត៌មាន *Kyoto Review of Southeast Asia*, កញ្ញា ២០១៥) <http://kyotoreview.org/issue-18/same-sex-relationships-vietnam-thailand/>

[31] https://aseansogie.wordpress.com/

[32] ធម្មនុញ្ញអាស៊ានមាត្រា២

[33] ធម្មនុញ្ញអាស៊ានមាត្រា២០

នូវទំនោរយេនឌ័រ”កាលពីខែមិថុនា ឆ្នាំ២០១៥ ក្នុងទីក្រុងបាងកកប្រទេសថៃ។ កិច្ចពិគ្រោះយោបល់នេះមានគោលបំណងពង្រីកចំណេះដឹងនិងការយល់ដឹងអំពីការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រដែលកើតមាននៅតាមគ្រឹះស្ថានអប់រំនៅអាស៊ីប៉ាស៊ីហ្វិច កំណត់និងចែករំលែកឧទាហរណ៍អំពីការអនុវត្តល្អដើម្បីបង្ការនិងឆ្លើយតបចំពោះការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រនិងបង្កលក្ខណៈឱ្យមានការអនុវត្តសកម្មភាពតាមប្រទេសមួយចំនួនដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញដែលកើតមាននៅតាមសាលារៀន។

មានការសិក្សាមួយចំនួនតូចត្រូវបានធ្វើឡើងក្នុងតំបន់នេះពាក់ព័ន្ធនឹងការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការនូវទំនោរយេនឌ័រ ។ ឧទាហរណ៍ ការអង្កេតតាមប្រព័ន្ធអ៊ិនធើណែតកាលពីពេលថ្មីៗដែលត្រូវបានធ្វើឡើងក្នុងប្រទេសជប៉ុនបានរកឃើញថាមានអ្នកឆ្លើយសំណួរជាបុរសស្រឡាញ់បុរសនិងអ្នកស្រឡាញ់ទាំងពីរភេទចំនួន៥៩% ទទួលរងការសម្លុតដែលនាំឱ្យមានចំនួន ២៣% គេចមិនចូលសាលារៀន និង ចំនួន១៨% ធ្វើបានខ្លួនឯង។[34]

ការសិក្សាមួយក្នុងប្រទេសថៃដែលធ្វើឡើងដោយសកលវិទ្យាល័យមាហីដុល (Mahidol) ក្នុងទីក្រុងបាងកក និងរៀបចំដោយអង្គការយូណេស្កូប្រចាំនៅបាងកក និងអង្គការផ្លែនអន្តរជាតិប្រទេសថៃដែលមានដាក់បញ្ចូលការអង្កេតមួយ ដែលបំពេញដោយសិស្សនិស្សិតចំនួន ២០៧០ នាក់ អាយុចន្លោះពី ១៣ ដល់ ២០ ឆ្នាំ ក៏ដូចជាការសម្ភាសស៊ីជម្រៅ និងការពិភាក្សាក្រុមគោលដៅផងនោះបានរកឃើញថាអ្នកឆ្លើយការអង្កេតចំនួន ៥៦% បានរាយការណ៍ថាទទួលរងការសម្លុតនៅក្នុងខែកន្លងទៅ ដោយសារតែនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់ពួកគេ។[35] ការសិក្សានេះបានរកឃើញទៀតថាការរំលោភបំពានខាងសង្គម (ការផាត់ចេញពីសង្គមដោយជួបផ្ទាល់និងតាមប្រព័ន្ធអ៊ិនធើណែត) គឺជាប្រភេទនៃការសម្លុតដែលកើតមានញឹកញាប់ជាងគេមានចំនួន ៣៦% ហើយការបំពានផ្លូវកាយគឺជាប្រភេទដែលតែងតែកើតឡើងបន្ទាប់មានចំនួន ៣១%។ អ្វីដែលគួរឱ្យព្រួយបារម្ភមានមនុស្សតិចតួចដែលត្រូវបានគេសម្លុតប៉ុណ្ណោះបានស្វែងរកជំនួយពីគ្រឹះស្ថានអប់រំរបស់ពួកគេ ដោយមានតិចជាងមួយភាគប្រាំ (ស្មើនឹង ១៩,៥%) ទៅរកបុគ្គលិកដែលធ្វើការងារពាក់ព័ន្ធនឹងសាលារៀនឱ្យជួយ។ អ្នកឆ្លើយសំណួរចំនួន៦៨% ពុំបានប្រាប់អ្នកណាឱ្យដឹងឡើយ ហើយ២៣% អះអាងថានេះគឺដោយសារតែ *"នឹងពុំមានអ្វីកើតឡើងឡើយ បើទោះបីជាពួកគេទៅប្រាប់អ្នកណាម្នាក់ក៏ដោយ"*។ ក្នុងចំណោមអ្នកដែលទទួលរងការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រមានចំនួន ២៣%

---

[34] Yuki Nikaido, "ការសម្លុតរាលដាល សម្រាប់ក្មេងជំទង់ដែលជាប្រុសស្រឡាញ់ប្រុស និងអ្នកស្រឡាញ់ភេទទាំងពីរ" *សារព័ត៌មាន The Asahi Shimbun* (០១ កញ្ញា ២០១៥) <http://ajw.asahi.com/article/behind_news/social_affairs/AJ201509010026>

[35] 'តើជាមិនភក្តិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅប្រទេសថៃ?: សង្ខេបអំពីការសម្លុតនៅសាលារៀនដោយសារ និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ (២០១៨): http://unesdoc.unesco.org/images/0022/002277/227706E.pdf

រាយការណ៍ថាជួបប្រទះនឹងបញ្ហាបាក់ទឹកចិត្ត (បើធៀបជាមួយនឹង ៦% នៃអ្នកដែលពុំបានរាយការណ៍ថាបានទទួលរងការសម្លុត) និងចំនួន ៧% រាយការណ៍ថាធ្លាប់ប៉ុនប៉ងធ្វើអត្តឃាត (បើធៀបជាមួយនឹងត្រឹមតែ ១,២% នៃអ្នកដែលពុំបានរាយការណ៍ថាបានទទួលរងការសម្លុត និងចំនួន ៣,៦% នៃអ្នកដែលរាយការណ៍ថាធ្លាប់ទទួលរងការសម្លុតដោយសារមូលហេតុមិនមែននិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ)។

## ៤.៣. អឺរ៉ុប

នៅអឺរ៉ុបមានការសិក្សាជាច្រើនផ្តោតលើការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។ ការសិក្សាមួយដែលធ្វើឡើងនៅប្រទេសអៀរឡង់ខាងជើងបានធ្វើការអង្កេតបុរសស្រឡាញ់បុរសចំនួន ១៩០ នាក់ (អាយុពី ១៥ ដល់ ២៥ ឆ្នាំ) និងបានរកឃើញថាពួកគេ ៦៥%ជួបប្រទះនឹងបញ្ហានៅសាលារៀនដោយសារតែនិន្នាការភេទរបស់ពួកគេដោយ ៤៥% រាយការណ៍ថាពួកគទទួលរងការសម្លុត។[36] អ្វីដែលគួរឱ្យព្រួយបារម្ភ ការសិក្សាដដែលនេះ បានរាយការណ៍ថា ក្នុងចំណោមអ្នកដែលរាយការណ៍ថាជួបនឹងបញ្ហា ១៥% ជួបប្រទះនឹងការរើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នាពីសំណាក់បុគ្គលិកសាលារៀននិងចំនួន១០% ពីសំណាក់បុគ្គលិកក្នុសាលារៀនផ្សេងទៀត។ ការសិក្សាក្នុងអឺរ៉ុបទាំងមូលក្នុងឆ្នាំ ២០១២ ដែលមានមនុស្សជាង៩០០០០ នាក់ ដែលចាត់ទុកខ្លួនជាអ្នកស្រឡាញ់ភេទដូចគ្នាបានចូលរួមក្នុងការសិក្សាបានរកឃើញថា អ្នកឆ្លើយសំណួរជាង ៨០% ចាំថាធ្លាប់ឮការនិយាយអវិជ្ជមានឬមើលឃើញទង្វើអវិជ្ជមានដោយសារតែមិត្តរួមថ្នាក់ណាម្នាក់ ត្រូវបានគេចាត់ទុកថាជាអ្នកស្រឡាញ់ភេទដូចគ្នាក្នុងពេលដែលពួកគេរៀននៅសាលារៀនមុនអាយុ ១៨ ឆ្នាំ។[37]

ការសិក្សាមួយទៀតដែលធ្វើសកលវិទ្យាល័យ Sheffield Hallam នៅចក្រភពអង់គ្លេសបានធ្វើឡើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នាមកពីប្រទេសក្រូអាត អៀរឡង់ អ៊ីតាលី ដាណឺម៉ាក និងប៉ូឡូញ បានរកឃើញថាអ្នកស្រឡាញ់ភេទដូចគ្នាចំនួន ៧៣% ទទួលដោយរងការហៅឈ្មោះមិនសមរម្យ ហើយចំនួន ៤៧% ទទួលរងការគំរាមកំហែងនិងការសម្លុត និងមួយភាគបីធ្លាប់មានគំនិតចង់ធ្វើអត្តឃាត ដោយសារតែពួកគេទទួលរងការសម្លុតពេលនៅក្នុងសាលារៀន។[38]

ការសិក្សាមួយទៀតដែលធ្វើឡើងនៅចក្រភពអង់គ្លេសបានរកឃើញថា យុវជនជាអ្នកស្រឡាញ់ភេទដូចគ្នាជាងពាក់កណ្តាលស្មើនឹង ៥៥% ធ្លាប់ទទួលរងការសម្លុតដោយសារតែ

---

36 Helen McNamee "ចេញមកដោយខ្លួនឯង៖ ការពិនិត្យលើសុខភាពផ្លូវចិត្តរបស់បុរសវ័យក្មេងដែលស្រឡាញ់ភេទដូចគ្នា" (របាយការណ៍) (ឆ្នាំ ២០០៦) <http://www.rainbow-project.org/assets/publications/out_on_your_own.pdf>

37 ទីភ្នាក់ងារនៃសហភាពអឺរ៉ុបទទួលបន្ទុកសិទ្ធិជាមូលដ្ឋាន "ការអង្កេតលើបុរសស្រឡាញ់ប្រុស ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ របស់សហភាពអឺរ៉ុប៖ សង្ខេបលទ្ធផល" (របាយការណ៍) (ឆ្នាំ ២០១៣) <http://fra.europa.eu/sites/default/files/eu-lgbt-survey-results-at-a-glance_en.pdf>

38 វិទ្យាស្ថានអប់រំ Sheffield "ឧបសគ្គ និងការសម្លុត៖ បទពិសោធន៍របស់យុវជនដែលជាអ្នកស្រឡាញ់ភេទដូចគ្នា នៅអឺរ៉ុប" (របាយការណ៍) (ឆ្នាំ ២០០៣) <https://www.shu.ac.uk/sioe/case-studies/ceir.html>

និន្នាការភេទឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ ដោយ៦០% នៃក្រុមនេះលើកឡើងថាវាកើតមានឡើងញឹកញាប់ឬញឹកញាប់ខ្លាំង។[39]

## ៤.៤. សហរដ្ឋអាមេរិច

នៅក្នុងឆ្នាំ ២០០៩ ការអង្កេតទូទាំងប្រទេសមួយត្រូវបានធ្វើឡើងដើម្បីវាយតម្លៃលើបទពិសោធន៍របស់អ្នកស្រឡាញ់ភេទដូចគ្នាតាមសាលារៀន។ ការអង្កេតនេះធ្វើឡើងទៅកាន់សិស្សចំនួន ៧២៦១ នាក់ ដែលមានអាយុចាប់ពី ១៣ ដល់ ២១ ឆ្នាំ ដែលជាអ្នកស្រឡាញ់ភេទដូចគ្នា។[40] ការសិក្សានេះបានរកឃើញថាសិស្សចំនួន ៨៩,៦% ទទួលរងការយាយីជាពាក្យសម្តី ដោយសារតែនិន្នាការភេទរបស់ពួកគេ និងចំនួន ៦៣,៧% ទទួលរងការយាយីដោយសារតែការបង្ហាញនូវទំនោរយេនឌ័រ ។ ចំនួន ៤០,១% បានរាយការណ៍ថាទទួលរងការបៀតបៀនផ្លូវកាយ និង ចំនួន ១២,៥% ទទួលរងការវាយប្រហារផ្លូវកាយដោយសារតែការបង្ហាញនូវទំនោរយេនឌ័រ។ ក្នុងចំណោមអ្នកដែលទទួលរងការបៀតបៀនឬការវាយប្រហារ សិស្ស ៦៩,២% ពុំបានរាយការណ៍ពីរឿងនេះទៅកាន់សាលារៀនឡើយដោយពួកគេជឿថាការរាយការណ៍របស់ពួកគេនឹងធ្វើឱ្យស្ថានការណ៍កាន់តែដុនដាបឬនឹងពុំមានការចាត់វិធានការអ្វីឡើយ ហើយ សិស្សចំនួន ៣៣,៨% ដែលមិនបានរាយការណ៍ពីការសម្លុតបាននិយាយថាសាលារៀនពុំបានធ្វើអ្វីឡើយ។ លទ្ធផលនេះ គឺស្រដៀងគ្នាជាមួយនឹងលទ្ធផលនៅប្រទេសថៃដែរ និងបង្ហាញថាការខកខានរបស់សាលារៀនក្នុងការការពារសិស្សពីការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ ពុំទាក់ទងនឹងវប្បធម៌ឡើយ។ អ្នកដែលត្រូវបានគេសម្លុតបានរាយការណ៍ពីអវត្តមាន ការធ្លាក់ទឹកចិត្ត និងការថប់បារម្ភក្នុងកម្រិតខ្ពស់ ជាងអ្នកដែលមិនបានរាយការណ៍ថាធ្លាប់ទទួលរងការសម្លុត។ ការសិក្សាមួយទៀតដែលធ្វើឡើងក្នុងឆ្នាំ ២០០៩ ក្នុងសហរដ្ឋអាមេរិចបានរកឃើញថាសិស្សនិស្សិតដែលជាអ្នកស្រឡាញ់ភេទដូចគ្នាច្រើនតែរាយការណ៍ពីគំនិតចង់ធ្វើអត្តឃាត (មានចំនួន ៣០% បើធៀបជាមួយនឹងនៃសិស្សមិនមែនជាអ្នកស្រឡាញ់ភេទដូចគ្នាមានតែចំនួន៦%) និងការធ្វើបាបដល់ខ្លួនឯង (មានចំនួន ៥% បើធៀបនឹងសិស្សមិនមែនជាអ្នកស្រឡាញ់ភេទដូចគ្នាមានតែ ៣%) ។[41]

---

[39] ស្ថាប័នប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ជាតិ "ក្មេងបុរស ដែលចូលចិត្តក្មេងប្រុស៖ ការសិក្សាពីកន្លែងដែលយុវជនស្រឡាញ់ភេទដូចគ្នាដឹងពីភេទ ទំនាក់ទំនង និងមេរោគអេដស៍" (របាយការណ៍) (ឆ្នាំ ២០១៥) <http://www.nat.org.uk/media/Files/Publications/Boys_Who_Like_Boys.pdf>

[40] GLSEN "ការអង្កេតថ្នាក់ជាតិលើបរិយាកាសតាមសាលារៀន ឆ្នាំ ២០០៩៖ បទពិសោធន៍របស់យុវជន ដែលជាបុរសស្រឡាញ់ប្រុស ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ នៅតាមសាលារៀនក្នុងប្រទេសរបស់យើង" (របាយការណ៍) (ឆ្នាំ ២០០៩)

[41] Joanna Almeida, Renee M. Johnson, Heather L. Corliss, Beth E. Molnar និង Deborah Azrael "វិបត្តិផ្លូវចិត្ត ក្នុងចំណោមយុវជនដែលស្រឡាញ់ភេទដូចគ្នា៖ ឥទ្ធិពលនៃការដឹងពីការរើសអើង ផ្អែកលើនិន្នាការភេទ" (របាយការណ៍) *ព្រឹត្តិបត្រព័ត៌មានអំពីយុវជន និងក្មេងជំទង់* (ខែ សីហា ឆ្នាំ ២០០៩) លេខ ៣៨ ការបោះពុម្ពផ្សាយទី ៧៖ ១០០១-១០១៤

## ៤.៥. ប្រទេសអូស្ត្រាលី

នៅក្នុងឆ្នាំ ២០១០ មានការបោះពុម្ពផ្សាយការសិក្សាទូទាំងប្រទេសមួយដែលធ្វើឡើងក្នុងរយៈពេល១២ ឆ្នាំទាក់ទងនិងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ ។[42] ការសិក្សានេះរួមមានការអង្កេតទៅលើអ្នកដែលស្រឡាញ់ភេទដូចគ្នានិងអ្នកដែលស្គាល់ពីយេនឌ័រខ្លួនឯង (“SSAGQ”) ដែលមានអាយុចាប់ពី ១៤ ដល់ ២១ ឆ្នាំ ចំនួន ៣១៣៤ នាក់។ ការសិក្សានេះបានរកឃើញថាអ្នកឆ្លើយសំណួរចំនួន ៦១% ធ្លាប់ទទួលរងការបំពារបំពានពាក្យសម្ដី និងមានចំនួន ១៨% ធ្លាប់ទទួលរងការបំពារបំពានផ្លូវកាយដោយសារតែការរើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នា។ អ្វីដែលគួរឱ្យចាប់អារម្មណ៍គឺវាហាក់ដូចជាផ្ទុយពីអ្វីដែលកើតមានឡើងក្នុងប្រទេសកម្ពុជា ដែលមានការទទួលស្គាល់ចំពោះបុរសស្រឡាញ់បុរស ជាងស្ត្រីស្រឡាញ់ស្ត្រី ការអង្កេតនេះបានរកឃើញថាអ្នកឆ្លើយសំណួរជាបុរសទទួលរងការរំលោភបំពានជាងអ្នកឆ្លើយសំណួរជាស្ត្រី ដែលនេះអាចពន្យល់បានថាដោយសារតែភាពខុសប្លែកគ្នាខាងផ្នែកវប្បធម៌។ ការសិក្សានេះបានរាយការណ៍ថាក្នុងចំណោមអ្នកដែលទទួលរងការបំពានពាក្យសម្ដីដោយសារតែការរើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នាមានចំនួន ៤០% ដែលគិតចង់ធ្វើបាប់ដល់ខ្លួនឯង ដែលភាគរយនេះមានចំនួនទ្វេរដងបើប្រៀបធៀបទៅភាគរយនៃអ្នកមិនដែលរងការរំលោភបំពាន ហើយចំនួន ៦២% នៃអ្នកដែលទទួលរងការបំពារបំពានផ្លូវកាយ គិតចង់ធ្វើបាបខ្លួនឯង ដែលជាភាគរយនេះមានច្រើនជាងអ្នកដែលមិនបានរាយការណ៍ពីការរំលោភបំពានដល់ទៅចំនួន ៣ ដង។ លើសពីនេះ អ្នកដែលទទួលរងការបំពានជាពាក្យសម្ដីដែលប៉ុនប៉ងធ្វើអត្តឃាតមានចំនួនច្រើនជាងពីដងបើប្រៀបធៀបទៅនឹងភាគរយអ្នកដែលមិនបានទទួលការបំពាន។ សម្រាប់អ្នកដែលបានរាយការណ៍ពីការបំពានផ្លូវកាយតួលេខនេះមានច្រើនជាង ៤,៥ ដង ។ អ្វីដែលគួរចាប់អារម្មណ៍ ពាក់ព័ន្ធនឹងការឆ្លើយតបចំពោះការសម្លុតដោយសារតែការរើសអើងទៅលើអ្នកស្រឡាញ់ភេទដូចគ្នាមានប្រហែលជា ៤០% បាននិយាយប្រាប់គ្រូនិងសុំការគាំទ្រពីគ្រូ ដែលជាការផ្ទុយគ្នាទៅនឹងការសិក្សាស្រាវជ្រាវនានាក្នុងប្រទេសថៃ និងប្រទេសកម្ពុជា ដែលត្រូវបានលើកយកមកបង្ហាញក្នុងរបាយការណ៍នេះ។

ការសិក្សាមួយទៀត ដែលបោះពុម្ពផ្សាយក្នុងខែមីនា ឆ្នាំ ២០១៥ បានបង្ហាញឱ្យឃើញពីការលេចឡើងជាថ្មីនូវការរើសអើងអ្នកស្រឡាញ់ភេទដូចគ្នានៅតាមសាលារៀនក្នុងប្រទេសអូស្ត្រាលី និងបានរកឃើញថាមានកុមារអាយុ ១៤-១៧ ឆ្នាំ ចំនួនមួយភាគបី មានអារម្មណ៍ពុំស្រួលក្នុងចិត្តដែលមានអ្នកស្រឡាញ់ភេទដូចគ្នាក្នុងក្រុមមិត្តរបស់ពួកគេឡើយ ខណៈពេលដែលមានតែ ៩% មានអារម្មណ៍ “ថប់បារម្ភ” ឬ “មិនស្រួលក្នុងចិត្ត” ពេលនៅជិតអ្នកដែលស្រឡាញ់ភេទដូចគ្នា។

[42] Lynne Hillier, Tiffany Jones, Marisa Monagle, Naomi Overton, Luke Gahan, Jennifer Blackman, Anne Micthell “សរសេរខ្លួនឯងជា ៣៖ ការសិក្សាថ្នាក់ជាតិលើកទី ៣ ស្ដីពីសុខភាពផ្លូវភេទ និងសុខុមាលភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នា និងយុវជនដែលនៅមានចម្ងល់ពីយេនឌ័ររបស់ខ្លួន” (របាយការណ៍) (ឆ្នាំ ២០១០) <https://www.latrobe.edu.au/arcshs/downloads/arcshs-research-publications/WTi3.pdf>

មានអ្នកដែលត្រូវបានអង្កេតជាងពាក់កណ្តាលបាននិយាយថាពួកគេបានឃើញផ្ទាល់នឹងភ្នែកថាមនុស្សត្រូវបានគេសម្លុតដោយសារតែនិន្នាការភេទរបស់ពួកគេ។[43] ការសិក្សាក្នុងប្រទេសអូស្ត្រាលីមួយទៀតបានរកឃើញថា អ្នកស្រឡាញ់ភេទដូចគ្នា ២៥% ដែលធ្លាប់ទទួលរងការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រប្រើប្រាស់កញ្ឆាកាលពីឆ្នាំមុន បើធៀបជាមួយនឹងអត្រាជាមធ្យមនៅថ្នាក់ជាតិ ១០% ដែលនេះបង្ហាញថាការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ អាចមានផលប៉ះពាល់លើឥរិយាបថប្រឆាំងសង្គមនៅពេលក្រោយផងដែរ។[44]

[43] "យុទ្ធនាការធំ ដែលមានគោលបំណងលុបបំបាត់ការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នា" សារព័ត៌មាន *Beyond Blue* (៣១ មីនា ២០១៥)។ អាចរកបានតាមរយៈ: <https://www.beyondblue.org.au/about-us/news/news/2015/03/30/major-campaign-aims-to-stamp-out-discrimination-against-lgbti-people>

[44] William Leonard, Anthony Lyons និង Emily Bariola "ការពិនិត្យស៊ីជម្រៅលើជីវិតឯកជន ២៖ ការឆ្លើយតបនឹងបញ្ហាសុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ (LGBT) នៅអូស្ត្រាលី" (របាយការណ៍) (ឆ្នាំ ២០១៥)។ អាចរកបានតាមរយៈ: <http://glhv.org.au/files/Closer_Look_Private_Lives2.pdf>

# ៥. របកគំហើញ

ការវិភាគលើទិន្នន័យដែលគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័ររបស់ ម.ស.ម.ក ប្រមូលបានបានបង្ហាញឱ្យឃើញថាការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រកើតមានជាទូទៅតាមសាលារៀនទូទាំងប្រទេសកម្ពុជា ហើយបង្ករអោយមានផលប៉ះពាល់លើជីវិតរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាពេញមួយជីវិតរបស់ពួកគេ។ ការរើសអើងតាមសាលារៀនភាគច្រើនកើតមានឡើងក្នុងទម្រង់ជាពាក្យសម្តី ការបៀតបៀនផ្លូវកាយ និងការបៀតបៀនផ្លូវភេទ ការរើសអើងចេញពីគ្រូបង្រៀននិងការផាត់ចេញពីសង្គម ពីសំណាក់មិត្តរួមថ្នាក់ដោយសារតែនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។

តាមរយៈការវិភាគទៅលើលទ្ធផលនៃការស្រាវជ្រាវនេះ ក៏ដូចជាការចុះប្រមូលព័ត៌មាននិងការអង្កេត គម្រោងបានរកឃើញថាស្ថានភាពដែលសិស្សនិស្សិតជាអ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាជួបប្រទះ បញ្ហាស្រដៀងគ្នានឹងអ្វីដែលអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងប្រទេសផ្សេងទៀតក្នុងតំបន់និងជុំវិញពិភពលោកជួបប្រទះដែរ។

## ៥.១. ប្រេវ៉ាឡង់ និងទម្រង់នៃការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រតាមសាលារៀន

ក្រោយពីបានធ្វើការអង្កេតក្នុងដំណាក់កាលទីមួយរួច ក្រុមការងារគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័របានកត់សម្គាល់ឃើញថាពាក្យពេចន៍ក្នុងសំណួរក្នុងការអង្កេតនេះ ត្រូវបានសរសេរតាមបែបផែនមួយដែលសន្មត់ទុកជាមុនថា និន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់បុគ្គល គឺជាមូលហេតុដែលនាំឱ្យពួកគេទទួលរងការសម្លុត។ បន្ទាប់ពីបានកត់សម្គាល់ឃើញចំណុចខ្វះខាតនេះ និងដោយទទួលស្គាល់ថាមានមូលហេតុជាច្រើន ដែលនាំឱ្យអ្នកស្រឡាញ់ភេទដូចគ្នាទទួលរងការសម្លុត ក្រុមការងារបានរៀបចំសំណួរឡើងវិញ ដើម្បីបង្កើនគុណភាពនៃការស្រាវជ្រាវនេះ។ បើតាមការអង្កេតក្នុងដំណាក់កាលទីពីរដែលទទួលបានពីការចុះប្រមូលព័ត៌មានលើកទី ២ និងលើកទី ៣ ក៏ដូចជាលទ្ធផលពីការចុះប្រមូលព័ត៌មានលើកទី ១ ក្នុងរាជធានីភ្នំពេញមានអ្នកឆ្លើយសំណួរចំនួន ៦២,៧១% ទទួលរងការសម្លុតនៅពេលណាមួយពេលដែលពួកគេរៀននៅសាលារៀន។ នៅពេលស្នើឱ្យធ្វើការបកស្រាយបន្ថែមអ្នកចូលរួមចំនួន ៩៣,៥៩% ដែលបានទទួលរងការសម្លុតគិតថាមូលហេតុមួយផ្នែកឬមូលហេតុទាំងស្រុង ដែលនាំឱ្យមានការសម្លុតគឺដោយសារនិន្នាការភេទឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ លទ្ធផលទាំងនេះបង្ហាញថា អ្នកចូលរួមស្ទើរតែទាំងអស់ ដែលអះអាងថាខ្លួន ធ្លាប់ទទួលរងការសម្លុតក្នុងសាលារៀន

ក្នុងការអង្កេតនេះគិតថា ពួកគេទទួលរងការសម្លុតដោយសារតែនិន្នាការភេទឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។

ក្នុងចំណោមអ្នកដែលរាយការណ៍ថា ទទួលរងការសម្លុត នៅសាលារៀន ៤២,២% បាននិយាយថាពួកគេទទួលរងការសម្លុត "ជាញឹកញាប់" ឬ "ជារៀងរាល់ថ្ងៃ"។ អ្នកចូលរួមភាគច្រើនពោលគឺ ៥៣,៨៥% បាននិយាយថា ពួកគេទទួលរងការសម្លុត "នៅពេលខ្លះ"។ អ្វីដែលគួរឱ្យព្រួយបារម្ភ មានអ្នកចូលរួមតែ ៥,១២% ប៉ុណ្ណោះ ដែលរាយការណ៍ថា "មិនធ្លាប់" ទទួលរងការសម្លុតនៅសាលារៀន ឬ "កម្រ" ទទួលរងការសម្លុត។ ទិន្នន័យនេះបង្ហាញភស្តុតាងថា ការសម្លុត ពាក់ព័ន្ធនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ មានប្រេវ៉ាឡង់ តាមសាលារៀនកម្ពុជា។

ដូចដែលឃើញក្នុងក្រាហ្វខាងក្រោម នៅពេលសួរពីទម្រង់នៃការសម្លុត ដែលត្រូវបានគេប្រើប្រាស់ មានអ្នកចូលរួមច្រើនលើសលុបរហូតដល់ចំនួន ៨៤,៤៦% បាននិយាយថា ពួកគេទទួលរងការសម្លុតជាពាក្យសម្តីដែលជាទម្រង់នៃការសម្លុត ដែលមានប្រេវ៉ាឡង់ខ្ពស់ជាងគេ។ ការសម្លុតប្រភេទទី ២ ដែលកើនកើតមានច្រើនជាងគេ គឺការផាត់ចេញពីសង្គម ដោយអ្នកចូលរួមក្នុងការអង្កេតមានចំនួន ៤៦,១៥% បាននិយាយថា ពួកគេជួបប្រទះនឹងការសម្លុតប្រភេទនេះ។ ការសម្លុតផ្លូវកាយ និងផ្លូវភេទ បើទោះបីជាប្រភេទនៃការសម្លុត ដែលត្រូវបានរាយការណ៍ថាបានកើតមានតិចតួចជាងគេក៏ដោយ អ្នកចូលរួមដែលរាយការណ៍ថាទទួលរងការសម្លុតប្រភេទនេះមានចំនួនច្រើនគួរឱ្យព្រួយបារម្ភ។ ការសម្លុតផ្លូវកាយ ដូចជា ការរុញ ការវាយ ការស្តោះទឹកមាត់ដាក់ អំពើហិង្សា ការចាក់សោរក្នុងបន្ទប់ទឹក និងការលួចគ្រឿងសម្ភារជាដើមត្រូវបានរាយការណ៍ដោយអ្នកចូលរួមមានចំនួន ៣៩,៧៤%។ ជាការពិត ចំនួនអ្នកដែលរាយការណ៍ថាទទួលរងការសម្លុតផ្លូវកាយក្នុងការសិក្សានេះ មានលើសពីចំនួនអ្នកចូលរួមដែលបានរាយការណ៍ពីការសម្លុតផ្លូវកាយ នៅក្នុងការសិក្សាដែលសកលវិទ្យាល័យមាហីដុលនៅទីក្រុងបាងកកធ្វើឡើង មានចំនួន ៣១%។[45] ការសម្លុតខាងផ្លូវភេទដូចជា ជនរងគ្រោះត្រូវបានគេបង្ខំឱ្យស្រាតខោ ឬសំពត់ ធ្វើគ្រាប់តាមការបំពានផ្លូវភេទឬទទួលរងការបំពានផ្លូវភេទជាក់ស្តែងតែម្តងនិងការស្ទាបអង្អែលត្រូវបានលើកឡើងដោយអ្នកចូលរួមចំនួនមួយភាគបី។ ព័ត៌មាននេះធ្វើឱ្យគេយល់កាន់តែច្បាស់ពីបរិយាកាសដែលអ្នកស្រឡាញ់ភេទដូចគ្នាទទួលរងពេលដែលពួកគេនៅរៀន។ ខណៈពេលដែលពួកគេភាគច្រើនប្រឈមនឹងការបំពានជាពាក្យសម្តី មានអ្នកចូលរួមមួយភាគធំទៀតក៏ទទួលរង នូវការសម្លុតក្នុងទម្រង់ផ្សេងទៀតផងដែរ។

---

45 សូមមើលការសិក្សា ដែលធ្វើឡើងដោយសកលវិទ្យាល័យ Mahidol ទីក្រុងបាងកក ក្នុងផ្នែក ៤.២ នៃរបាយការណ៍នេះ។




ការស្វែងយល់ស៊ីជម្រៅអំពីការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រតាមសាលារៀនក្នុងប្រទេសកម្ពុជា ត្រូវបានផ្តល់ដោយស្ត្រីប្លូរភេទម្នាក់នៅរាជធានីភ្នំពេញ ដែលមានឈ្មោះហៅក្រៅថា កូឡាប។ គាត់បានពន្យល់ពីស្ថានភាពរបស់គាត់ពេលនៅរៀន ប្រាប់ក្រុមការងារនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រក្នុងកំឡុងពេលចុះប្រមូលទិន្នន័យថា៖

*"...ខ្ញុំមានបទពិសោធន៍ជាច្រើន ពាក់ព័ន្ធជាមួយនឹងការសម្លុតយុវជនក្នុងសាលារៀន។ បញ្ហាមានច្រើនដូចជាការហៅឈ្មោះ ការប្រមាថ ការស្រែកដាក់ និងការផាត់ចេញពីក្រុមយុវជន ដោយសារតែពួកគេរើសអើងចំពោះស្រីស្រស់ (អ្នកប្លូភេទ) ដូចជារូបខ្ញុំ។ ពួកគេតែងរុញខ្ញុំ និងស្ទាបអង្អែលខ្លួនខ្ញុំ ជាដើម..."។*

នៅក្នុងការអង្កេតដំណាក់កាលទីពីរ អ្នកចូលរួមត្រូវបានស្នើឱ្យធ្វើការរៀបរាប់ពីការកើតឡើងនូវការសម្លុតក្នុងទម្រង់នីមួយៗថា "រៀងរាល់ថ្ងៃ" "ជាញឹកញាប់" ពេលខ្លះ" "កម្រកើតឡើង" "មិនដែលកើតឡើង" និង "មិនចង់និយាយ"។ នេះរួមមានការសម្លុតផ្លូវកាយ នៅសាលារៀន និងក្រៅសាលារៀន ការសម្លុតផ្លូវភេទនៅសាលារៀន និងក្រៅសាលារៀន ការសម្លុតជាពាក្យសម្តីនៅសាលារៀន និងក្រៅសាលារៀន និងការផាត់ចេញមិនឱ្យចូលរួមពីសំណាក់មិត្តភក្តិនៅសាលារៀន និងក្រៅសាលារៀន។ គោលបំណងនៃការប្រមូលទិន្នន័យអំពីការសម្លុត ពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រទាំងក្នុងទាំងក្រៅសាលារៀនគឺដើម្បីវាយតម្លៃថាតើបរិយាកាសក្នុងសាលារៀនមានលក្ខណៈរើសអើងច្រើនជាងឬតិចជាងខាងក្រៅសាលារៀន

ដែលអាចឱ្យគេទាញជាសេចក្តីសន្និដ្ឋានឱ្យបានសមស្របអំពីតួនាទីរបស់សាលារៀននៅកម្ពុជា ក្នុងការរើសអើង ពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។

លទ្ធផលដែលទទួលបានពីសំណួរទាំងនេះបានផ្តល់នូវលទ្ធផលគួរឱ្យចាប់អារម្មណ៍ហើយ សង្ឃឹមថានឹងផ្តល់នូវមូលដ្ឋានដ៏មានប្រយោជន៍ដើម្បីលើកទឹកចិត្តឱ្យមានការស្រាវជ្រាវថែមទៀត។ ក្នុងចំណោមអ្នកដែលទទួលរងការសម្លុតផ្លូវកាយនៅសាលារៀនចំនួន ៧៣,០៨% បាននិយាយថា ពួកគេទទួលរងការសម្លុតបែបនេះ "ពេលខ្លះ" "ជាញឹកញយ" ឬ "ជារៀងរាល់ថ្ងៃ"។ នៅខាងក្រៅ បរិយាកាសសាលារៀនវិញ តួលេខនេះរៀងតិចជាងបន្តិចដោយអ្នកចូលរួមចំនួន ៦២,៨២% ទទួល រងការសម្លុតខាងផ្លូវកាយ "ពេលខ្លះ" "ជាញឹកញាប់" ឬ "ជារៀងរាល់ថ្ងៃ"។ លើសពីនេះ ការសម្លុតជា ពាក្យសម្តីក៏កើតមានក្នុងសាលារៀនជាងខាងក្រៅសាលារៀនផងដែរ ដោយអ្នកចូលរួម ៩២,៣១% រាយការណ៍ថាកើតមាន"ពេលខ្លះ" "ជាញឹកញាប់" ឬ "ជារៀងរាល់ថ្ងៃ" ក្នុងសាលារៀន បើធៀប ជាមួយនឹង ៨៣,៣៣% ខាងក្រៅសាលារៀន។ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យដូចគ្នានេះ តួលេខ បង្ហាញពីការផាត់ចេញពីសង្គមគឺស្រដៀងគ្នាសម្រាប់ករណីក្នុងសាលារៀនមានចំនួន ៦៤,១% និង ក្រៅសាលារៀនមានចំនួន ៦២,៨៣%។ ក្នុងចំណោមអ្នកចូលរួមដែលបានរាយការណ៍ថាបាន ទទួលរងការសម្លុតខាងផ្លូវភេទចំនួន ៤៨,៧២% បានលើកឡើងថាបញ្ហានេះបានកើតឡើងក្នុង សាលារៀន "ពេលខ្លះ" "ជាញឹកញាប់" ឬ "ជារៀងរាល់ថ្ងៃ"។ ការសម្លុតខាងផ្លូវភេទគឺជាទម្រង់តែ មួយគត់នៃការសម្លុតដែលមានប្រេវ៉ាឡង់ខ្ពស់ជាងនៅខាងក្រៅសាលារៀន ដោយអ្នកចូលរួមចំនួន ៥៥,១១% គឺជាជនរងគ្រោះដោយសារការសម្លុតផ្លូវភេទខាងក្រៅសាលារៀន "ពេលខ្លះ" "ជាញឹក ញាប់" ឬ "ជារៀងរាល់ថ្ងៃ" ។ លទ្ធផល ពាក់ព័ន្ធជាមួយនឹងការសម្លុតខាងផ្លូវកាយ និងការសម្លុតជា ពាក្យសម្តី អាចមើលឃើញ ក្នុងក្រាហ្វខាងក្រោម ៖


តើការសម្លុតធ្វើបាបកើតឡើងញឹកញាប់កម្រិតណាក្នុងអំឡុងពេល
អ្នកសិក្សានៅសាលារៀន
ការរំលោភបំពានឬ អំពើហឹង្សាលើរាងកាយនៅសាលារៀន
៨.៩៧%
២៣.០៨%
៤១.០៣%
៦.៤១%
២០.៥១%
ការរំលោភបំពានឬ អំពើហឹង្សាលើរាងកាយនៅក្រៅសាលារៀន
៨.៩៧%
១៩.២៣%
៣៤.៦២%
១១.៥៤%
២៤.៣៦%
១.២៨%
ជារៀងរាល់ថ្ងៃ
ញឹកញាប់
ម្តងម្កាល
កម្រ
មិនធ្លាប់
មិនចង់បង្ហាញ




ទិន្នន័យខាងលើអាចទាញចេញនូវសេចក្តីសន្និដ្ឋានចំនួនពីរ។ ទី ១ ទិន្នន័យនេះបានបង្ហាញឱ្យឃើញថាមិនត្រឹមតែថាការសម្លុតពាក់ព័ន្ធជាមួយនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រលេចចេញក្នុងទម្រង់ផ្សេងៗគ្នាប៉ុណ្ណោះទេ ប៉ុន្តែវាក៏បង្ហាញផងដែរថាអ្នកដែលទទួលរងការសម្លុតដោយសារតែនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់ពួកគេទទួលរងការសម្លុតប្រភេទនេះជាប្រចាំ ដោយអ្នកចូលរួមភាគច្រើនដែលទទួលរងការសម្លុត "ពេលខ្លះ" "ជាញឹកញាប់" ឬ "រៀងរាល់ថ្ងៃ"។ ទីពីរ របកគំហើញនេះផ្តល់នូវភស្តុតាងបង្ហាញថា ការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់ពួកគេច្រើនកើតមានក្នុងបរិយាកាសសាលារៀនជាងខាងក្រៅសាលារៀន ដូច្នេះទិន្នន័យនេះគឺជាមូលដ្ឋានភស្តុតាងរឹងមាំថាសាលារៀននៅកម្ពុជាពុំបានផ្តល់នូវសុវត្ថិភាពដល់អ្នកស្រឡាញ់ភេទដូចគ្នាឡើយ ហើយថែមទាំងអាចរួមចំណែកធ្វើឱ្យមានការសម្លុតដល់សិស្សទៀតផង។

បើទោះបីជាការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រមានប្រេវ៉ាឡង់ខ្ពស់នៅខាងក្នុងសាលារៀនក៏ដោយ គេមិនអាចមើលរំលងការលំបាកជាច្រើនដែលអ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះនៅខាងក្រៅសាលារៀនឡើយ។ ជាការពិត របាយការណ៍នេះបានបង្ហាញរួចហើយពីសម្ពាធសង្គមដែលយុវជនជាអ្នកស្រឡាញ់ភេទដូចគ្នាទទួលរងក្នុងផ្នែក ៣.៣ ខាងលើ។ ការអង្កេតទាំងពីរដំណាក់កាលបានខិតខំស្វែងរកព័ត៌មានពីអ្នកចូលរួមថាតើអ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានសហគមន៍របស់ពួកគេទទួលស្គាល់ក្នុងកម្រិតណា ពេលដែលពួកគេនៅរៀនក្នុងសាលា។

អ្នកចូលរួមភាគច្រើនមានចំនួន ៩១,៣៩% បានឆ្លើយថាសហគមន៍របស់ពួកគេ "ទទួលស្គាល់ជាធម្មតា" នូវអ្នកស្រឡាញ់ភេទដូចគ្នា ។ លើសពីនេះ អ្នកចូលរួមក្នុងការអង្កេតចំនួន ៨,៩២% ឆ្លើយដោយលើកឡើងថាសហគមន៍របស់ពួកគេ "ទទួលយកអ្នកស្រឡាញ់ភេទដូចគ្នាក្នុងកម្រិតខ្ពស់"។ ខណៈពេលដែលលទ្ធផលទាំងនេះមានលក្ខណៈវិជ្ជមាន ទិន្នន័យនេះក៏បង្ហាញផងដែរថា មានអ្នកឆ្លើយសំណួរជាងមួយភាគបួនស្មើនឹង ២៧,០៥% ចាត់ទុកសហគមន៍ក្នុងសាលារៀនរបស់ពួកគេថា "មិនអាចទទួលយកបានទាំងស្រុង" ហើយ ២៤,១៨% ចាត់ទុកសហគមន៍របស់ពួកគេ"មិនទទួលយក"[46] ដែលបង្ហាញថា អ្នកស្រឡាញ់ភេទដូចគ្នាជួបនឹងការលំបាកច្រើន ដើម្បីធ្វើសមាហរណកម្មខ្លួនចូលទៅក្នុងសហគមន៍របស់ពួកគេ។

បន្ថែមពីលើការសម្លុតលើរាងកាយ និងក្នុងសង្គមយុវជនដែលជាអ្នកស្រឡាញ់ភេទដូចគ្នាក៏ប្រឈមនឹងការសម្លុតតាមប្រព័ន្ធអ៊ិនធើណែត ឬទូរសព្ទ ក្នុងកំឡុងពេលដែលពួកគេនៅរៀន បើទោះបីជាការសម្លុតក្នុងទម្រង់បែបនេះ មានប្រេវ៉ាឡង់ទាបក្នុងចំណោមសិស្សនៅកម្ពុជា ដោយសារតែកង្វះលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ប្រជាពលរដ្ឋ ដែលមានការលំបាកផ្នែកសង្គម សេដ្ឋកិច្ច និងអ្នករស់នៅតំបន់ជនបទក៏ដោយ។ នៅពេលសាកសួរថាតើអ្នកចូលរួមធ្លាប់ទទួលរងការសម្លុតតាមប្រព័ន្ធអ៊ិនធើណែតក្នុងឆ្នាំដែលពួកគេនៅរៀនដែរឬទេ ៥៧,១៤% នៃអ្នកដែលបានរាយការណ៍ថាបានទទួលរងការសម្លុតបាននិយាយថាពួកគេពុំទាន់អាចប្រើប្រាស់ប្រព័ន្ធអ៊ិនធើណែតនៅពេលនោះនៅឡើយទេ។ ក្នុងចំណោមអ្នកចូលរួមចំនួន ៣១ នាក់ ដែលអាចប្រើប្រាស់ប្រព័ន្ធអ៊ិនធើណែតបាន មាន ២៧ នាក់ ស្មើនឹងចំនួន ៣៥,០៦% បាននិយាយថា ពួកគេពុំបានទទួលការសម្លុតតាមប្រព័ន្ធអនឡាញឡើយ ហើយ ៦ នាក់ ស្មើនឹងចំនួន ៧,៨% បាននិយាយថាពួកគេទទួលរងការសម្លុតតាមប្រព័ន្ធអ៊ិនធើណែត។

ស្រដៀងគ្នានឹងការសម្លុតតាមប្រព័ន្ធអ៊ិនធើណែតដែរ ក្នុងចំណោមអ្នកចូលរួមដែលធ្លាប់ទទួលរងការសម្លុតមានចំនួន ៣២,០៥% បាននិយាយថា ពួកគេពុំមានទូរសព្ទប្រើ កាលពីពេលនៅរៀនឡើយ។ ក្នុងចំណោមអ្នកដែលមានទូរស័ព្ទប្រើចំនួន ៥៥,១៣% និយាយថាពួកគេពុំបានទទួល

[46] អ្នកចូលរួម ៤ នាក់ ស្មើនឹង៣,២% ឆ្លើយថា "មិនដឹង/មិនចាំ" ចំពោះសំណួរនេះ។

រងការសម្លុតតាមទូរសព្ទពេលនៅរៀនឡើយ ហើយចំនួន ១២,៨៣% បាននិយាយថាពួកគេបានទទួលរងការសម្លុតតាមទូរសព្ទ។

ការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រគឺជាអ្វីដែលតែងកើតមានឡើងតាមសាលារៀនក្នុងប្រទេសកម្ពុជា ហើយការពន្យល់មួយអំពីប្រវាឡង់បែបនេះអាចដោយសារតែមានការយល់ឃើញចំពោះអ្នកស្រឡាញ់ភេទដូចគ្នាជាអវិជ្ជមាន។ តាមការអង្កេតដំណាក់កាលទី ១ និងដំណាក់កាលទី ២ សុទ្ធតែខិតខំបង្កើតនូវទិន្នន័យពាក់ព័ន្ធនឹងចំណុចនេះ។ ប៉ុន្តែ ការអង្កេតដំណាក់កាលទី ១ និងទី ២ ខុសគ្នាតិចតួច ពាក់ព័ន្ធនឹងរបៀបសួរសំណួរពាក់ព័ន្ធនេះ។ នៅក្នុងការអង្កេតដំណាក់កាលទី ១ អ្នកចូលរួម ត្រូវបានសួរសំណួរទូទៅថាតើពួកគេធ្លាប់ឮសារវិជ្ជមាន និងអវិជ្ជមានអំពីអ្នកស្រឡាញ់ភេទដូចគ្នាដែរឬទេ ហើយជម្រើសដែលមាន មានដូចជា "បាទ/ចាស" "ទេ" ឬ "មិនដឹង"។ នៅក្នុងការអង្កេតដំណាក់កាលទី ២ អ្នកចូលរួមត្រូវបានសួរជាក់លាក់ ថាតើពួកគេធ្លាប់ឮសារវិជ្ជមានឬអវិជ្ជមាននៅសាលារៀនដែរឬទេ ដោយជម្រើសមានដូចជា"ភាគច្រើនវិជ្ជមាន" "ភាគច្រើនអវិជ្ជមាន" និង "ប្រហាក់ប្រហែលគ្នា សម្រាប់សារនីមួយៗ"។ ចេញពីការចុះប្រមូលព័ត៌មានលើកទី ១ អ្នកចូលរួមចំនួន ៩២,៩៥% បានរាយការណ៍ថាធ្លាប់ឮសារអវិជ្ជមានអំពីការដែលពួកគេជាអ្នកស្រឡាញ់ភេទដូចគ្នា ប៉ុន្តែ ចំនួន ៧៨,១៥% នៃអ្នកដែលបានចូលរួមក្នុងការអង្កេតនេះ ក៏បានរាយការណ៍ថាបានឮសារវិជ្ជមានអំពីការដែលពួកគេជាអ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។ នេះបង្ហាញថា ខណៈពេលដែលអ្នកចូលរួមស្ទើរតែទាំងអស់ក្នុងពេលចុះប្រមូលព័ត៌មានលើកទី១ ធ្លាប់ទទួលបានសារអវិជ្ជមានអំពីការដែលពួកគេជាអ្នកស្រឡាញ់ភេទដូចគ្នា ពួកគេភាគច្រើនក៏ទទួលបានសារវិជ្ជមានផងដែរ ដែលជាសញ្ញាប្រសើរមួយ។

នៅក្នុងការអង្កេតដំណាក់កាលទី ២ ការឆ្លើយតបចំនួន ៥៥,២៥% ឆ្លើយថា "មានលក្ខណៈប្រហាក់ប្រហែលគ្នា" ។ អ្នកឆ្លើយតបចំនួន ៩២,០៦% បានរាយការណ៍ថា ធ្លាប់ឮ "សារអវិជ្ជមានភាគច្រើន" ហើយមានតែ ១២,៧០% ប៉ុណ្ណោះ ដែលឮសារ "មានលក្ខណៈវិជ្ជមាន"។ ទិន្នន័យដែលទទួលបានពីការអង្កេតដំណាក់កាលទី ២ បង្ហាញថាសាលារៀននៅកម្ពុជា អាចផ្តល់នូវបរិបទមួយដែលបង្កលក្ខណៈឱ្យមានការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រតាមរយៈការបង្កភាពងាយស្រួលឱ្យមានការបញ្ជូនសារអវិជ្ជមានអំពីអ្នកស្រឡាញ់ភេទដូចគ្នា។

អ្នកចូលរួមក៏ត្រូវបានសួរផងដែរថាតើអ្នកណាដែលទទួលខុសត្រូវនាំឱ្យមានការសម្លុត ពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ ដែលពួកគេទទួលរង។ ការឆ្លើយតបរបស់ពួកគេ ត្រូវបានបង្ហាញក្នុងក្រាហ្វខាងក្រោម៖




ដូចដែលបានឃើញក្នុងរូបភាពខាងលើ អ្នកចូលរួមក្នុងចំនួនលើសលុបពោលគឺមានចំនួន ៦៧,៩៥% បានលើកឡើងថា ពួកគេត្រូវបានសម្លុតភាគច្រើនពីសំណាក់សិស្សប្រុសដែលធ្វើឱ្យករណីបែបនេះក្លាយជាប្រភពនៃការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រដែលត្រូវបានលើកឡើងញឹកញាប់ជាងគេ។ អ្វីដែលគួរឱ្យកត់សម្គាល់ផងដែរនោះគឺអ្នកចូលរួម ១ ភាគ ៦ បានរាយការណ៍ថាពួកគេត្រូវបានសម្លុតពីសំណាក់គ្រូបង្រៀនដែលផ្តល់នូវភស្តុតាងបង្ហាញពីភាពពាក់ព័ន្ធផ្ទាល់របស់សាលារៀនក្នុងករណីការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រមួយចំនួន។ អ្វីដែលគួរឱ្យកត់សម្គាល់ផងដែរគឺថា អ្នកចូលរួមជាង ១ ភាគ ៥ ធ្លាប់ទទួលរងការសម្លុតពីនគរបាល។ នេះគឺជាស្ថិតិគួរឱ្យមានការព្រួយបារម្ភជាខ្លាំង និងផ្តល់នូវភស្តុតាងបង្ហាញថាស្ថាប័នរបស់រដ្ឋគឺជាអ្នកដែលទទួលខុសត្រូវផ្ទាល់លើការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។

នៅក្នុងការសម្ភាសមួយទល់មួយជាលក្ខណៈសម្ងាត់ជាមួយអ្នកចូលរួមដែលធ្វើឡើងដោយក្រុមការងារគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ អ្នកឆ្លើយតបសម្ភាសន៍ជាច្រើននាក់បានរៀបរាប់លំអិតអំពីការសម្លុតដែលពួកគេទទួលរងពីសំណាក់គ្រូរបស់ពួកគេ។ បុរសប្តូរភេទ

(ស្ត្រីតែងខ្លួនជាបុរស) ម្នាក់អាយុ ១៩ ឆ្នាំ មកពីខេត្តកំពង់ឆ្នាំង ដែលមានឈ្មោះហៅក្រៅថា ស្រស់ បាននិយាយ ក្នុងការសម្ភាស ថា៖

*"ខ្ញុំពិតជាមានការអាក់អន់ចិត្ត ជាមួយនឹងគ្រូរបស់ខ្ញុំ។ ជាទូទៅ សិស្សប្រុស និងសិស្សស្រីមិនបានទទួលទណ្ឌកម្មពីគ្រូនោះទេ ប៉ុន្តែខ្ញុំទទួលរងទណ្ឌកម្ម បើទោះបីជាខ្ញុំរៀនពូកែ ឬជាសិស្សឆ្លាតក្នុងថ្នាក់ក៏ដោយ។ គ្រូរបស់ខ្ញុំតែងជេរ ឬស្តីឱ្យខ្ញុំ។ ក្នុងនាមជាបុរសប្តូរភេទខ្ញុំពុំមានភាពកក់ក្តៅក្នុងសាលារៀនរបស់ខ្ញុំឡើយ។ ខ្ញុំមិនសូវទទួលរងការរើសអើងច្រើនពីមិត្តភក្តិរបស់ខ្ញុំឡើយ ប៉ុន្តែគ្រូរបស់ខ្ញុំតែងសម្លុតខ្ញុំ។"*

នៅក្នុងការសម្ភាសដ៏កម្រមួយជាមួយនឹងបុរសស្រឡាញ់បុរសម្នាក់ជាខ្មែរឥស្លាម ឈ្មោះហៅក្រៅថា តុំ គាត់បានរំឭកពីផលប៉ះពាល់ ដែលសហគមន៍ឥស្លាមមានមកលើសិស្ស និងគ្រូជាអ្នកស្រឡាញ់ភេទដូចគ្នា ពេលនៅរៀន៖

*"នៅក្នុងគ្រួសាររបស់ខ្ញុំ សហគមន៍កាន់សាសនាឥស្លាមមិនទទួលស្គាល់អ្នកស្រឡាញ់ភេទដូចគ្នាឡើយ។ ប្រសិនបើគេដឹងថាអ្នកជាអ្នកស្រឡាញ់ភេទដូចគ្នា ជាសាធារណៈ អ្នកត្រូវតែរស់នៅខាងក្រៅសហគមន៍ឥស្លាម។ គ្រូឥស្លាមក៏ជាក្តីបារម្ភរបស់ខ្ញុំដែរ ពេលដែលខ្ញុំនៅរៀន ដោយសារតែពួកគាត់មិនទទួលសិស្ស ដែលជាអ្នកស្រឡាញ់ភេទដូចគ្នាឡើយ។ ពួកគេប្រាប់ឱ្យយើងធ្វើជា "បុរស ឬស្ត្រីពិតប្រាកដ" ហើយប្រសិនបើអ្នកស្រឡាញ់ភេទដូចគ្នាបង្ហាញខ្លួនក្នុងថ្នាក់រៀន ពួកគេនឹងត្រូវបណ្តេញចេញពីថ្នាក់។*

យើងបានឮពីបុរសប្តូរភេទម្នាក់(ស្ត្រីតែងខ្លួនជាបុរស)ម្នាក់ក្នុងរាជធានីភ្នំពេញ ដែលមានឈ្មោះហៅក្រៅចេកឃី ដែលបច្ចុប្បន្នកំពុងរៀនថ្នាក់បរិញ្ញាបត្រក្នុងរាជធានីភ្នំពេញ គាត់បាននិយាយថា ៖

*"ខ្ញុំបានលើកពីបញ្ហានេះ ជាមួយនឹងគ្រូរបស់ខ្ញុំ ពាក់ព័ន្ធជាមួយការនិយាយសម្តីមិនសមរម្យរបស់គាត់។ គ្រូរបស់ខ្ញុំនិយាយថា "ឯងខុសគ្នាស្រលះពីសិស្សផ្សេងទៀតក្នុងថ្នាក់នេះ។ ឯងមិនមែនជាមនុស្សប្រុសនោះទេ សូមធ្វើខ្លួនឱ្យដូចស្រីពិតប្រាកដ"។*

ដោយសារតែបញ្ហានេះតែងកើតមានឡើង ចេកឃីបានស្នើឱ្យសាលាជួយដោះស្រាយបញ្ហានេះ ប៉ុន្តែគាត់ពុំបានទទួលដំណោះស្រាយអ្វីឡើយ។

បន្ថែមពីលើការសម្លុតក្នុងទម្រង់ផ្សេងទៀត ការអង្កេតនេះបានសួរអ្នកចូលរួមថាតើគ្រូបានពង្រឹងការស្លៀកពាក់ឯកសណ្ឋាន ឬស្តង់ដានៃការរៀបចំខ្លួន ដែលពួកគេពុំមានភាពងាយស្រួលជាមួយដែរឬទេ។ ឯកសណ្ឋានសាលារៀនគឺជាអ្វីដែលសិស្សទាំងអស់ត្រូវតែគោរពតាម។ សិស្សប្រុសស្លៀកខោខៀវ ហើយសិស្សស្រីត្រូវស្លៀកសំពត់ខៀវ។[47] ក្រុមការងារគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័របានទទួលស្គាល់ថាស្តង់ដានៃការរៀបចំខ្លួនដែលត្រូវតែគោរពតាមបែប

[47] កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ "ការធ្វើជាអ្នកស្រឡាញ់ភេទដូចគ្នា នៅអាស៊ីៈ របាយការណ៍ សម្រាប់ប្រទេសកម្ពុជា - ទំព័រ៨១

នេះ ទំនងជាធ្វើឱ្យសិស្សដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសអ្នកដែលមានអត្តសញ្ញាណយេនឌ័រ ខុសពីភេទកំណើតរបស់ពួកគេ មានអារម្មណ៍មិនងាយស្រួល។

ការអង្កេតទាំងពីរដំណាក់កាល បានរកឃើញថាមានអ្នកចូលរួមជាង ១ ភាគ ៤ ស្មើនឹង ២៦,៨៩% បាននិយាយថាគ្រូរបស់ពួកគេពិតជាបានអនុវត្តស្តង់ដាឯកសណ្ឋាន ដែលធ្វើឱ្យពួកគេមានអារម្មណ៍មិនងាយស្រួលនោះឡើយ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺ អ្នកប្តូរភេទចំនួន ៩០.៤៨ ដែលបានចូលរួមក្នុងការអង្កេតមានអារម្មណ៍មិនស្រួលក្នុងចិត្តចំពោះការបង្ខំឱ្យស្លៀកពាក់ឯកសណ្ឋាន។ នេះបង្ហាញថាសិស្សដែលជាអ្នកប្តូរភេទទទួលរងផលប៉ះពាល់លើសលុប ដោយសារតែស្តង់ដាឯកសណ្ឋាន បើធៀបជាមួយនឹងក្រុមអ្នកស្រឡាញ់ភេទដូចគ្នាតូចៗផ្សេងទៀត។

ស្រីស្រស់ (បុរសតែងខ្លួនជាស្រី) ម្នាក់មកពីខេត្តសៀមរាប ដែលមានឈ្មោះហៅក្រៅថា និមល បានប្រាប់ក្រុមការងារគម្រោងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រថានៅពេលដែលនាងមានអាយុ ៩ ឆ្នាំ (ថ្នាក់ទី ៣) នាងបានបោះបង់ចោលការសិក្សា ដោយសារតែគ្រូរបស់នាងបញ្ជាឱ្យនាងកាត់សក់ ហើយនាងមិនធ្វើតាម។ នៅក្នុងខែ មិថុនា ឆ្នាំ ២០១៥ សកលវិទ្យាល័យបាងកកបានប្រកាសជាផ្លូវការពីជម្រើសឯកសណ្ឋានដែលផ្តល់លទ្ធភាពឱ្យនិស្សិតស្លៀកពាក់ ទៅតាមអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។ [48] វឌ្ឍនភាពបែបនេះនឹងផ្តល់ជាប្រយោជន៍ដល់សិស្ស ដូចជានិមលជាដើមនិងសិស្សផ្សេងទៀត ដែលពុំមានភាពងាយស្រួលជាមួយនឹងស្តង់ដាឯកសណ្ឋាននិងការរៀបចំខ្លួនរបស់សិស្សនៅកម្ពុជា។

## ៥.២. ការឆ្លើយតបចំពោះការសម្លុត

បើតាមទិន្នន័យ ដែលទទួលបានពីការអង្កេតទីពីរ ការឆ្លើយតបលើសលុបពីអ្នកចូលរួមក្នុងការអង្កេតចំពោះការសម្លុតគឺ "មិនបានធ្វើអ្វីទាំងអស់" ដែលត្រូវគ្នានឹងអ្នកឆ្លើយសំណួរជិតពាក់កណ្តាលស្មើនឹង ៤៩,៨៧%។ អ្នកឆ្លើយសំណួរជិត ១ ភាគ ៥ ស្មើនឹង ១៧,៩៥% បានរាយការណ៍ពីការសម្លុតទៅគ្រូ ហើយ ចំនួន ១៤,១០% រាយការណ៍ពីបញ្ហានេះទៅកាន់ឪពុកម្តាយរបស់ខ្លួន។ មានអ្នកចូលរួមតែមួយភាគតូចប៉ុណ្ណោះស្មើនឹង ១,២៨% ដែលរាយការណ៍បញ្ហានេះទៅកាន់នគរបាល។ ប៉ុន្តែតួលេខសម្រាប់អ្នកដែលគេចពីសាលារៀនមានកម្រិតទាបជាងតួលេខដូចគ្នា (ស្មើនឹង ២៣%) ដែលទទួលបានពីការសិក្សាស្រដៀងគ្នាដែលធ្វើឡើងក្នុងប្រទេសជប៉ុន ដែលត្រូវបានបង្ហាញក្នុងផ្នែកអំពី "បរិបទសកល" នៃរបាយការណ៍នេះ។ អ្វីដែលគួរឱ្យមានការព្រួយបារម្ភជាងគេ គឺការស្រាវជ្រាវនេះបង្ហាញភស្តុតាងពីការស្ទាក់ស្ទើររបស់ជនរងគ្រោះក្នុងការរាយការណ៍ពីការសម្លុតនេះក្នុងប្រទេសកម្ពុជា។ អ្វីដែលជាការព្រួយបារម្ភជាពិសេសនោះគឺការស្ទាក់ស្ទើរក្នុងការរាយការណ៍ពីការសម្លុតប្រាប់គ្រូ។ នេះអាចបង្ហាញពីការខ្វះទំនុកចិត្តលើប្រព័ន្ធសាលារៀនក្នុងការ

---

[48] "សកលវិទ្យាល័យបាងកក គាំទ្រឲ្យមានជម្រើសឯកសណ្ឋានតាមយេនឌ័រ" *សារព័ត៌មាន Coconuts Bangkok* (៨ មិថុនា ២០១៥) <http://bangkok.coconuts.co/2015/06/08/bangkok-university-officially-endorses-uniform-gender-choice>

ដោះស្រាយបញ្ហានេះ ប៉ុន្តែក៏អាចជាសញ្ញាបង្ហាញពីបញ្ហារបស់សាលារៀនខ្លួនឯងដែលការសិក្សានេះបានរកឃើញថាក៏ជាប្រភពនៃការសម្លុតផងដែរ។

នៅក្នុងការអង្កេតដំណាក់ទី ២ អ្នកចូលរួមក្នុងការអង្កេត ត្រូវបានសាកសួរថាតើគ្រូឆ្លើយតបចំពោះការសម្លុតដោយរបៀបណា។ ការឆ្លើយតបទាំងនេះ ត្រូវបានបង្ហាញក្នុងក្រាហ្វខាងក្រោម ៖




ដូចដែលបានឃើញក្នុងរូបភាពនេះ គ្រូបង្រៀនចំនួន ៤២,៣១% បានចាត់វិធានការមួយចំនួនដើម្បីបញ្ឈប់មិនឱ្យមានការសម្លុតកើតឡើងទៀត។ ទោះជាយ៉ាងណាក៏ដោយ គ្រូជាច្រើននាក់ហាក់មិនដឹងថាការសម្លុតបានកើតឡើហើយពុំបានធ្វើអ្វីទាំងអស់។ នេះអាចដោយសារតែការខ្វះឆន្ទៈដូចបង្ហាញខាងលើរបស់ជនរងគ្រោះក្នុងការសុំជំនួយពីសាលារៀន ឬអាចដោយសារតែគ្រូខ្វះការយល់ដឹងជាមូលដ្ឋានពីជីវិតប្រចាំថ្ងៃក្នុងសាលារៀន ចេញពីទស្សនៈយល់ឃើញរបស់សិស្សដែលជាអ្នកស្រឡាញ់ភេទដូចគ្នា។ អ្វីដែលកាន់តែធ្វើឱ្យមានការព្រួយបារម្ភនោះ គឺទិន្នន័យពាក់ព័ន្ធជាមួយនឹងគ្រូ ដែលដឹងពីការសម្លុត។ គ្រូបង្រៀនចំនួន ២៥,៦៤% បានចូលរួមក្នុងការសម្លុត ឬដឹងពីការសម្លុតដែរហើយមិនបានធ្វើអ្វីទាំងអស់ ដែលនេះតំណាងឱ្យសិស្សក្នុងភាគរយមួយខ្ពស់ដែលទទួលរងផលប៉ះពាល់ ដោយសារតែសកម្មភាព ឬការមិនធ្វើសកម្មភាពរបស់គ្រូ។ រដ្ឋធម្មនុញ្ញចែងថា *"រដ្ឋត្រូវការពារកុមារពីសកម្មភាពទាំងឡាយណា ដែលធ្វើឱ្យប៉ះពាល់ដល់ឱកាសទទួលបានការអប់រំ សុខភាពនិងសុខុមាលភាពរបស់ពួកគេ..."*។ គួរឱ្យសោកស្តាយ លទ្ធផលនៃការស្រាវជ្រាវនេះ

បង្ហាញថា សាលារៀនក្នុងប្រទេសកម្ពុជា និងគ្រូបង្រៀនជាច្រើននាក់ពុំបានផ្ដល់ការការពារដល់កុមារជាអ្នកស្រឡាញ់ភេទដូចគ្នាពីទង្វើនានាដូចជាការសម្លុតជាដើម ដែលមានផលប៉ះពាល់មកលើសកម្មភាពអប់រំ សុខភាព និងសុខុមាលភាពរបស់ពួកគេនោះទេ។

## ៥.៣. ផលប៉ះពាល់នៃការសម្លុតមកលើជនរងគ្រោះ

ផលប៉ះពាល់នៃការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រមកលើជនរងគ្រោះអាចមានទំហំធំធេងនិងមានទម្រង់ច្រើនយ៉ាង។ ការស្រាវជ្រាវនេះមានគោលបំណងវាយតម្លៃលើផលប៉ះពាល់ភ្លាមៗផងនិងផលប៉ះពាល់រយៈពេលវែងផង ដែលកើតឡើងដោយសារតែការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។ ដូច្នេះ គេត្រូវធ្វើការពិចារណាថាតើការសម្លុតអាចមានផលប៉ះពាល់លើការសម្រេចចិត្តរបស់ជនរងគ្រោះក្នុងការបន្តការអប់រំដែរឬទេក៏ដូចជាលើសុខុមាលភាពរយៈពេលវែងជាទូទៅ។ ការសិក្សាស្រដៀងគ្នាជុំវិញពិភពលោក បានរកឃើញពីទំនាក់ទំនងរវាងការសម្លុតយុវជនជាអ្នកសម្លុតភេទដូចគ្នានិងបញ្ហាសុខភាពផ្លូវចិត្តជាច្រើនដូចជា ការធ្លាក់ទឹកចិត្ត ការថប់បារម្ភ ការផ្ដល់មិនឱ្យតម្លៃដល់ខ្លួនឯង និងអត្រាធ្វើអត្តឃាតខ្ពស់។ លើសពីនេះ បញ្ហាពាក់ព័ន្ធនឹងសុខភាព ដូចជា ការប្រើបំពានជាតិស្រវឹង ការរួមភេទដោយមិនបានការពារនិងការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ក៏មានទំនាក់ទំនងជាមួយនឹងការសម្លុត ពាក់ព័ន្ធនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រដែរ។

ការអង្កេតជំណាក់កាលទី ២ បានដាក់បញ្ចូលសំណួរ ដែលសួរថាតើអ្នកចូលរួមបានរៀនចប់កម្រិតមធ្យមសិក្សាដែរឬទេ ហើយប្រសិនបើពួកគេមិនបានរៀនចប់ តើមូលហេតុអ្វីដែលនាំឱ្យពួកគេឈប់រៀន។ អ្នកចូលរួមចំនួន ៣០,៧៧% បានរៀនចប់សាលាមធ្យមសិក្សា។ ប៉ុន្តែ ក្នុងចំណោមចំនួនដែលនៅសល់ លទ្ធផលធ្វើឱ្យមានការភ្ញាក់ផ្អើល។ ក្នុងចំណោមអ្នកដែលមិនបានរៀនចប់មធ្យមសិក្សា "ការទទួលខុសត្រូវផ្សេងទៀត" គឺជាចម្លើយដែលឆ្លើយញឹកញាប់ជាងគេដោយមានអ្នកចូលរួមជាង ១ ភាគ ៥ ស្មើនឹង២០,៥១% ឆ្លើយចម្លើយនេះ។ ប៉ុន្តែ អ្នកចូលរួម ចំនួន ១២,៨២% បានលើកឡើងពីមូលហេតុដែលពួកគេមិនរៀនចប់សាលាមធ្យមសិក្សាគឺដោយសារតែ *"ការសម្លុតដោយសារតែនិន្នាការភេទឬអត្តសញ្ញាណយេនឌ័ររបស់ពួកគេ"*។ តួលេខនេះមានច្រើនចំនួនអ្នកចូលរួមដែលមិនបានរៀនចប់សាលាមធ្យមសិក្សា ដោយសារតែ "ចំណាយ" មានចំនួន ១០,២៦% ដោយសារតែពួកគេ "មិនចូលចិត្តរៀន" មានចំនួន ៧,៦៩% "មធ្យោបាយធ្វើដំណើរ" មានចំនួន ២,៥៦% និង "ការសម្លុតដោយសារមូលហេតុផ្សេងទៀត" មានចំនួន ២,៥៦% និងភាគរយស្មើគ្នានឹងអ្នកដែលមានមូលហេតុ "ផ្សេងទៀត" ដែលពុំបានរៀបរាប់ដែលនាំឱ្យពួកគេមិនរៀនចប់សាលាមធ្យមសិក្សាមានចំនួន ១២,៨២% ។ លទ្ធផលទាំងនេះ ត្រូវបានបង្ហាញ ក្នុងក្រាហ្វខាងក្រោម ៖




របកគំហើញខាងលើបង្ហាញថាការសម្លុតនៅសាលារៀនពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រមានផលប៉ះពាល់អវិជ្ជមានភ្លាមៗដល់សក្ដានុពលនៃការសិក្សារបស់យុវជនដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងប្រទេសកម្ពុជា ដែលនាំឱ្យមានការបោះបង់ចោលការសិក្សាទាំងពួកគេមិនចង់ធ្វើ ហើយមានផលប៉ះពាល់ខ្លាំងលើសក្ដានុពលរយៈពេលវែងរបស់ពួកគេ។

ដូចគ្នានឹងលទ្ធផលរកឃើញគួរឱ្យព្រួយបារម្ភ ពាក់ព័ន្ធនឹងអត្រាបោះបង់ចោលការសិក្សារបស់ជនរងគ្រោះ លទ្ធផលរបស់យើងក៏បង្ហាញឱ្យឃើញផងដែរថាអត្រាធ្លាក់ទឹកចិត្ត បញ្ហាពាក់ព័ន្ធនឹងការផ្ដល់តម្លៃដល់ខ្លួនឯង ការមានគំនិត និងនិន្នាការចង់ធ្វើអត្តឃាត ក៏ដូចជាការលំបាកក្នុងការជឿទុកចិត្តអ្នកដទៃ និងការបង្កើតទំនាក់ទំនងស្នេហា គឺជាបញ្ហារួមរបស់អ្នកដែលចូលរួមក្នុងការអង្កេតនេះ។

ជាការចាប់ផ្ដើមផ្នែកចុងក្រោយនៃការអង្កេតទាំងពីរនេះដែលផ្ដោតលើការប្រមូលព័ត៌មានអំពីជីវិតនិងអារម្មណ៍បច្ចុប្បន្នរបស់អ្នកស្រឡាញ់ភេទដូចគ្នា នៅថ្ងៃនេះ អ្នកចូលរួមក្នុងការអង្កេតត្រូវបានសួរសំណួរថា "និយាយជាទូទៅ តើអ្នកសប្បាយចិត្តកម្រិតណា ក្នុងជីវិតរបស់អ្នកបច្ចុប្បន្ននេះ?" ដោយអ្នកចូលរួមចំនួន ១៣% រាយការណ៍ថា "មិនសប្បាយចិត្ត" រហូតដល់ "មិនសប្បាយចិត្តទាល់តែសោះ"។ លើសពីនេះ អ្នកចូលរួមចំនួន ៣១% បានរាយការណ៍ថា "ពិតសប្បាយចិត្ត"

រហូតដល់ "រីករាយខ្លាំង" និងអ្នកចូលរួមជាងពាក់កណ្តាលស្មើនឹង ៥២% រាយការណ៍ថា "ពេលខ្លះរីករាយ ហើយពេលខ្លះមិនរីករាយ"។

អ្នកចូលរួមក្នុងការអង្កេត ដែលបានចូលរួមក្នុងការអង្កេតដំណាក់កាលទី ២ ត្រូវបានសួរថា តើបច្ចុប្បន្ននេះ ពួកគេគិតពីការសម្លុតដែលពួកគេជួបប្រទះពេលនៅរៀនញឹកញាប់កម្រិតណា។ លទ្ធផលត្រូវបានបង្ហាញក្នុងក្រាហ្វខាងក្រោម។ ដូចដែលឃើញក្នុងក្រាហ្វនេះ អ្នកចូលរួមចំនួន ៣៧,៣% បាននិយាយថា ពួកគេគិតពីបញ្ហានេះ "ពេលខ្លះ" ។ ចំនួន ១៨,២៥% បាននិយាយថា ពួកគេគិតពីវា "ជារឿយៗ" និង ចំនួន៩,៥២% គិតពីវា "ម្តងម្កាល"។ តួលេខទាំងនេះ ស្មើនឹងជិត ២ ភាគ ៣ នៃអ្នកចូលរួមក្នុងការអង្កេតនេះ។ អ្នកចូលរួម ដែលនៅសល់ស្មើនឹង ៣៤,៩២% បានឆ្លើយថា ពួកគេ "មិនដែល" ឬ "កម្រ" គិតពីការសម្លុតនេះណាស់។




ការអង្កេតដំណាក់កាលទី ១ មានដាក់បញ្ចូលសំណួររឹតតែជាក់លាក់ពាក់ព័ន្ធនឹងផលប៉ះពាល់រយៈពេលវែងដែលការសម្លុតមានមកលើជនរងគ្រោះ ដោយសួរសំណួរថាតើអ្នកចូលរួមមាននឹកឃើញឬចងចាំការទទួលរងការសម្លុតដែរឬទេ។ អ្នកចូលរួមភាគច្រើនបានបញ្ជាក់ថាពួកគេធ្លាប់នឹកឃើញ ឬចងចាំម្តងម្កាល មានចំនួន ៥៣,៧៨% ដោយ ១៣,៤៥% លើកឡើងថា ពួកគេនឹកឃើញជារឿយៗ ហើយចំនួន ៣២,៧៧% បានរាយការណ៍ថាពួកគេមិនដែលនឹកឃើញឬចងចាំអ្វីនោះទេ។ លើសពីនេះចំនួន ៣៨,៦៦% រាយការណ៍ថាការនឹកឃើញឬការចងចាំទាំងនេះ មានផលប៉ះពាល់ជាអវិជ្ជមានទៅលើពួកគេ ដោយចំនួន ២១,៨៥% លើកឡើងថាការសម្លុតទាំងនោះផ្តល់

ផលវិជ្ជមាន ហើយអ្នកចូលរួមចំនួន ៣៩,៥០% លើកឡើងថា ការសម្លុតទាំងនោះពុំមានផលប៉ះពាល់អ្វីទាំងអស់។ លទ្ធផលទាំងនេះបញ្ជាក់ថា ការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ អាចមានផលប៉ះពាល់យ៉ាងធំធេងទៅលើជនរងគ្រោះនៅពេលក្រោយទៀតក្នុងជីវិត។

មានអ្នកចូលរួមក្នុងការអង្កេតនេះជាងពាក់កណ្តាលបានរាយការណ៍ថា មានការផ្តល់តម្លៃខ្លួនឯងពីកម្រិត "ទាប" ទៅ "មធ្យម" ហើយអ្នកចូលរួមចំនួន ៨០% ជួបប្រទះនឹងការធ្លាក់ទឹកចិត្ត "ពេលខ្លះ" (៥០%) "ជាញឹកញាប់" (២០%) ឬ "ជានិច្ចកាល" (១០%)។ អ្នកចូលរួមចំនួន ២០% ទៀតឆ្លើយថា "កម្រ" "មិនដែល" ឬ "មិនចង់និយាយ"។ ស្ថិតិទាំងនេះបង្ហាញថា ការផ្តល់តម្លៃដល់ខ្លួនឯងទាប និងការធ្លាក់ទឹកចិត្តមានកម្រិតខ្ពស់ក្នុងចំណោមអ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា។

ការស្រាវជ្រាវ ដែលប្រមូលព័ត៌មានពីការអង្កេតដំណាក់កាលទី ១ បង្ហាញថា អ្នកចូលរួមក្នុងការអង្កេតចំនួន ២៤,៣៧% ធ្លាប់មានគំនិតចង់ធ្វើអត្តឃាត "ម្តងម្កាល" ឬ "ជាញឹកញាប់"។ លើសពីនេះចំនួន ១៥,៩៧% បានប៉ុនប៉ងធ្វើអត្តឃាតម្តង ហើយចំនួន ១,៦៨% រាយការណ៍ថា ប៉ុនប៉ងធ្វើអត្តឃាតច្រើនជាងម្តង។

បន្ថែមពីលើលទ្ធផលរកឃើញ ដែលបង្ហាញពីបញ្ហាជ្រាលជ្រៅ ពាក់ព័ន្ធនឹងការផ្តល់តម្លៃខ្លួនឯង ការធ្លាក់ទឹកចិត្ត និងអត្តឃាត អ្នកចូលរួមជាអ្នកស្រឡាញ់ភេទដូចគ្នាដែលចូលរួមក្នុងការសិក្សានេះបញ្ជាក់ថាពួកគេមានការលំបាកក្នុងជឿទុកចិត្តអ្នកដទៃ និងបង្កើតទំនាក់ទំនងស្នេហា។ អ្នកចូលរួមជិត ៣ ភាគ ៤ ក្នុងការអង្កេតនេះ បាននិយាយថា ពួកគេមាន "ការលំបាកខ្លាំង" មានចំនួន ៥១% ឬ "លំបាកដែរ" មានចំនួន ២១% ក្នុងការជឿទុកចិត្តអ្នកដទៃ។ អ្នកចូលរួមមានចំនួន ២៦% ដែលធ្លាប់មានទំនាក់ទំនងស្នេហារាយការណ៍ថាមាន "ការលំបាក" ក្នុងការបង្កើតទំនាក់ទំនងទាំងនេះ។ អ្នកចូលរួមចំនួន ២៥% បានរាយការណ៍ថាមិនដែលមានទំនាក់ទំនងស្នេហាឡើយ ហើយពួកគេមាន "ការលំបាកខ្លាំង" ក្នុងការបង្កើតទំនាក់ទំនងបែបនេះ។

ដូចគ្នានឹងទិន្នន័យខាងលើដែរ យើងក៏បានឮពីបុរសស្រឡាញ់បុរសវ័យ ៥៥ ឆ្នាំម្នាក់ ដែលមានឈ្មោះហៅក្រៅ ចេកឃីដែរបានរៀបរាប់ពីការលំបាកដែលគាត់ជួបប្រទះក្នុងនាមជាអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងប្រទេសកម្ពុជា ៖

> *"ចាប់ពីពេលនោះ រហូតមកដល់សព្វថ្ងៃនេះ ខ្ញុំពិតជាធ្លាក់ទឹកចិត្តយ៉ាងខ្លាំង។ ខ្ញុំតែងតែសម្លឹងទៅមិត្តភក្តិរបស់ខ្ញុំនៅសាលារៀន ឬមិត្តរួមការងារ និងស្រម៉ៃថានឹងរកបានប្រុសសង្ហារម្នាក់។ ខ្ញុំមិនហ៊ានបង្ហាញនូវទំនោរយេនឌ័រខ្លួនឱ្យគេដឹងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញរបស់ខ្ញុំនោះទេ ដោយសារតែគ្រួសារនិងកន្លែងធ្វើការរបស់ខ្ញុំស្អប់បុរសស្រឡាញ់បុរស។ រហូតមកទល់នឹងពេលថ្មីៗនេះ ឪពុកម្តាយរបស់ខ្ញុំតែងសួរខ្ញុំ "តើពេលណាទើបខ្ញុំរៀបការ?" ពួកគេលែងសួរខ្ញុំទៀតហើយ ដោយសារតែ*

*ខ្ញុំមិនដែលឆ្លើយនឹងពួកគេ។ ខ្ញុំពិតជារស់នៅដោយភាពសោកសៅ តាំងពីពេលដែលខ្ញុំនៅរៀនរហូតដល់ខ្ញុំចាស់ឥលូវនេះ។ ខ្ញុំចង់បង្ហាញនិងមានទំនាក់ទំនងគត់មត់នឹងគេ ប៉ុន្តែខ្ញុំចាំបាច់ត្រូវរក្សាអាថិកំបាំងនៃនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់ខ្ញុំ។"*

ដោយឡែកអ្វីដែលវិជ្ជមានវិញ នៅក្នុងការអង្កេតដំណាក់កាលទី ២ អ្នកចូលរួមត្រូវបានសួរសំណួរដែលរៀបចំឡើង ដើម្បីវាយតម្លៃលើការពេញចិត្តជាទូទៅជាមួយនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់ពួកគេ។ អ្នកចូលរួមចំនួន ៧០,៦៣% ជ្រើសរើសចម្លើយ "ខ្ញុំមានមោទនភាព ចំពោះអត្តសញ្ញាណយេនឌ័រនិងនិន្នាការភេទរបស់ខ្ញុំ" ដោយមានត្រឹមតែ ១២,៧០% ប៉ុណ្ណោះ ដែលជ្រើសរើសយក "ខ្ញុំខ្មាសគេ ហើយចង់អាចផ្លាស់ប្តូរអត្តសញ្ញាណយេនឌ័រនិងនិន្នាការភេទរបស់ខ្ញុំ"។ អ្នកឆ្លើយតបចំនួន ១៦,៦៧% ជ្រើសរើសចម្លើយ "ខ្ញុំមិនគិតអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ខ្ញុំឡើយ"។

ទិន្នន័យប្រមូលបានពាក់ព័ន្ធជាមួយនឹងការប្រើជាតិស្រវឹង និងការប្រើគ្រឿងញៀន ក្នុងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាបង្ហាញពីភាពល្អប្រសើរ។ នៅពេលដែលអ្នកចូលរួមត្រូវបានសួរថាតើពួកគេធ្លាប់ប្រើគ្រឿងញៀន ដើម្បីសប្បាយដែរឬទេចំនួន ៨៦% និយាយថា ពួកគេមិនធ្លាប់ប្រើទេ ដោយមានតែចំនួន ៧% ប៉ុណ្ណោះ ដែលឆ្លើយថាពួកគេធ្លាប់ប្រើ។ លើសពីនេះ អ្នកចូលរួមក្នុងការអង្កេតចំនួន ៤៥% បាននិយាយថាពួកគេប្រើប្រាស់ជាតិស្រវឹង "ពីរបីដង ក្នុងមួយខែ" ហើយតិចជាង ១០% និយាយថាពួកគេប្រើប្រាស់ជាតិស្រវឹង "ក្នុងថ្ងៃភាគច្រើន"។ អ្នកចូលរួមដែលនៅសេសសល់ឆ្លើយផ្សេងគ្នា ចន្លោះរវាង "មិនដែល" ប្រើជាតិស្រវឹងមានចំនួន ១៦% "ពីរបីដងក្នុងមួយសប្តាហ៍" មានចំនួន ១៧% ឬ "ពីរបីដងក្នុងមួយឆ្នាំ" មានចំនួន ១២% ។

នៅពេលដែលអ្នកចូលរួមផឹកជាតិស្រវឹង ភាគច្រើនផឹក "តិចតួច" មានចំនួន ៤២% រហូតដល់កម្រិត "មធ្យម" មានចំនួន ៣២%។ អ្នកចូលរួមក្នុងការអង្កេតចំនួន ១% និយាយថា ពួកគេមិនចង់ប្រាប់ថាតើពួកគេផឹកច្រើនប៉ុណ្ណានោះទេ ប៉ុន្តែ ចំនួន ១១% និយាយថា ពួកគេ "មិនផឹកសោះ" និង ចំនួន ១២% និយាយថា ពួកគេផឹកជាតិស្រវឹងក្នុងបរិមាណ "ច្រើន"។ បើទោះបីជាពុំមានក្រុមសម្រាប់ផ្ទៀងផ្ទាត់ ដើម្បីប្រៀបធៀបទិន្នន័យនេះក៏ដោយ លទ្ធផលរកឃើញនេះហាក់បីដូចជាមិនលើសលប់ពេកនោះទេ។

# ៦. សេចក្តីសន្និដ្ឋាននិងអនុសាសន៍

លិខិតូបករណ៍ច្បាប់ជាច្រើនទាំងអន្តរជាតិ ទាំងជាតិ ចែងពីវិធានការមួយចំនួន ដែលត្រូវបានរៀបចំឡើងដើម្បីបង្កើតនូវបរិយាកាសអប់រំដែលពុំមានការរើសអើងនិងបង្កលក្ខណៈឱ្យយុវជនកម្ពុជាអាចសម្រេចបាននូវសក្តានុពលរបស់ខ្លួន ដោយមិនគិតពីឋានៈរបស់ពួកគេ។ ប៉ុន្តែការស្រាវជ្រាវដែលបង្ហាញក្នុងរបាយការណ៍នេះបង្ហាញថាមានភាពចាំបាច់ជាបន្ទាន់មួយ ដើម្បីផ្តល់ការការពារឱ្យបានកាន់តែប្រសើរដល់សិស្សដែលជាអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ប្រសិនបើចង់ឱ្យមានការសម្រេច និងការពារសិទ្ធិមនុស្សរបស់ពួកគេ។ ការរើសអើងផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ នៅតាមសាលារៀនគឺជាបញ្ហាមួយដែលមានផលប៉ះពាល់លើសពីក្នុងបន្ទប់រៀន។ អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជាត្រូវឆ្លងកាត់ប្រព័ន្ធសាលារៀនក្នុងរយៈពេលដែលងាយរងគ្រោះ និងរយៈពេលបង្កើនចំណេះដឹងរបស់ពួកគេ។ ការស្រាវជ្រាវនេះបង្ហាញថាបទពិសោធន៍ដែលពួកគេជួបប្រទះ ក្នុងប្រព័ន្ធអប់រំនឹងនៅជាប់ជាមួយពួកគេក្នុងជីវិតដែលអាចធ្វើឱ្យជីវិតរបស់ពួកគេកាន់តែប្រសើរឬកាន់តែធ្ងន់ធ្ងរជាងមុន។ ប្រសិនបើបុគ្គលដែលជាអ្នកស្រឡាញ់ភេទដូចគ្នា នឹងក្លាយជាសមាជិកស្មើភាពគ្នាពិតប្រាកដក្នុងសង្គមខ្មែរ ការរើសអើងផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ នៅតាមសាលារៀនចាំបាច់ត្រូវតែដោះស្រាយជាអាទិភាពបន្ទាន់។ នេះតម្រូវឱ្យមានការខិតខំប្រឹងប្រែងដោយមានការប្តេជ្ញាចិត្តឱ្យចំគោលដៅពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល គ្រូ សាលារៀននិងតួអង្គផ្សេងទៀត។ អនុសាសន៍ពិស្តារដើម្បីសម្រេចគោលដៅនេះត្រូវបានបង្ហាញនៅផ្នែកខាងក្រោម។

ទិន្នន័យ ដែលបង្ហាញក្នុងរបាយការណ៍នេះ ផ្តល់នូវភស្តុតាងបែបបរិមាណ និងគុណភាពសំខាន់ៗដែលបង្ហាញថាអ្នកស្រឡាញ់ភេទដូចគ្នាជួបប្រទះនឹងបញ្ហាធ្ងន់ធ្ងរ ដោយសារតែការសម្លុតតាមគ្រឹះស្ថានអប់រំពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់ពួកគេ។ ទិន្នន័យនេះក៏បង្ហាញផងដែរថា ការសម្លុតផ្អែកលើនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រគឺជាបញ្ហាប្រឈមក្នុងសាលារៀន ជាជាងក្រៅសាលារៀន ដែលបង្ហាញថា បើទោះបីជាអ្នកស្រឡាញ់ភេទដូចគ្នា ទទួលរងការរើសអើងពីសង្គមកម្ពុជាជាទូទៅក៏ដោយ វាគឺជាភារកិច្ចរបស់សាលារៀនដែលត្រូវបង្កើតនូវបរិយាកាសមួយ ដែលពុំមានការរើសអើងពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។

ការរើសអើងពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រតាមសាលារៀនស្តែងចេញជាច្រើនទម្រង់ដូចជា ការបំពារបំពានខាងផ្លូវកាយ ការបំពារបំពានជាពាក្យសម្តីនិងការបំពារបំពានផ្លូវភេទ។ លទ្ធផលរកឃើញដែលគួរឱ្យមានការព្រួយបារម្ភជាពិសេស

គឺលទ្ធផលរកឃើញ ដែលបង្ហាញពីភាពធម្មតានៃការកើតមានការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ និងលទ្ធផលរកឃើញ ដែលថា សាលារៀនខ្លួនឯងក៏ចូលរួមពាក់ព័ន្ធ ឬយ៉ាងហោចណាស់ខកខានក្នុងការធ្វើអន្តរាគមន៍ ចំពោះករណីមានការសម្លុត ពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។ ជាលទ្ធផល ជនរងគ្រោះមានជំនឿតិចតួចលើលទ្ធភាពរបស់សាលារៀនក្នុងការដោះស្រាយបញ្ហានៃការសម្លុតនេះ។ អ្វីដែលបង្ហាញចេញយ៉ាងច្បាស់លាស់ដោយការស្រាវជ្រាវនេះដែរគឺ ប្រេវ៉ាឡង់នៃការសម្លុតនេះធ្វើឱ្យយុវជនដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ជាច្រើននាក់ត្រូវបោះបង់ចោលការសិក្សាដែលជាការដាក់កំហិតលើឱកាសក្នុងជីវិតរបស់ពួកគេ។ ការស្រាវជ្រាវនេះក៏បង្ហាញផងដែរថាអ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាច្រើនតែមានបញ្ហាសុខភាពផ្លូវចិត្តរយៈពេលវែង ដោយសារតែនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័ររបស់ពួកគេ។ អ្វីដែលប្រហែលជាធ្វើឱ្យមានការព្រួយបារម្ភជាងគេពាក់ព័ន្ធជាមួយនឹងចំណុចនេះ គឺលទ្ធផលរកឃើញពាក់ព័ន្ធនឹងការធ្លាក់ទឹកចិត្តក្នុងកម្រិតមួយដ៏ខ្ពស់របស់អ្នកចូលរួមក្នុងការការអង្កេតនេះ។ បញ្ចូលគ្នាជាមួយនឹងលទ្ធផលរកឃើញបានពីការសិក្សាផ្សេងទៀត ដែលត្រូវបានលើកឡើងក្នុងរបាយការណ៍នេះ ទិន្នន័យនេះគាំទ្រដល់ការលើកឡើងថាការធ្លាក់ទឹកចិត្តគឺជាបញ្ហាសំខាន់មួយក្នុងជីវិតទាំងមូលរបស់អ្នកស្រឡាញ់ភេទដូចគ្នា។

ជាទូទៅ លទ្ធផលរកឃើញនៃការស្រាវជ្រាវនេះគឺស្រដៀងគ្នាខ្លាំងទៅនឹងទិន្នន័យ ពីប្រទេសផ្សេងទៀតដែលបង្ហាញថាការសម្លុតអ្នកស្រឡាញ់ភេទដូចគ្នា តាមសាលារៀន និងផលប៉ះពាល់ដែលកើតឡើងដោយសារការសម្លុតគឺជាបញ្ហាសកលដែលចាំបាច់ត្រូវដោះស្រាយពីសំណាក់ស្ថាប័នរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលដែលធ្វើការងារខាងការការពារសិទ្ធិមនុស្ស។ មានភាពខុសប្លែកគ្នាគួរឱ្យកត់សម្គាល់មួយចំនួនក្នុងចំណុចខ្លះរវាងការសិក្សានេះ និងការសិក្សាជាសកលមួយចំនួន ដែលត្រូវបានលើកមកបង្ហាញក្នុងរបាយការណ៍នេះដែរ។ ករណីមួយគឺស្ថានភាពក្នុងប្រទេសអូស្ត្រាលីដែលជនរងគ្រោះដោយសារការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ ច្រើនតែស្វែងរកការគាំទ្រពីសាលារៀនរបស់ពួកគេគឺខុសពីប្រទេសកម្ពុជា ដែលបង្ហាញថាសិស្សអូស្ត្រាលីមានទំនុកចិត្តលើលទ្ធភាពរបស់សាលារៀនពួកគេជាង ក្នុងការដោះស្រាយបញ្ហាសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។

កាលពីពេលថ្មីៗនេះ អ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងប្រទេសកម្ពុជា ហាក់បីដូចជាមានបំណងបង្ហាញថាខ្លួនគិតគូរពីអ្នកស្រឡាញ់ភេទដូចគ្នាដោយធ្វើការផ្សព្វផ្សាយរូបភាពរបស់ប្រទេសកម្ពុជាថាជាប្រទេសមួយដែលឈរមុខគេទៅលើរឿងសមភាពអ្នកស្រឡាញ់ភេទដូចគ្នានៅតំបន់អាស៊ីអាគ្នេយ៍។ អ្វីដែលគួរឱ្យសោកស្តាយ រូបភាពនេះនៅតែផ្ទុយនឹងបទពិសោធន៍របស់យុវជនជា

អ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់ដែលជួបប្រទះនឹងការរើសអើង និងការសម្លុតក្នុងប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជា ដូចដែលត្រូវបានរៀបរាប់លំអិតក្នុងរបាយការណ៍នេះ។ ខណៈពេលដែលវាជាចំណុចមួយល្អប្រសើរ ដែលរដ្ឋាភិបាលកម្ពុជាបានបង្កើនការចូលរួមរបស់ខ្លួន ជាមួយនឹងសង្គមស៊ីវិល ពាក់ព័ន្ធនឹងបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេសសក្នុងប្រព័ន្ធអប់រំហាក់បីដូចជានៅមានការងារជាច្រើនទៀត ដែលចាំបាច់ត្រូវធ្វើ។

ដោយចងចាំពីចំណុចនេះ ម.ស.ម.កសូមផ្តល់នូវអនុសាសន៍ខាងក្រោមដល់អ្នកពាក់ព័ន្ធនានា ផ្អែកតាមការស្រាវជ្រាវ ដែលបង្ហាញក្នុងរបាយការណ៍នេះ ៖

***១. អនុសាសន៍ ដាក់ជូនរាជរដ្ឋាភិបាលកម្ពុជា***

*១.១. ធានាយ៉ាងណាឱ្យគ្រឹះស្ថានអប់រំនៅកម្ពុជាបង្កភាពងាយស្រួលដល់អ្នកស្រឡាញ់ភេទដូចគ្នា តាមរយៈ៖*

*១.១.១. បន្តនិងពង្រីកកិច្ចសហប្រតិបតិការបច្ចុប្បន្ន ជាមួយសង្គមស៊ីវិលដើម្បីផ្តល់ការបណ្តុះបណ្តាលអំពីការគិតគូរពីអ្នកស្រឡាញ់ភេទដូចគ្នាទូទាំងប្រទេសកម្ពុជា។*

*១.១.២. បន្តនិងពង្រីកកិច្ចសហប្រតិបតិការបច្ចុប្បន្នជាមួយសង្គមស៊ីវិល ដើម្បីឱ្យកម្មវិធីសិក្សានៅបឋមសិក្សា និងមធ្យមសិក្សា ដាក់បញ្ចូលបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា។*

*១.១.៣. ធានាយ៉ាងណាឱ្យគោលនយោបាយស្តីពីឯកសណ្ឋានសាលារៀន មានភាពបត់បែន ដើម្បីសម្របតាមសិស្សនិស្សិតដែលអត្តសញ្ញាណយេនឌ័រមិនត្រូវនឹងភេទពីកំណើតរបស់ពួកគេ។*

*១.១.៤. ចេញសេចក្តីព្រាងគោលនយោបាយស្តីពីការសម្លុតដែលអាចអនុវត្តដោយសាលារៀនទាំងអស់ និងដែលគិតគូរពីការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។*

*១.២. ដាក់ឱ្យអនុវត្តនូវច្បាប់ប្រឆាំងនឹងការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ឱ្យបានឆាប់តាមដែលអាចធ្វើបានដោយមានដាក់បញ្ចូលបញ្ញត្តិ ដែលនឹង ៖*

*១.២.១. ធានាឱ្យមានការប្រតិបត្តិស្មើភាពគ្នាដល់សិស្សនិស្សិត និងបុគ្គលិក ដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងគ្រប់គ្រឹះស្ថានអប់រំបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សាទាំងអស់។*

*១.២.២. ធានាឱ្យមានការផ្តល់ឱកាសស្មើភាពគ្នាដល់អ្នកស្រឡាញ់ភេទដូចគ្នានៅកន្លែងធ្វើការ និងក្នុងដំណើរការនៃការជ្រើសរើសបុគ្គលិក។*

១.២.៣. ធានាឱ្យមានការទទួលបានសេវាថែទាំសុខភាពស្មើភាពគ្នា ដល់អ្នកស្រឡាញ់ភេទដូចគ្នា។

១.៣. ធ្វើវិសោធនកម្មមាត្រា ៤៥ (អំពីអាពាហ៍ពិពាហ៍) ក្នុងរដ្ឋធម្មនុញ្ញ ដើម្បីដកចេញចំណុច "ប្តីមួយ" និង "ប្រពន្ធមួយ" ឬជម្រើសមួយទៀត ចេញអនុក្រឹត្យ ដើម្បីបញ្ជាក់ពីនីត្យានុកូលភាពដែលមានស្រាប់នៃអាពាហ៍ពិពាហ៍រវាងគូស្រករភេទដូចគ្នា និងតម្រូវឱ្យអាជ្ញាធរមូលដ្ឋានទាំងអស់ទទួលស្គាល់ និងគោរពសម្ព័ន្ធភេទដូចគ្នា។

១.៤. ធានាឱ្យមានការផ្តល់សេវាសុខភាពទូទៅ និងសេវាសុខភាពផ្លូវចិត្តដល់អ្នកស្រឡាញ់ភេទដូចគ្នា ដែលកំពុងប្រឈមនឹងហានិភ័យ និងធានាយ៉ាងណាឱ្យមានការបណ្តុះ បណ្តាលបុគ្គលិកថែទាំសុខភាពដើម្បីដោះស្រាយបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា។

## ២. អនុសាសន៍ សម្រាប់គ្រប់គណបក្សនយោបាយទាំងអស់ ៖

២.១. ប្តេជ្ញាលើកកម្ពស់សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាក្នុងប្រទេសកម្ពុជា តាមរយៈ ៖

២.១.១. ការធ្វើការសន្យាច្បាស់លាស់ជាសាធារណៈថានឹងអនុវត្តតាមអនុសាសន៍ ១.១ ដល់ ១.៤ ប្រសិនបើខ្លួនជាប់ការបោះឆ្នោតដើម្បីកាន់អំណាច។

២.១.២. ការផ្សព្វផ្សាយសារវិជ្ជមានអំពីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅពេលរៀបចំយុទ្ធនាការ ឬចូលរួមក្នុងការជជែកជាសាធារណៈនានា។

## ៣. អនុសាសន៍ សម្រាប់សាលារៀន និងគ្រូបង្រៀន

៣.១. ជំរុញឱ្យមានការប្រតិបត្តិស្មើគ្នាចំពោះសិស្សនិស្សិតដែលជាអ្នកស្រឡាញ់ភេទដូចគ្នាដោយ ៖

៣.១.១. រៀបចំនូវគោលនយោបាយប្រឆាំងការសម្លុត ដែលមានដាក់បញ្ចូលការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ និងដែលមានដាក់បញ្ចូលនូវយន្តការសម្រាប់ឱ្យជនរងគ្រោះ ដោយសារការសម្លុត អាចធ្វើការរាយការណ៍ប្រកបដោយសុវត្ថិភាពពីករណីសម្លុតនានា ដែលអាចទទួលបានដំណោះស្រាយសមស្រប។

៣.១.២. ដោះស្រាយគ្រប់ករណីនៃការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រឱ្យបានសមស្រប។

៣.១.៣. អប់រំសិស្សនិស្សិតអំពីសារៈសំខាន់នៃការអធ្យាស្រ័យ សមភាព និងការមិនរើសអើងក្នុងថ្នាក់រៀន។

៣.១.៤. អប់រំសិស្សនិស្សិតអំពីសិទ្ធិរបស់ពួកគេ ក្រោមរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ប្រព័ន្ធអប់រំនិងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសកម្ពុជាជាភាគី។

## ៤. អនុសាសន៍ សម្រាប់អង្គការសង្គមស៊ីវិលនៅកម្ពុជា

៤.១. ធានាថាសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នាជាពិសេសក្នុងប្រព័ន្ធអប់រំក្លាយជាអាទិភាពមួយនៃរាជរដ្ឋាភិបាលកម្ពុជា ដោយ ៖

៤.១.១. សហការឱ្យបានជិតស្និទ្ធជាមួយនឹងអង្គការសង្គមស៊ីវិលផ្សេងទៀត និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាដើម្បីធានាយ៉ាងណាឱ្យសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាមានសម្លេងរួមរឹងមាំនៅពេលធ្វើការតស៊ូមតិ។

៤.១.២. រៀបចំគម្រោងនិងសកម្មភាពដែលផ្តល់ភាពអង់អាចដល់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជាក្នុងការតស៊ូមតិដើម្បីសិទ្ធិរបស់ពួកគេនិងប្រយុទ្ធប្រឆាំងនឹងការសម្លុតពាក់ព័ន្ធនឹងនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រ។

៤.១.៣. ពង្រីកកិច្ចសហប្រតិបត្តិការបច្ចុប្បន្ន ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាយ៉ាងណាឱ្យគ្រូបង្រៀនគ្រប់រូបក្នុងប្រទេសកម្ពុជាទទួលបានការបណ្តុះបណ្តាលដែលគិតគូរពីអ្នកស្រឡាញ់ភេទដូចគ្នា។

៤.១.៤. ពង្រីកកិច្ចសហប្រតិបត្តិការបច្ចុប្បន្នជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជាដើម្បីធានាយ៉ាងណាឱ្យកម្មវិធីសិក្សាដាក់បញ្ចូលបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា។

៤.១.៥. បញ្ជ្រាបការគិតគូរពីនិន្នាការភេទឬអត្តសញ្ញាណយេនឌ័រ/ការបង្ហាញនូវទំនោរយេនឌ័រនិងការមិនរើសអើងទៅក្នុងគ្រប់គោលនយោបាយផ្ទៃក្នុង ដំណើរការនៃការជ្រើសរើសបុគ្គលិក សកម្មភាព និងការងារគម្រោងទាំងអស់។

៤.១.៦. ធ្វើការស្រាវជ្រាវបន្ថែមទៀត អំពីការសម្លុតលើអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងប្រទេសកម្ពុជា និងជំរុញឱ្យមានការចូលរួមពីគ្រូ អ្នកគ្រប់គ្រងសាលារៀន និងមន្ត្រី រដ្ឋាភិបាលក្នុងការស្រាវជ្រាវនេះ។

## ៥. អនុសាសន៍ សម្រាប់អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយ

៥.១. ធានាថាសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា ជាពិសេស ក្នុងប្រព័ន្ធអប់រំក្លាយជាអាទិភាពមួយនៃរាជរដ្ឋាភិបាលកម្ពុជា ដោយ ៖

៥.១.១. ធ្វើការបញ្ជ្រាបការគាំទ្រដល់រដ្ឋាភិបាលកម្ពុជា និងក្រសួងពាក់ព័ន្ធ ដើម្បីធានាយ៉ាងណាឱ្យប្រទេសកម្ពុជាមានសមត្ថភាពអភិវឌ្ឍន៍ប្រព័ន្ធអប់រំ ដែលគិតគូរពេញលេញពីបញ្ហារបស់អ្នកស្រឡាញ់ភេទដូចគ្នា ដែលពុំមានការរើសអើង។

៥.១.២. ដាក់អាទិភាពលើការបញ្ចូលអ្នកស្រឡាញ់ភេទដូចគ្នា ការមិនរើសអើង និងអនុសាសន៍នានា ក្នុងរបាយការណ៍នេះ នៅពេលចូលរួមក្នុងការងារគោលនយោបាយជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា។

# ៧. គន្លងនិទ្ទេស

## ច្បាប់របស់ប្រទេសកម្ពុជា

*ច្បាប់*

ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា (២០០៧)

រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា (វិសោធនកម្ម ឆ្នាំ ១៩៩៣)

ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា (២០០៩)

ច្បាប់ស្តីពីការអប់រំ នៃព្រះរាជាណាចក្រកម្ពុជា (២០០៧)

ច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា (១៩៩៧)

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី (២០១១)

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ (១៩៨៩)

***សេចក្តីសម្រេច***

ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា *សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០០៧*

## ច្បាប់ និងលិខិតុបករណ៍អន្តរជាតិ

*សន្ធិសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិ*

ធម្មនុញ្ញនៃសហប្រជាជាតិ (២៦ មិថុនា ១៩៤៥)

អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនារីភេទ (អនុម័តថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៧៩)

អនុសញ្ញាស្តីពីសិទ្ធិកុមារ (២០ វិច្ឆិកា ១៩៨៩ ចូលជាធរមាន ០២ កញ្ញា ១៩៩០)

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៦ ធ្នូ ១៩៦៦ ចូលជាធរមាន ២៣ មីនា ១៩៧៦)

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (អនុម័ត ១៦ ធ្នូ ១៩៦៦)

សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (អនុម័ត ១០ ធ្នូ ១៩៤៨)

*សន្ធិសញ្ញា និងកិច្ចព្រមព្រៀងថ្នាក់តំបន់*

ធម្មនុញ្ញនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (២០ វិច្ឆិកា ២០០៧ ចូលជាធរមាណ ១៥ ធ្នូ ២០០៨)

*ច្បាប់យុត្តិសាស្ត្រ និងសេចក្តីសម្រេច*

គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌៖ *ការពិចារណាលើរបាយការណ៍ដែលដាក់ដោយរដ្ឋភាគី ក្រោមមាត្រា ១៦ និង១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ - ប្រទេសចិន៖ តំបន់រដ្ឋបាលពិសេស ហុងកុង* (E/C.12/1/Add.58). ២១ ឧសភា ២០១១

គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌៖ *ការពិចារណាលើរបាយការណ៍ដែលដាក់ដោយរដ្ឋភាគី ក្រោមមាត្រា ១៦ និង១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ - ប្រទេសអៀរឡង់* (E/C.12/1/Add.35). ១៤ ឧសភា ១៩៩៩

អនុសញ្ញាស្តីពីសិទ្ធិកុមារ៖ *ការពិចារណាលើរបាយការណ៍ ដែលដាក់ដោយរដ្ឋភាគី ក្រោមមាត្រា ៤៤ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ៖ យោបល់សន្និដ្ឋាន៖ ចក្រភពអង់គ្លេស និងអៀរឡង់ខាងជើង* (CRC/C/GBR/CO/4). ២០ តុលា ២០០៨

គណៈកម្មាធិការសិទ្ធិមនុស្សរបស់សហប្រជាជាតិ៖ *ការពិចារណាលើរបាយការណ៍ ដែលដាក់ដោយរដ្ឋភាគី ក្រោមមាត្រា ៤០ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ សេចក្តីសន្និដ្ឋានសរុបរបស់គណៈកម្មាធិការសិទ្ធិមនុស្ស - ប្រទេសប៉ូឡូញ* (CCPR/C/79/Add.110). ២៩ កក្កដា ១៩៩៩

គណៈកម្មាធិការសិទ្ធិមនុស្សរបស់សហប្រជាជាតិ៖ *ការយល់ឃើញរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ក្រោមមាត្រា ៥ កថាខណ្ឌ ៤ នៃពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ របាយការណ៍លេខ ៤៨៨/១៩៩២៖ Toonen v. Australia* (CCPR/C/50/D/488/1992). ០៤ មេសា ១៩៩៤

គណៈកម្មាធិការសិទ្ធិមនុស្សរបស់សហប្រជាជាតិ៖ *ការយល់ឃើញរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ក្រោមមាត្រា ៥ កថាខណ្ឌ ៤ នៃពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ របាយការណ៍លេខ ៩៤១/២០០០៖ Young v Australia* (CCPR/C/78/D/941/2000). ០៦ សីហា ២០០៣

គណៈកម្មាធិការសិទ្ធិមនុស្សរបស់សហប្រជាជាតិ៖ *ការយល់ឃើញរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ក្រោមមាត្រា ៥ កថាខណ្ឌ ៤ នៃពិធីសារបន្ថែមនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ពលរដ្ឋ និងសិទ្ធិនយោបាយ របាយការណ៍លេខ ១៩៣២/២០១០៖ Fedotova v Russian Federation* (CCPR/C/106/D/1932/2010). ៣១ តុលា ២០១២

*លិខិតុបករណ៍អន្តរជាតិដទៃទៀត*

គោលការណ៍យ៉កយ៉ាកាតា Yogyakarta ស្តីពីការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិ ពាក់ព័ន្ធនឹងនិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ (២៦ មីនា ២០០៧)

**របាយការណ៍ និងឯកសារបោះពុម្ពផ្សាយ**

ម.ស.ម.ក "បង្ហាញខ្លួនជាចំហក្នុងព្រះរាជាណាចក្រ៖ បុរសស្រឡាញ់ប្រុស ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ ក្នុងប្រទេសកម្ពុជា" (របាយការណ៍) (ខែ ធ្នូ ឆ្នាំ ២០១០) <http://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=8&id=3>

ម.ស.ម.ក "ឥន្ទធនូខ្មែរ៖ ពីកែប្រែការរើសអើងទៅជាមោទនភាព" (របាយការណ៍) (ខែ ធ្នូ ឆ្នាំ ២០១២)<http://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=85&id=3>

ក្រុមហ៊ុនដំរីស្រាវជ្រាវ និងពិគ្រោះយោបល់ "ការអង្កេតបឋមលើយុទ្ធនាការប្រាស្រ័យទាក់ទងរួមគ្នាលើអំពើហិង្សាលើស្ត្រី" (របាយការណ៍) (ឆ្នាំ ២០១២)

ទីភ្នាក់ងារនៃសហភាពអឺរ៉ុបទទួលបន្ទុកសិទ្ធិជាមូលដ្ឋាន "ការអង្កេតលើបុរសស្រឡាញ់ប្រុស ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទរ របស់សហភាពអឺរ៉ុប៖ សង្ខេបលទ្ធផល" (របាយការណ៍) (ឆ្នាំ ២០១៣) <http://fra.europa.eu/sites/default/files/eu-lgbt-survey-results-at-a-glance_en.pdf>

ជីស្លេន (GLSEN)ការអង្កេតថ្នាក់ជាតិលើបរិយាកាសតាមសាលារៀន ឆ្នាំ ២០០៩៖ បទពិសោធន៍របស់យុវជន ដែលជាបុរសស្រឡាញ់ប្រុស ស្ត្រីស្រឡាញ់ស្ត្រី អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ នៅតាមសាលារៀនក្នុងប្រទេសរបស់យើង" (របាយការណ៍) (ឆ្នាំ ២០០៩)

ហេឡេន ម៉ាក់ណាមី (Helen McNamee)ចេញមកដោយខ្លួនឯង៖ ការពិនិត្យលើសុខភាពផ្លូវចិត្តរបស់បុរសវ័យក្មេងដែលស្រឡាញ់ភេទដូចគ្នា" (របាយការណ៍) (ឆ្នាំ ២០០៦) <http://www.rainbow-project.org/assets/publications/out_on_your_own.pdf>

ចូណា អាល់ម៉ៃដា (Joanna Almeida) និងអ្នកនិពន្ធផ្សេងទៀត(Renee M. Johnson, Heather L. Corliss, Beth E. Molnar និង Deborah Azrael )វិបត្តិផ្លូវចិត្ត ក្នុងចំណោមយុវជនដែលស្រឡាញ់ភេទដូចគ្នា៖ ឥទ្ធិពលនៃការដឹងពីការរើសអើង ផ្អែកលើនិន្នាការភេទ" (របាយការណ៍) *ព្រឹត្តិបត្រព័ត៌មានអំពីយុវជន និងក្មេងជំទង់* (ខែ សីហា ឆ្នាំ ២០០៩) លេខ ៣៨ ការបោះពុម្ពផ្សាយទី ៧៖ ១០០១-១០១៤

ឡៃណេ ហីលីយេ៉ (Lynne Hillier) និងអ្នកនិពន្ធដទៃទៀត(Tiffany Jones, Marisa Monagle, Naomi Overton, Luke Gahan, Jennifer Blackman, Anne Micthell )សរសេរខ្លួនឯងជា ៣៖ ការសិក្សាថ្នាក់ជាតិលើកទី ៣ ស្តីពីសុខភាពផ្លូវភេទ និងសុខុមាលភាពរបស់អ្នកស្រឡាញ់ភេទដូចគ្នា និងយុវជនដែលនៅមានចម្ងល់ពីយេនឌ័ររបស់ខ្លួន" (របាយការណ៍) (ឆ្នាំ ២០១០) <https://www.latrobe.edu.au/arcshs/downloads/arcshs-research-publications/WTi3.pdf>

ស្ថាប័នប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ជាតិ "ក្មេងប្រុស ដែលចូលចិត្តក្មេងប្រុស៖ ការសិក្សាពីកន្លែងដែលយុវជនស្រឡាញ់ភេទដូចគ្នា ដឹងពីភេទ ទំនាក់ទំនង និងមេរោគអេដស៍" (របាយការណ៍) (ឆ្នាំ ២០១៥) <http://www.nat.org.uk/media/Files/Publications/Boys_Who_Like_Boys.pdf>

វិទ្យាស្ថានអប់រំ Sheffield "ឧបសគ្គ និងការសម្លុត៖ បទពិសោធន៍របស់យុវជនដែលជាអ្នកស្រឡាញ់ភេទដូចគ្នា នៅអឺរ៉ុប" (របាយការណ៍) (ឆ្នាំ ២០០៣) <https://www.shu.ac.uk/sioe/case-studies/ceir.html>

សហប្រជាជាតិ "របាយការណ៍ពិភពលោកស្តីពីអំពើហិង្សាលើកុមារ" (របាយការណ៍) (ឆ្នាំ ២០០៦) <http://www.unicef.org/violencestudy/reports.html>

កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ "ការធ្វើជាអ្នកស្រឡាញ់ភេទដូចគ្នា នៅអាស៊ី៖ របាយការណ៍សម្រាប់ប្រទេសកម្ពុជា - ការពិនិត្យឡើងវិញ និងការវិភាគតាមបែបចូលរួមលើបរិយាកាសច្បាប់ និងសង្គម សម្រាប់អ្នកដែលជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ (LGBT) និងសង្គមស៊ីវិល" (របាយការណ៍) (ឆ្នាំ ២០១៤)

<http://www.asiapacific.undp.org/content/dam/rbap/docs/Research%20&%20Publications/hiv_aids/rbap-hhd-2014-blia-cambodia-country-report.pdf>

អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់សហប្រជាជាតិ "ការឆ្លើយតបរបស់វិស័យអប់រំចំពោះការសម្លុតដោយសារតែការរើសអើងភេទដូចគ្នា" (កូនសៀវភៅ) (ឆ្នាំ ២០១២) <http://unesdoc.យូណេស្កូ.org/images/0021/002164/216493e.pdf>

អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌របស់សហប្រជាជាតិ "ប្រទេសថៃដែលផ្តល់ភាពងាយស្រួលដល់អ្នកស្រឡាញ់ភេទដូចគ្នា៖ ព័ត៌មានសង្ខេបអំពីការសម្លុតនៅសាលារៀន ដោយសារតែនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ" (ឯកសារសង្ខេប) (ឆ្នាំ ២០១៤)

<http://unesdoc.យូណេស្កូ.org/images/0022/002277/227706E.pdf>

វិសន់ សាឡាស់ (Vicente S.Salas) និង ស្រ៊ុន ស្រ៊ន (Srun Sorn) ការស្វែងយល់ពីការផាត់ចេញពីសង្គមនៃស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់ប្រុស និងអ្នកប្តូរភេទ ក្នុងគ្រួសារ និងសហគមន៍ នៅ

តាមតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា និងវិធីដោះស្រាយរបស់ពួកគេ" (របាយការណ៍) (ឆ្នាំ ២០១២)<http://www.aidsdatahub.org/sites/default/files/publication/Cambodia_Journal_GLBT_for_publication.pdf>

វីលាម លីអូណាត (William Leonard) និងអ្នកនិពន្ធដទៃទៀត( Anthony Lyons និង Emily Bariola)ការពិនិត្យស៊ីជម្រៅលើជីវិតឯកជន ២៖ ការឆ្លើយតបនឹងបញ្ហាសុខភាពផ្លូវចិត្ត និងសុខុមាលភាពរបស់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ និងអ្នកប្តូរភេទ (LGBT) នៅអូស្ត្រាលី" (របាយការណ៍) (ឆ្នាំ ២០១៥) <http://glhv.org.au/files/Closer_Look_Private_Lives2.pdf>

## អត្ថបទ និងសេចក្តីប្រកាសព័ត៌មាន

"សកលវិទ្យាល័យបាងកក គាំទ្រឲ្យមានជម្រើសឯកសណ្ឋានតាមយេនឌ័រ" *សារព័ត៌មាន Coconuts Bangkok* (៨ មិថុនា ២០១៥) <http://bangkok.coconuts.co/2015/06/08/bangkok-university-officially-endorses-uniform-gender-choice>

ដាវិដ ហ្គីលបឺត (David Gilbert)ការរើសអើងលើអ្នកប្តូរភេទក្នុងគ្រួសារ និងសាច់ញាតិ ក្នុងប្រទេសមីយ៉ាន់ម៉ា" (សារព័ត៌មាន *Kyoto Review of Southeast Asia*, កញ្ញា ២០១៥) <http://kyotoreview.org/issue-18/familial-transphobia-kinship-opens-myanmar/>

ឌូក្លាស សែនឌ័រ (Douglas Sanders)ទំនាក់ទំនងភេទតែមួយ៖ ការផ្តល់ការទទួលស្គាល់ ក្នុងប្រទេសវៀតណាម និងថៃ" (សារព័ត៌មាន *Kyoto Review of Southeast Asia*, កញ្ញា ២០១៥) <http://kyotoreview.org/issue-18/same-sex-relationships-vietnam-thailand/>

"ប្រទេសកម្ពុជាស្វាគមន៍អាពាហ៍ពិពាហ៍របស់អ្នកស្រឡាញ់ភេទដូចគ្នា បើតាមការលើកឡើងរបស់អ្នកនាំពាក្យរដ្ឋាភិបាល" សារព័ត៌មាន *Khmer Times* (២៤ កញ្ញា ២០១៥) <http://www.khmertimeskh.com/news/16143/cambodia-welcomes-same-sex-marriage--gov---t-spokesman-says/>

"យុទ្ធនាការធំ ដែលមានគោលបំណងលុបបំបាត់ការរើសអើងលើអ្នកស្រឡាញ់ភេទដូចគ្នា" សារព័ត៌មាន *Beyond Blue* (៣១ មីនា ២០១៥) <https://www.beyondblue.org.au/about-us/news/news/2015/03/30/major-campaign-aims-to-stamp-out-discrimination-against-lgbti-people>

"រដ្ឋធម្មនុញ្ញរបស់ប្រទេសនេប៉ាល់នាំមុខគេក្នុងតំបន់ខាងសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា" *សារព័ត៌មាន The World Post* (១០ តុលា ២០១៥) <http://www.huffingtonpost.com/tracy-fehr/nepal-constitution-lgbti-rights_b_8239360.html>

"មោទនភាពបញ្ចប់ជាមួយនឹងពរជ័យតាមបែបព្រះពុទ្ធសាសនា" *សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍ (២២ ឧសភា ២០១២)<http://www.phnompenhpost.com/lifestyle/pride-closes-buddhist-blessing>

សេចក្ដីប្រកាសព័ត៌មានរបស់សហប្រជាជាតិ "ស្ថាប័នសហប្រជាជាតិអំពាវនាវឲ្យរដ្ឋនានាចាត់វិធានការបន្ទាន់ ដើម្បីបញ្ចប់អំពើហិង្សា និងការរើសអើងលើស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់ប្រុស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរភេទនិងអន្តរភេទ (LGBTI) ជាមនុស្សពេញវ័យ ក្មេងជំទង់ និងកុមារ" (២៩ កញ្ញា ២០១៥)
http://www.un.org/apps/news/story.asp?NewsID=52042#.VjsZOpjovIU>

យូគី នីកៃដូ (Yuki Nikaido)"ការសម្លុតរាលដាល សម្រាប់ក្មេងជំទង់ដែលជាប្រុសស្រឡាញ់ប្រុស និងអ្នកស្រឡាញ់ភេទទាំងពីរ" *សារព័ត៌មាន The Asahi Shimbun* (០១ កញ្ញា ២០១៥)
<http://ajw.asahi.com/article/behind_news/social_affairs/AJ201509010026>

## ធនធានអ៊ិនធើណែត

មជ្ឈមណ្ឌលស្រាវជ្រាវ Pew៖ សាសនា និងជីវិតសាធារណៈ: *សមាសភាគសាសនាបែងចែកតាមប្រទេស ២០១០-២០៥០* <http://www.pewforum.org/2015/04/02/religious-projection-table/>

អង្គការយូណេស្កូ: *ផលប៉ះពាល់នៃការសម្លុត និងការរើសអើងភេទដូចគ្នា* <http://www.យូណេស្កូ.org/new/en/education/themes/leading-the-international-agenda/health-education/homophobic-bullying/bullying/> ASEAN SOGIE SOGIE Caucus.
<https://aseansogie.wordpress.com/